ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ខេត្តបាត់ដំបង

## ឆ្នាំ២០២១ - ២០២៥









ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ខេត្តបាត់ដំបង

## ឆ្នាំ២០២១ - ២០២៥

រដ្ឋបាលជលផល និងរដ្ឋបាលខេត្តបាត់ដំបង

## អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាសម្បូរធនធានធម្មជាតិយ៉ាងស្តុកស្តម្ភ ជាពិសេសបឹងទន្លេសាប ដែលមានធនធានជលផលជាច្រើនប្រភេទ ដូចជា មច្ឆជាតិ ថនិកសត្វ ល្មូន បក្សីទឹក វារីរុក្ខជាតិ និងព្រៃលិចទឹក ក្នុងការទ្រទ្រង់ជីវៈចម្រុះ និងជីវភាពរស់នៅរបស់មនុស្សជាតិ ដែលជាការចាំបាច់ត្រូវគ្រប់គ្រង និងការពារ ដើម្បីរក្សាតុល្យភាពរវាងការប្រើប្រាស់ និងការអភិរក្សប្រកបដោយចីរភាព។ ដូច្នេះធនធានជលផលក្នុងបឹងទន្លេសាបមិនត្រឹមតែមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ត្រីសាច់ជារៀងរាល់ថ្ងៃដល់ប្រជាពលរដ្ឋកម្ពុជាប៉ុណ្ណោះទេ ថែមទាំងការពារ និងរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ព្រមទាំងផ្តល់សេវាកម្មផ្នែកទេសចរណ៍ដ៏ល្អប្រសើរផងដែរ។

ជានិច្ចកាល រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ និងរៀបចំគោលនយោបាយសំខាន់ៗជាច្រើនទាក់ទងនឹងការការពារ ការអភិរក្ស និងការគ្រប់គ្រងធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីជលផលប្រកបដោយចីរភាព ដែលជាពំនាក់អាស្រ័យរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើនរយពាន់គ្រួសារ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់បឹងទន្លេសាប ក្នុងការប្រកបរបរចិញ្ចឹមជិវិត ការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

នៅក្រោមសសរស្តម្ភទី១ស្តីពី □**ការនេសាទ និងការគ្រប់គ្រង**□ នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផលសម្រាប់ ឆ្នាំ២០១៥-២០២៤ គឺត្រូវសម្រេចឱ្យបាននូវចក្ខុវិស័យ □**ធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីដែលបានខូចខាត នឹងត្រូវបានស្តារ អភិរក្ស និងការពារ ដើម្បីចូលរួមធានានូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគត**□។ គោលបំណងរួមនៃផែនការយុទ្ធសាស្ត្រនេះគឺ "អ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការ ដើម្បីធានាថា ធនធានជលផលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រើប្រាស់ អភិរក្ស និងគ្រប់គ្រងប្រកបដោយនិរន្តរភាព។

ខេត្តបាត់ដំបងមានផ្ទៃកដីធំមួយស្ថិតនៅក្នុងតំបន់ទំនាបនៃបឹងទន្លេសាប មានសក្តានុពលខ្ពស់ក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈផលនេសាទ ផលិតកម្មកសិកម្ម និងការអភិវឌ្ឍអេកូទេសចរណ៍។ ដោយស្ថានភាពភូមិសាស្ត្រខេត្តបាត់ដំបងជាប់ពាក់ព័ន្ធនឹងតំបន់ទំនាបបឹងទន្លេសាប ដែលសម្បូរទៅដោយជីវៈចម្រុះយ៉ាងស្តុកស្តម្ភ ប៉ុន្តែធនធានទាំងនេះកំពុងទទួលរងការគំរាមកំហែង ជាពិសេស ភ្លើងឆេះព្រៃលិចទឹកតែងកើតមានជារៀងរាល់ឆ្នាំ ដែលបានបង្កឱ្យបាត់បង់ទីជម្រកមច្ឆជាតិ នាំឱ្យប៉ះពាល់ដល់ផលស្តុកធនធានជលផល បរិស្ថាន និងសង្គម អាស្រ័យហេតុនេះ ទើបរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអង្គការ FAO ក្រោមកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ) ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងខេត្តបាត់ដំបង រៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ សម្រាប់ខេត្តបាត់ដំបង។

តាងនាមរដ្ឋបាលជលផល ខ្ញុំសូមគាំទ្រទាំងស្រុងចំពោះការអនុវត្តផែនការគ្រប់គ្រងដ៏មានសារៈសំខាន់នេះ ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកឡើងវិញប្រកបដោយប្រសិទ្ធភាព សម្រាប់ជាប្រយោជន៍ដល់ការអភិរក្សធនធានជលផល និងជីវៈចម្រុះនៃតំបន់ដីសើម ហើយនិងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន។

ជាមួយគ្នានេះដែរ ក្នុងនាមរដ្ឋបាលខេត្តបាត់ដំបង ខ្ញុំសូមគាំទ្រ និងប្រកាសជាផ្លូវការក្នុងការដាក់ឱ្យប្រើប្រាស់នូវផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹករយៈពេល៥ឆ្នាំសម្រាប់ខេត្តបាត់ដំបង ហើយរដ្ឋបាល

ខេត្តនឹងត្រៀមជានិច្ចនូវកិច្ចអន្តរាគមន៍ក្នុងការអនុវត្តនូវផែនការនេះ ដើម្បីធានាឱ្យប្រាកដថា ធនធានជលផលរបស់យើងនឹងបានគ្រប់គ្រងប្រកបដោយនិរន្តរភាព សម្រាប់គាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគត។

ថ្ងៃ.................ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧.. ខែធ្នូ..... ឆ្នាំ២០២១
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល**

ពុំ សុជាំ

ថ្ងៃ.................ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
បាត់ដំបង ថ្ងៃទី.....ខែធ្នូ..... ឆ្នាំ២០២១
**អភិបាល**
**នៃគណៈអភិបាលខេត្តបាត់ដំបង**

សុខ លូ

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងាររៀបចំផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកនៃរដ្ឋបាលជលផល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានគាំទ្រកម្មវិធី □**ជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន** (**ផ្នែកនេសាទ**)□ ហៅកាត់ថា CAPFISH-Capture សម្រាប់ការគ្រប់គ្រងធនធានជលផលនៅកម្ពុជា ព្រមទាំងការបង្កើត និងសម្របសម្រួលការងារគណៈកម្មការតម្រង់ទិសកម្មវិធី ដើម្បីធានានូវកិច្ចសហការល្អរវាងរដ្ឋបាលជលផល ជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ក្រុមការងារសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មការតម្រង់ទិសកម្មវិធី CAPFISH-Capture ចំពោះការគាំទ្រដោយផ្ទាល់ និងកិច្ចប្រឹងប្រែងផ្តល់យោបល់ក្នុងការតម្រង់ទិស និងកែតម្រូវការអនុវត្តកម្មវិធីឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ទន្ទឹមនឹងនេះ ក្រុមការងារក៏សូមថ្លែងអំណរគុណជាពិសេស ចំពោះឯកឧត្តម **សុខ លូ** អភិបាលនៃគណៈ អភិបាលខេត្តបាត់ដំបង និងមន្ត្រីបច្ចេកទេស ដែលបានគាំទ្រ និងសម្របសម្រួលរាល់បេសកកម្មរបស់មន្ត្រីរដ្ឋបាលជលផល ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់រៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ព្រមទាំងការផ្តល់ធាតុចូលតាមរយៈកិច្ចប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធអំពីមូលហេតុនិងបញ្ហាដែលបង្កឱ្យមានភ្លើងឆេះព្រៃ ផលប៉ះពាល់នៃភ្លើងឆេះព្រៃ បទពិសោធន៍ល្អៗនៃការទប់ស្កាត់និងការពន្លត់ភ្លើងឆេះព្រៃ យន្តការគ្រប់គ្រងភ្លើងឆេះព្រៃ និងការស្តារព្រៃលិចទឹកដែលបានឆេះ ជាការរួមចំណែកដ៏សំខាន់ក្នុងរៀបចំផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក។

ក្រុមការងារក៏សូមសម្តែងការកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះឯកឧត្តម **ពុំ សុថា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល លោក លោកស្រី ជាប្រធាន និងអនុប្រធាននាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល និងសហការី ព្រមទាំងលោក លោកស្រី ជាមន្ត្រីខណ្ឌរដ្ឋបាលជលផលបាត់ដំបង ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការជួយរៀបចំឱ្យមានជាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះឡើង ក្រោមការជួយសម្របសម្រួលពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សូមថ្លែងអំណរគុណជូនលោក Alexandre Huynh តំណាងអង្គការ FAO ប្រចាំប្រទេសកម្ពុជា ព្រមទាំងលោក David Brown ប្រធានទីប្រឹក្សាបច្ចេកទេស និងមន្ត្រីបច្ចេកទេសនៃអង្គការ FAO ដែលបានជួយគាំទ្រ និងសម្របសម្រួលការងារបច្ចេកទេសក្នុងការរៀបចំផែនការនេះឡើង។

ផែនការទប់ស្កាត់និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់ខេត្តកំពង់ធំ ក៏បានទទួលធាតុចូលពីអង្គការមួយចំនួនដែលមានសកម្មភាពក្នុងតំបន់បឹងទន្លេសាប ដូចជា UNESCO, WCS, KFW, BirdLife VSO និង CI ក្នុងការចែករំលែកព័ត៌មានលម្អិតពីការងារ និងបទពិសោធន៍របស់ពួកគេនៅក្នុងតំបន់គោលដៅរៀងៗ ខ្លួនផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកដល់ប្រតិភូសហភាពអឺរ៉ុបប្រចាំនៅប្រទេសកម្ពុជា ជាពិសេសឯកឧត្តម □□□□□□□ □□□□□□□ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប លោក □□□□□ □□□□□□□□ ប្រធានសហប្រតិបត្តិការនៃប្រតិភូសហភាពអឺរ៉ុប និងលោក Aymeric Roussel អតីតអ្នកគ្រប់គ្រងកម្មវិធី និងលោក □□□□□□□□□□ □□□□□□ អ្នកគ្រប់គ្រងកម្មវិធី □□□□□□□□-□□□□□□□□ និងជាសហប្រធាននៃក្រុមការងារបច្ចេកទេសសម្រាប់វិស័យជលផល ដែលបានជួយពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ផ្តល់យោបល់លើសេចក្តីព្រាងផែនការនេះ និងផ្តល់ការគាំទ្រថវិកាដល់ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តគម្រោង "កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ" ដែលអនុវត្តដោយរដ្ឋបាលជលផល។

# មាតិកា


**អារម្ភកថា**........................................ Error! Bookmark not defined.

**សេចក្តីថ្លែងអំណរគុណ** ........................................iii

**១. សេចក្តីផ្តើម**........................................1

**២. ជីវៈចម្រុះនៅក្នុងតំបន់ទំនាបបឹងទន្លេសាប ខេត្តបាត់ដំបង** ........................................2

**៣. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ ខេត្តបាត់ដំបង** ........................................3

៣១. ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកឯកភ្នំ ........................................4

៣២. ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកមោងឫស្សី ........................................5

៣៣. ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកសង្កែ ........................................5

៣៤. ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកថ្មគោល........................................6

**៤. បញ្ហាប្រឈមនៃការគ្រប់គ្រងព្រៃលិចទឹកក្នុងខេត្តបាត់ដំបង**........................................6

៤.១ មូលហេតុនៃភ្លើងឆេះព្រៃលិចទឹក........................................7

៤.២ ទីតាំងភ្លើងឆេះព្រៃលិចទឹក........................................8

៤.៣ ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ........................................8

៤.៤ បញ្ហាប្រឈមក្នុងការចាត់វិធានការពន្លត់ភ្លើងឆេះព្រៃ ........................................13

៤.៥ ការអនុវត្តច្បាប់ជលផលដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក........................................15

**៥. ដំណើរការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបង**........................................15

៥.១ ការទប់ស្កាត់ ........................................16

*៥.១.១ ការពិនិត្យឡើងវិញ........................................16*

*៥.១.២ ការកាត់បន្ថយហានិភ័យ........................................17*

*៥.១.៣ ការត្រៀមរួចជាស្រេច........................................18*

៥.២ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក ........................................21

៥.៣ ការស្តារព្រៃលិចទឹក........................................23

*៥.៣.១ ការសិក្សាអំពីវិធីសាស្ត្រស្តារព្រៃលិចទឹកទៅតាមស្ថានភាពជាក់ស្តែង ........................................23*

*៥.៣.៣ ការស្តារព្រៃលិចទឹកដោយការដាំកូនឈើបន្ថែម........................................25*

**៦. សមត្ថភាពយឺនឌ័រនៅក្នុងការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក**........................................28

**៧. ក្របខណ្ឌការងារនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក** ........................................29

៧.១ ពេលវេលាអនុវត្ត ........................................29

៧.២ គោលបំណង ........................................29

៧.៣ គោលដៅ........................................30

៧.៤ លទ្ធផលរំពឹងទុក ........................................30

**៨. ការត្រួតពិនិត្យ និងវាយតម្លៃ**........................................32

**៩. សកម្មភាព និងថវិកានៃផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត ឆ្នាំ២០២១-២០២៥** ........................................34

**១០. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ថ្នាក់ស្រុក ឆ្នាំ ២០២១-២០២៥ ..... 39**
១០.១ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ស្រុកឯកភ្នំ ឆ្នាំ២០២១-២០២៥ ..... 39
១០.២ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ស្រុកមោងឫស្សី ឆ្នាំ២០២១-២០២៥ ..... 44
១០.៣ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកស្រុកសង្កែ ឆ្នាំ២០២១-២០២០ ..... 49
១០.៤ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ស្រុកថ្មគោល ឆ្នាំ២០២១-២០២២ ..... 54
**១១. ឧបសម្ព័ន្ធ ..... 59**
ឧបសម្ព័ន្ធ១៖ តារាងឈ្មោះប្រភេទព្រៃលិចទឹកក្នុងតំបន់ទំនាបបឹងទន្លេសាប ..... 59
ឧបសម្ព័ន្ធ២៖ បញ្ជីឈ្មោះជីវៈចម្រុះនៅក្នុងក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាប ខេត្តបាត់ដំបង ..... 62
ឧបសម្ព័ន្ធ៣៖ ផែនទីភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបង ..... 64

## ១. សេចក្ដីផ្ដើម

បឹងទន្លេសាបត្រូវបានពិពណ៌នាដោយប្រជាជនកម្ពុជាថាជាបេះដូងនៃវប្បធម៌ និងសេដ្ឋកិច្ចជាតិរបស់ខ្លួន ហើយតាមទស្សនៈពិភពលោកក៏បានទទួលស្គាល់ថាជាបេះដូងនៃធនធានជលផលទឹកសាបរបស់កម្ពុជាដែរ ជាបឹងទឹកសាបដ៏ធំនៅអាស៊ីអាគ្នេយ៍ ជាតំបន់ដីសើមដែលមានផលិតភាពខ្ពស់ក្នុងចំណោមតំបន់ដីសើមជាច្រើននៅលើពិភពលោក។ ព្រៃលិចទឹក និងវាលទំនាបលិចទឹកនៅជុំវិញបឹងទន្លេសាបផ្ដល់ជម្រកដ៏ល្អប្រសើរដល់មច្ឆជាតិ ឧរង្គសត្វ និងសត្វស្លាបដែលកំពុងរងការគំរាមកំហែងមួយចំនួន សម្រាប់បង្កាត់ពូជ ពងកូន និងផ្ដល់ចំណី។ យោងតាមទិន្នន័យរបស់រដ្ឋបាលជលផល ត្រីដែលចាប់បានពីបឹងទន្លេសាប ផ្ដល់នូវប្រូតេអ៊ីនជាង៦០%នៅក្នុងរបបអាហារក្នុងប្រទេសកម្ពុជា (ព្រឹត្តិប័ត្រវិទ្យាសាស្ត្រAPN លេខ៣ ខែមីនា ឆ្នាំ២០១៣ ប្រភពសារធាតុចិញ្ចឹមនៃបឹងទន្លេសាប ប្រទេសកម្ពុជា)។

ដោយសារចំនួនប្រជាជន និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមានការរីកចម្រើនលូតលាស់ជាលំដាប់ ព្រមទាំងការអនុវត្តច្បាប់ស្ដីពីជលផលនៅមានកម្រិត ធនធានជលផលនៅក្នុងបឹងទន្លេសាបកំពុងរងការគំរាមកំហែង ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារសកម្មភាពរបស់មនុស្សក្នុងការប្រកួតប្រជែងប្រើប្រាស់ធនធានជលផល និងការកាប់ឆ្ការឈូសឆាយព្រៃលិចទឹកយកដីធ្វើកសិកម្ម ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់មច្ឆជាតិ រុក្ខជាតិ សត្វព្រៃ សត្វស្លាប និងជីវៈចម្រុះនៃបឹងទន្លេសាប។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្រិតទឹកបឹងទន្លេសាបបានឈានដល់កំរិតទាបដោយសារតែការប្រែប្រួលអាកាសធាតុ ដូចជា ការកើនឡើងនូវកំដៅ គ្រោះរាំងស្ងួត ជាពិសេសការបាត់បង់គម្របព្រៃនៅតំបន់ខាងលើខ្សែទឹក និងការរៀបចំដីសម្រាប់ផលិតកម្មកសិកម្មមិនមាននិរន្តរភាព។ លក្ខខណ្ឌទាំងនេះបានបង្កឱ្យភ្លើងឆេះព្រៃលិចទឹកកាន់តែមានសភាពធ្ងន់ធ្ងរ ហើយជាលទ្ធផលបានធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់កន្លែងអភិរក្សជលផល តំបន់វ៉ាមសារព្រែកទាល់ (ជាដែនជម្រករបស់បក្សីទឹកធំជាងគេនៅអាស៊ីអាគ្នេយ៍) ដែលជាជម្រកត្រី និងសត្វស្លាប សម្រាប់បង្កកំណើត និងផ្គត់ផ្គង់ចំណី។

មានកត្តាសំខាន់ចម្បងពីរដែលត្រូវបានគេចាត់ទុកថាជាមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់ទំនាបបឹងទន្លេសាប គឺដោយសារឧប្បត្តិហេតុអចេតនា និងចេតនារបស់មនុស្ស។ ករណីភ្លើងឆេះព្រៃដែលកើតឡើងដោយអចេតនារួមមាន ការប្រើភ្លើងនិងផ្សែងដើម្បីប្រមូលទឹកឃ្មុំ ការបោះចោលកន្ទុយបារីដែលនៅមានភ្លើងនៅក្នុងគំនរសេរីវាង្គស្ងួត ការចំអិនអាហារដោយមិនបានពន្លត់ភ្លើងមុននឹងចាកចេញ។ ករណីភ្លើងឆេះព្រៃដែលកើតឡើងដោយចេតនារួមមាន ការកាប់និងដុតព្រៃលិចទឹកដើម្បីយកដីធ្វើកសិកម្ម ការដុតស្មៅព្រៃដើម្បីចាប់សត្វ និងរកសត្វគោ-ក្របីដែលបានលែងឱ្យស៊ីស្មៅនៅក្នុងព្រៃ និងការត្រួសត្រាយដុតព្រៃដើម្បីដាក់ឧបករណ៍នេសាទ សាច់ដៃកាត់អួរ ឬប្រឡាយ។

ភ្លើងឆេះព្រៃគឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរបំផុតចំពោះព្រៃលិចទឹក។ ដោយសារព្រៃលិចទឹកជាកន្លែងបន្តពូជ និងប្រភពផ្ដល់ចំណីដល់មច្ឆជាតិ សត្វស្លាប និងសត្វព្រៃជាច្រើនប្រភេទ ការបាត់បង់ព្រៃលិចទឹកនឹងនាំឱ្យមានការថយចុះទាំងប្រភេទ ទំហំ និងចំនួនត្រី ឧរង្គសត្វ សត្វល្មូន ថនិកសត្វ និងសត្វស្លាប។ បើសិនជាព្រៃលិចទឹកត្រូវបានរងនូវការឆេះជាញឹកញាប់ តំបន់នោះនឹងប្រែក្លាយទៅជាវាលស្មៅលិចទឹក និងគ្របដណ្ដប់ដោយប្រភេទរុក្ខជាតិរាតត្បាតចង្រៃ (បន្លាយួន) ដែលជាការបាត់បង់នូវជីវៈចម្រុះកំណើតដើមរបស់វា។

ទន្ទឹមនឹងនេះ ផលវិបាកនៃភ្លើងឆេះព្រៃលិចទឹកនៅតំបន់ទំនាបលិចទឹកបឹងទន្លេសាបក្នុងខេត្តបាត់ដំបង បានរួមចំណែកដ៏សំខាន់ដល់ការថយចុះជាលំដាប់នូវជីវៈចម្រុះនៅក្នុងតំបន់ទំនាបបឹងទន្លេសាបដែលមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជានេសាទ។ ដោយសារតែមើលឃើញនូវផលវិបាកបែបនេះហើយ បានជា

រដ្ឋបាលជលផល សហការជាមួយផ្នែកគាំទ្របច្ចេកទេសរបស់អង្គការ FAO ដែលកំពុងអនុវត្តកម្មវិធី □**ជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និង បរិយាប័ន្នផ្នែកនេសាទ**□ បានកំណត់ និងធ្វើការជាមួយអង្គភាព និងអ្នកពាក់ព័ន្ធសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក ឃុំ និងសហគមន៍នៅក្នុងខេត្តបាត់ដំបង ដើម្បីរៀបចំ និងអនុវត្តផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក កាត់បន្ថយហានិ-ភ័យនៃភ្លើងឆេះព្រៃនៅក្នុងខេត្ត។ នោះហើយជាមូលហេតុដែលផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកត្រូវបានបង្កើតដោយមានការចូលរួម ដើម្បីធានាថាការឆ្លើយតប ឬការជួយធ្វើអន្តរាគមន៍ទាន់ពេលវេលាត្រូវបានអនុវត្តដោយមានភាពបត់បែន និងរលូន។

ក្រុមការងារបច្ចេកទេសគាំទ្រការងារគ្រប់គ្រងភ្លើងឆេះព្រៃក្នុងខេត្តបាត់ដំបង រួមមានមន្ត្រីចំនួន១០នាក់ មកពីនាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផលនៃរដ្ឋបាលជលផល ដឹកនាំដោយលោក **ម៉ុន រ៉ាស៊ី** (ឧបសម្ព័ន្ធ១៖ បញ្ជីឈ្មោះសមាជិកក្រុម) ខណ្ឌរដ្ឋបាលជលផលបាត់ដំបង និងទីប្រឹក្សាបច្ចេកទេសអង្គការFAO បានចុះមូលដ្ឋាន ប្រមូលព័ត៌មានបឋម និងទិន្នន័យដែលមានស្រាប់នៅមូលដ្ឋានដើម្បីរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃដើម្បីអនុវត្តនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។

បេសកកម្មនៅមូលដ្ឋានបានចាប់ធ្វើនៅក្នុងខែឧសភា ឆ្នាំ២០២០ ដើម្បីជួបប្រជុំជាមួយនឹងសហគមន៍ និងអ្នកពាក់ព័ន្ធក្នុងឃុំ និងស្រុកគោលដៅ ដើម្បីប្រមូលព័ត៌មានអំពីមូលហេតុនៃភ្លើងឆេះព្រៃ សកម្មភាពដែលបានឆ្លើយតបទៅនឹងភ្លើងឆេះព្រៃលិចទឹក ស្ថាប័នពាក់ព័ន្ធនឹងការទប់ស្កាត់និងពន្លត់ភ្លើងឆេះព្រៃ យន្តការគ្រប់គ្រងភ្លើងឆេះព្រៃដែលមានស្រាប់ ប្រសិទ្ធភាពការងាររបស់យន្តការនេះ វិធីសាស្ត្រស្តារព្រៃលិចទឹកដែលត្រូវឆេះ និងតម្រូវការឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់គាំទ្រការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។ ទន្ទឹមនឹងនេះ និយាមកានៃតំបន់ភ្លើងឆេះព្រៃលិចទឹកត្រូវបានប្រមូលក្រោយពេលប្រជុំ ហើយបានយកទៅផលិតផែនទីតំបន់ភ្លើងឆេះព្រៃលិចទឹក ក្រោយពីបានបញ្ចប់បេសកកម្មនៅមូលដ្ឋាន។

## ២. ជីវៈចម្រុះនៅក្នុងតំបន់ទំនាបបឹងទន្លេសាប ខេត្តបាត់ដំបង

ផ្នែកខាងលិចនៃខេត្តបាត់ដំបង ខាងលើផ្លូវជាតិលេខ៦ គ្របដណ្តប់ប្រហែល៣/៤នៃផ្ទៃដីសរុបរបស់ខេត្ត ជាតំបន់ខ្ពង់រាប និងព្រៃឈើ សំបូរទៅដោយធនធានធម្មជាតិដែលមានលក្ខណៈល្អប្រសើរសម្រាប់ការងារអភិរក្សជីវៈចម្រុះ ការអភិរក្សទឹកក្រោមដី ការបង្កើនចំណូលដោយផ្អែកលើផលនិងអនុផលព្រៃឈើ ផលិតកម្មកសិកម្ម ឧស្សាហកម្ម និងការចិញ្ចឹមសត្វ។

ផ្នែកខាងកើត ខាងក្រោមផ្លូវជាតិលេខ៦ គ្របដណ្តប់ប្រហែល១/៤នៃផ្ទៃដីសរុបរបស់ខេត្តបាត់ដំបង គឺជាតំបន់វាលទំនាបលិចទឹកបឹងទន្លេសាប មានកម្រិតជម្រាលទាបជាង១០% លាតសន្ធឹងពីខាងលិចទៅខាងកើតរហូតដល់បឹងទន្លេសាប។ ដីនៅក្នុងតំបន់នេះជាប្រភេទដីល្បាប់ មានជីជាតិល្អសម្រាប់ការដាំដុះ ជាពិសេសស្រូវប្រាំង ស្រូវវស្សា ស្រូវបណ្តែញទឹក ដំណាំរួមផ្សំ (ម្ទេស ពោត ល្ង សណ្តែក) ព្រមទាំងជាដែននេសាទនៅរដូវវស្សា និងរដូវប្រាំង ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជានេសាទ និងផ្គត់ផ្គង់តម្រូវការអាហាររូបត្ថម្ភរបស់សហគមន៍ដែលរស់នៅក្នុងខេត្ត និងនៅខេត្តផ្សេងៗទៀតផង។

វាលទំនាបបឹងទន្លេសាប ក្នុងខេត្តបាត់ដំបង មានធនធានជលផលជាច្រើនប្រភេទដូចជា ព្រៃលិចទឹក វារីរុក្ខជាតិ ត្រី សត្វស្លាប ថនិកសត្វ ឧរង្គសត្វ និងពពួកល្មូន)។ ម៉្យាងវិញទៀត ដីវាលទំនាបបឹងទន្លេសាបជាប្រភេទដីទំនាបល្បាប់ (Lacustrine Alluvias Soil) ដែលជារួមគឺជាដីមានជាតិល្អ។ យោងទៅតាមអាយុនៃដី ដីប្រភេទនេះបានបែងចែកជាពីរប្រភេទគឺ៖ ដីល្បាប់ចាស់ និងដីល្បាប់ថ្មី មានសមាមាត្រ ប៉ូតាស្យូម កំបោរ និងអាស៊ីដផូសហ្វ័រគ្រប់គ្រាន់ និងមានសមាសភាព ដីឥដ្ឋ ខ្សាច់ និងគ្រួសតូចល្អិតលាយចូលគ្នា ដែលមានអំណោយផលល្អដល់

ដំណាំស្រូវ ពោត ម្ទេស សណ្តែកបាយ និងអំពៅ ដែលជាប្រភពផ្តល់អាហារមានប្រូតេអ៊ីនខ្ពស់ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាកសិករ និងអ្នកនេសាទដែលរស់នៅជុំវិញបឹងទន្លេសាប។

បឹងទន្លេសាបដែលត្រូវបានភ្ជាប់ទៅនឹងទន្លេមេគង្គតាមរយៈទន្លេសាប បង្កើតបានជាប្រព័ន្ធអេកូឡូស៊ីមួយប្លែក ជាជម្រករបស់ពពួកសត្វជាច្រើនប្រភេទរួមមាន ត្រីទឹកសាបជាង២០០ប្រភេទដែលរស់នៅក្នុងបឹងទន្លេសាប ក្នុងនោះមាន៧០ប្រភេទនៃត្រីមានតម្លៃពាណិជ្ជកម្មខ្ពស់ ពស់ទឹកចំនួន២៣ប្រភេទ អណ្តើកចំនួន១៣ប្រភេទ ដែលរស់នៅ និងចិញ្ចឹមជីវិតនៅក្នុង និងនៅជុំវិញបឹងទន្លេសាប (www.globalnature.org/en/living-lakes/asia/tonle-sap#)។

នៅក្នុងទំនាបបឹងទន្លេសាបនៃខេត្តបាត់ដំបង មានតំបន់រ៉ាមសារព្រែកទាល់ ស្ថិតក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ តំបន់រ៉ាមសារព្រែកទាល់គឺជាបរនីយជីវមណ្ឌលមួយក្នុងចំណោមបរនីយជីវមណ្ឌលទាំងបីនៅក្នុងបឹងទន្លេសាប ដែលត្រូវបានគេស្គាល់ថាជាបន្ទាយសត្វស្លាបដ៏គួរឱ្យទាក់ទាញ និងមានតំលៃអភិរក្សបំផុតនៅក្នុងប្រទេសកម្ពុជា។ វាជាកន្លែងដែលអ្នកជំនាញខាងបក្សីសត្វព្យាយាមធ្វើការអភិរក្សសម្រាប់សត្វស្លាបដ៏កម្រមួយចំនួនដែលប្រមូលផ្តុំគ្នាដើម្បីបង្កាត់ និងបន្តពូជ ដូចជា រនាលស ត្រដក់ធំ និងទុងប្រផេះ។ អ្នកទៅទស្សនាតំបន់រ៉ាមសារព្រែកទាល់ ទោះបីជាមិនសូវចាប់អារម្មណ៍នឹងសត្វស្លាបក៏ដោយ ក៏នៅតែអត់ទ្រាំស្ងើចសរសើរមិនបានចំពោះវត្តមាននូវបក្សីដែលមានស្លាបធំវែង និងការបង្កើតសំបុកធំៗជាច្រើន។

ក្រៅពីការប្រមូលផ្តុំនៃសត្វស្លាប តំបន់ទំនាបបឹងទន្លសាបក្នុងខេត្តបាត់ដំបង មានប្រភេទព្រៃលិចទឹក និងព្រៃស្បាតប្រហែលជាង២០០ប្រភេទ (ឧបសម្ព័ន្ធ២៖បញ្ជីឈ្មោះព្រៃលិចទឹក) និងតិណជាតិជាច្រើនប្រភេទដែលប្រទះឃើញជាទូទៅដូចជា គួរ ផ្ទោល ច្រកែង សណ្តាន់ អង្កត់ខ្មៅ បាយដំណើប និងក្របៅស្វា។ ប្រភេទរុក្ខជាតិដែលមានលប់នៅក្នុងវាលទំនាបបឹងទន្លេសាបរួមមាន រាំង ផ្ទោល រំដេញក្អែក ស្មៅគោ កំប្លោក កំភ្លៅនាង កន្ទ្រាំងស្មារ និងបន្លាយូន។ គួរកត់សម្គាល់ផងដែរថា មានស្មៅ និងតិណជាតិមួយចំនួនដូចជាស្រងែ មានសារៈសំខាន់ចំពោះការអភិរក្សជីវៈចម្រុះ និងសន្និធិហ្សែនចម្រុះសម្រាប់ការបន្តពូជរបស់មច្ឆជាតិ ឧរង្គសត្វ និងសត្វស្លាប (ឧបសម្ព័ន្ធ៣៖ បញ្ជីឈ្មោះជីវៈចម្រុះនៅក្នុងក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាប ខេត្តបាត់ដំបង)។

មានត្រីជាង២០០ប្រភេទ ប្រើប្រាស់ព្រៃលិចទឹក និងវាលស្មៅនៅក្នុងតំបន់ទំនាបបឹងទន្លេសាបជាជម្រកសម្រាប់បង្កាត់ ពង ភ្ញាស់កូន និងប្រភពផ្តល់ចំណី។ ព្រៃលិចទឹកបានចេញផ្កា ផ្លែ និងទម្លាក់គ្រាប់ទៅក្នុងទឹកចាប់ពីពាក់កណ្តាលរដូវទឹកជំនន់ (ពីខែកញ្ញាដល់ខែធ្នូ) ជារៀងរាល់ឆ្នាំ ដែលជាប្រភពនៃដំណុះរុក្ខជាតិតាមបែបធម្មជាតិ និងជាប្រភពអាហារសម្រាប់ត្រីប្រហែលជា៣៤ប្រភេទ (Impacts on the Tonle Sap Ecosystem, June 2010, MRC)។

នៅក្នុងទំនាបបឹងទន្លេសាបខេត្តបាត់ដំបង មានកន្លែងអភិរក្សជលផលធំៗចំនួន៧កន្លែង គ្របដណ្តប់លើផ្ទៃដីសរុប៥៣.៧៥០ហិកតា ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយខណ្ឌរដ្ឋបាលជលផលបាត់ដំបង និងសហគមន៍នេសាទចំនួន៤៦ គ្របដណ្តប់លើផ្ទៃដីសរុប១៨១,៣១១ហិកតា ក្រោមការគ្រប់គ្រងផ្ទាល់របស់សហគមន៍នេសាទក្នុងមូលដ្ឋានសាមី ដោយមានការគាំទ្រពីខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។

## ៣. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ ខេត្តបាត់ដំបង

បាត់ដំបងគឺជាខេត្តមួយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានព្រំប្រទល់ខាងកើតជាប់ខេត្តពោធិ៍សាត់ និងបឹងទន្លេសាប ខាងលិចជាប់នឹងប្រទេសថៃ ខាងជើងជាប់នឹងខេត្តបន្ទាយមានជ័យ ហើយនិងខាងត្បូងជាប់នឹងខេត្តពោធិ៍សាត់។ ខេត្តបាត់ដំបងស្ថិតនៅភាគពាយ័ព្យនៃប្រទេស មានចំងាយ២៩១គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ លាតសន្ធឹងលើផ្ទៃដីសរុប១១.៧៤៨គីឡូម៉ែត្រការ៉េ។

ផ្អែកលើក្របខណ្ឌរដ្ឋបាលគ្រប់គ្រង ខេត្តបាត់ដំបងមានក្រុងចំនួន១ និងស្រុកចំនួន១៣ មានប្រជាជនសរុបចំនួន២៦៣.៤៣៥គ្រួសារ ស្មើនឹង១.២០៥.០៥០នាក់ (ស្ត្រី៦០២.៩៩៤នាក់) ក្នុងនោះមាន៧២.២០% ជាកសិករមានមុខរបរកសិកម្មជាចម្បង (ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ក្រសួងផែនការ ២០១៩)។

ទាក់ទងនឹងការគ្រប់គ្រងព្រៃលិចទឹក មានតែស្រុកចំនួន៤ ក្នុងចំណោមស្រុកទាំង១៣គឺ ស្រុកឯកភ្នំ ស្រុកសង្កែ ស្រុកមោងឫស្សី និងស្រុកថ្មគោល ត្រូវបានកំណត់ជាស្រុកគោលដៅសម្រាប់ការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយគម្រោង CAPFISH-Capture ព្រោះស្រុកទាំង៤នេះមានវាលស្មៅ ព្រៃលិចទឹក ព្រមទាំងមានសេចក្តីរាយការណ៍មកថាករណីភ្លើងឆេះព្រៃលិចទឹកមានកើតឡើងជារៀងរាល់ឆ្នាំ។

នៅក្នុងស្រុកគោលដៅទាំងបួន មានឃុំតែចំនួន១៩ ក្នុងចំណោមឃុំចំនួន៣៥ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។ ដោយផ្អែកលើទំហំព្រៃលិចទឹកដែលមាននៅក្នុងស្រុកទាំង៤ ស្រុកឯកភ្នំជាប់ចំណាត់ថ្នាក់លេខ១ ស្រុកសង្កែជាប់ចំណាត់ថ្នាក់លេខ២ ស្រុកមោងឫស្សីជាប់ចំណាត់ថ្នាក់លេខ៣ ខណៈដែលស្រុកថ្មគោលមានព្រៃលិចទឹកតិចជាង ជាប់ចំណាត់ថ្នាក់ចុងក្រោយ។

តាមតួលេខដែលផ្តល់ដោយខណ្ឌរដ្ឋបាលជលផលបាត់ដំបង ផ្ទៃដីព្រៃលិចទឹកសរុបនៅក្នុងខេត្ត មានទំហំ ២២៤.២១០ហិកតា ស្មើនឹង៣៤.៦៣%នៃផ្ទៃដីព្រៃលិចទឹកសរុប (៦៤៧.៤០៦ហិកតា) នៅក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាបទាំងមូល ដែលកំណត់ដោយអនុក្រឹត្យលេខ១៩៧ ដែលនៅក្នុងនោះ១២២.២៨៩ហ.ត ជាតំបន់រ៉ាមសារព្រែកទាល់ ស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

## ៣.១ ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកឯកភ្នំ

ឯកភ្នំជាស្រុកគោលដៅមួយក្នុងចំណោមស្រុកគោលដៅទាំង៤នៅក្នុងខេត្តបាត់ដំបង មានឃុំចំនួន៥ ក្នុងចំណោមឃុំទាំង៧ គឺឃុំព្រែកនរិន្ទ ឃុំព្រែកហ្លួង ឃុំពាមឯក ឃុំព្រៃចាស់ និងឃុំកោះជីវាំង ពាក់ព័ន្ធនឹងការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក។ ក្នុងចំណោមឃុំគោលដៅទាំង៥ មានឃុំសំខាន់ៗចំនួន២ គឺឃុំព្រៃចាស់ និងឃុំកោះជីវាំង ដែលជាឃុំបណ្តែតទឹកស្ថិតនៅក្បែរនឹងបឹងទន្លេសាប មានព្រៃលិចទឹកច្រើនជាងគេដែលនឹងដើរតួចំបងក្នុងការដឹកនាំដោយផ្ទាល់ក្នុងការត្រួតពិនិត្យ ទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ក្នុងខណៈដែលឃុំគោលដៅបីទៀតនឹងចូលរួមចំណែកដោយប្រយោលក្នុងការជួយកាត់បន្ថយហានិយភាព និងអត្រានៃការកើតមានឡើងនូវភ្លើងឆេះព្រៃលិចទឹកនៅក្នុងភូមិសាស្ត្រស្រុកឯកភ្នំ។

ស្រុកឯកភ្នំលាតសន្ធឹងលើផ្ទៃដីសរុបចំនួន៦៣៥គីឡូម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់នឹងស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះនៃខេត្តបន្ទាយមានជ័យ ព្រមទាំងស្រុកពួកក្នុងខេត្តសៀមរាប, ខាងត្បូងជាប់នឹងស្រុកសង្កែ និងក្រុងបាត់ដំបងនៃខេត្តបាត់ដំបង, ខាងកើតជាប់នឹងស្រុកពួកនៃខេត្តសៀមរាប និងបឹងទន្លេសាប, ហើយខាងលិចជាប់នឹងស្រុកថ្មគោល និងក្រុងបាត់ដំបង ខេត្តបាត់ដំបង។

ស្រុកឯកភ្នំមានប្រជាជនសរុបចំនួន៨២.៦០២នាក់ (ស្រី៤១.៨២៦នាក់) ស្មើនឹង១៨.២០៥គ្រួសារ ក្នុងនោះមាន៧៣.០២% នៃប្រជាជនសរុបជាកសិករប្រកបរបរកសិកម្មជាចម្បង ជាពិសេសដាំណាំស្រូវវស្សា ស្រូវប្រាំង ពោត សណ្តែកបាយ ល្ង ដំឡូងមី ម្រេច មៀន ស្វាយចន្ទី ស្វាយ កៅស៊ូ និងការចិញ្ចឹមសត្វគោ ក្របី (ទិន្នន័យសេដ្ឋកិច្ចសង្គម ស្រុកឯកភ្នំ ខែកុម្ភៈ ឆ្នាំ២០២០)។

នៅក្នុងវិស័យកសិកម្មនេះ ប្រមាណជា៣១.៦២%នៃប្រជាជនកសិករសរុប ពាក់ព័ន្ធនឹងដំណាំស្រូវប្រាំង និងស្រូវវស្សា ដែលបានដាំដុះនៅលើផ្ទៃដីស្រែសរុបចំនួន១០.៨៧៦ហិកតា ក្នុងនោះផ្ទៃដីដីស្រែចំនួន៨៩៦៣ហិកតា ដែលភាគច្រើនស្ថិតនៅក្នុងតំបន់២ និងតំបន់៣ (ទិន្នន័យសេដ្ឋកិច្ច-សង្គម ស្រុកសង្កែ ខែកុម្ភៈ ឆ្នាំ២០២០)។

## ៣.២ ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកមោងឫស្សី

ស្រុកមោងឫស្សីមានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃខេត្តបាត់ដំបង មានចំងាយប្រហែល៥២គីឡូម៉ែត្រពីក្រុងបាត់ដំបង តាមបណ្តោយផ្លូវជាតិលេខ៥។ ស្រុកមោងឫស្សីមានព្រំប្រទល់ខាងត្បូងជាប់នឹងស្រុកបាកាន និងស្រុកវាលវែងនៃខេត្តពោធិ៍សាត់ ខាងជើងជាប់នឹងស្រុកសង្កែនៃខេត្តបាត់ដំបង និងបឹងទន្លេសាប ខាងលិចជាប់នឹងស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ហើយខាងកើតជាប់នឹងស្រុកបាកាននៃខេត្តពោធិ៍សាត់ និងបឹងទន្លេសាប។ ស្រុកនេះជាស្រុកមួយក្នុងចំណោមស្រុកគោលដៅទាំង៤ ដែលមានឃុំចំនួន៥ក្នុងចំណោមឃុំទាំង៩គឺ ឃុំជ្រៃ ឃុំកកោះ ឃុំឫស្សីក្រាំង ឃុំព្រៃតូច និងឃុំតាលាស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដោយសារវត្តមាននៃព្រៃលិចទឹក និងការកើតមានឡើងនូវភ្លើងឆេះព្រៃលិចទឹកនៅក្នុងឃុំគោលដៅ។

ស្រុកមោងឫស្សីមានប្រជាជនសរុបចំនួន១៣៥.១៣២នាក់ (ស្ត្រី៦៨.២៤៧នាក់) ស្មើនឹង២៨.៥១៦គ្រួសារ ដែលក្នុងនោះមានប្រហែល៧៧,៣០% ជាកសិករប្រកបរបរកសិកម្មជាចម្បង (ស្រូវវស្សា ស្រូវប្រាំង ការចិញ្ចឹមសត្វ ដំឡូងមី ស្វាយ អំពៅ ល្ង ដំឡូងជ្វា សណ្តែកដី សណ្តែកសៀង នេសាទត្រី និងកែច្នៃអនុផលព្រៃឈើ។ ក្រៅពីមុខរបរកសិកម្មកសិករប្រហែល០,៩០%នៃចំនួនកសិករសរុបជាអ្នកនេសាទត្រី រស់ក្នុង និងក្បែរតំបន់ទំនាបបឹងទន្លេសាបក្នុងស្រុកមោងឫស្សី (ទិន្នន័យសេដ្ឋកិច្ចសង្គមរបស់ស្រុកមោងឫស្សី ខែមីនា ឆ្នាំ២០១៩)។

ក្នុងវិស័យកសិកម្ម មានកសិករចំនួនប្រហែល៦៩,៧០% នៃចំនួនកសិករមានមុខរបរកសិកម្មសរុប ពាក់ព័ន្ធនឹងការធ្វើស្រូវប្រាំង និងស្រូវវស្សានៅលើផ្ទៃដីសរុប៣៦.៥៣៧ហិកតា ក្នុងនោះ៦.១៤៧ហិកតា ជាដីស្រែប្រាំងដែលភាគច្រើនស្ថិតនៅក្នុងតំបន់២ និងមួយចំនួនស្ថិតនៅតំបន់៣នៃទំនាបបឹងទន្លេសាប។ ផ្ទៃដីស្រូវប្រាំងបានកើនពី៥.៧៥១ ដល់៦.១៤៧ហិកតា ក្នុងចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០១៩ ដែលភាគច្រើនគឺជាលទ្ធផលនៃការកាប់រានដីព្រៃលិចទឹក (ទិន្នន័យសេដ្ឋកិច្ចសង្គម ស្រុកមោងឫស្សី ខែមីនា ឆ្នាំ២០២០)។

## ៣.៣ ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកសង្កែ

ស្រុកសង្កែលាតសន្ធឹងលើផ្ទៃដីសរុប៧១.០២០ហិកតា មានព្រំប្រទល់ជាប់នឹងស្រុកឯកភ្នំនៃខេត្តបាត់ដំបង នៅភាគខាងជើង ស្រុកមោងឫស្សី និងស្រុកគាស់ក្រឡនៃខេត្តបាត់ដំបង នៅភាគខាងត្បូង ស្រុកមោងឫស្សី ខេត្តបាត់ដំបង និងបឹងទន្លេសាបនៅភាគខាងកើត និងស្រុកបាណន់ និងស្រុកឯកភ្នំ ខេត្តបាត់ដំបង នៅភាគខាងលិច។ ស្រុកសង្កែក៏ជាស្រុកគោលដៅមួយក្នុងចំណោមស្រុកគោលដៅទាំង៤ ដែលមានឃុំចំនួន៤ក្នុងចំណោមឃុំទាំង៧ គឺ ឃុំអន្លង់វិល ឃុំកំពង់ព្រះ ឃុំកំពង់ព្រៀង និងឃុំតាប៉ុន ពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។

ស្រុកសង្កែមានប្រជាជនសរុបចំនួន១២៩.៨៧០នាក់ (ស្ត្រី៦៦.១០១នាក់) ស្មើនឹង២៧.០៧២គ្រួសារ ដែលក្នុងនោះមាន៨១,៤៧% នៃចំនួនប្រជាជនសរុប ជាកសិករប្រកបរបរកសិកម្មជាចម្បង ជាពិសេស ស្រូវវស្សា ស្រូវ ប្រាំង ដំឡូងមី ពោត ម្ទេស សណ្តែកដី សណ្តែកសៀង ល្ង ដំឡូងមី ដំឡូងជ្វា អំពៅ ស្រកានាគ ស្វាយ ក្រូច ឆ្មា ចិញ្ចឹមត្រី ក្រពើ ពពែជ្រូក គោ ក្របី មាន់ និងទា។

នៅក្នុងវិស័យកសិកម្ម មានប្រមាណ៧៩,៤០% នៃប្រជាកសិករសរុបធ្វើស្រូវប្រាំង និងស្រូវវស្សា ដែលបានដាំដុះនៅលើផ្ទៃដីសរុប៣៧.២៥៧ហិកតា ក្នុងនោះមានដីស្រែប្រាំងទំហំ១.៧២៣ហ.ត ភាគច្រើនស្ថិតនៅក្នុងតំបន់២ និងមួយចំនួនក្នុងតំបន់៣ នៃតំបន់ព្រៃលិចទឹកបឹងទន្លេសាប (ទិន្នន័យសេដ្ឋកិច្ច-សង្គម ស្រុកសង្កែ ខែកុម្ភៈ ឆ្នាំ២០២០)។

### ៣.៤ ទិដ្ឋភាពភូមិសាស្ត្រ និងប្រជាសាស្ត្រនៃស្រុកថ្មគោល

ថ្មគោលជាស្រុកគោលដៅមួយក្នុងចំណោមស្រុកគោលដៅទាំង៥ សម្រាប់ការអនុវត្តផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ដែលមានឃុំចំនួន៤ ក្នុងចំណោមឃុំទាំង១០ គឺឃុំបឹងព្រីង ឃុំតាពូង ឃុំតាម៉ឺន និងឃុំជ្រោយស្ដៅ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ ស្រុកថ្មគោលមានផ្ទៃដីសរុប៦៤៧.២៩.៦៩ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងស្រុកបាណន់ និងក្រុងបាត់ដំបង ខេត្តបាត់ដំបង ខាងកើតជាប់នឹងស្រុកឯកភ្នំ និងក្រុងបាត់ដំបង ខេត្តបាត់ដំបង ហើយខាងលិចជាប់នឹងស្រុកបវេល ខេត្តបាត់ដំបង។

ស្រុកថ្មគោលមានប្រជាជនសរុបចំនួន១៣៣.៨៥៩នាក់ (ស្ត្រី៦៨.០១២នាក់) ស្មើនឹង២៨.៦៩០គ្រួសារ ក្នុងនោះ ៧៦%នៃប្រជាជនសរុបមានមុខរបរកសិកម្មជាចម្បង ជាពិសេសដំណាំស្រូវវស្សា ស្រូវប្រាំង ដំឡូងមី ពោត អំពៅ ស្វាយ ក្រូច ផ្លែស្រកានាគ វារីវប្បកម្មចិញ្ចឹមត្រី ក្រពើ និងការចិញ្ចឹមសត្វគោ-ក្របី។ ដោយឡែកនៅក្នុងវិស័យកសិកម្ម មានប្រមាណជា២១%នៃប្រជាកសិករសរុប ពាក់ព័ន្ធនឹងផលិតកម្មស្រូវលើផ្ទៃដីដាំដុះសរុបចំនួន៧៦.២២១ហិកតា ក្នុងនោះមាន១៦.០៦៧ហិកតា ស្ថិតនៅក្នុងតំបន់២ និងតំបន់៣ ក្នុងតំបន់ទំនាបបឹងទន្លេសាប (ទិន្នន័យសេដ្ឋកិច្ច-សង្គម ស្រុកថ្មគោល ខែកុម្ភៈ ឆ្នាំ២០២០)។

## ៤. បញ្ហាប្រឈមនៃការគ្រប់គ្រងព្រៃលិចទឹកក្នុងខេត្តបាត់ដំបង

ជាងមួយទសវត្សមកហើយ ភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់ទំនាបបឹងទន្លេសាបនៃខេត្តបាត់ដំបង បានកើតឡើងជារៀងរាល់ឆ្នាំ ក្នុងទ្រង់ទ្រាយតូច មធ្យម និងធំ ហើយស្ទើរតែគ្រប់ករណីទាំងអស់មិនអាចគ្រប់គ្រងបានដោយសារកង្វះខាតថវិកា និងសម្ភារៈ។ តាមសេចក្ដីរាយការណ៍ពីសហគមន៍ដែលរស់នៅក្នុងតំបន់នោះបានឱ្យដឹងថា គ្រប់ករណីនៃភ្លើងឆេះព្រៃលិចទឹកគឺបណ្ដាលមកពីសកម្មភាពដោយចេតនា និងអចេតនារបស់មនុស្ស។ ជាទម្លាប់ដ៏យូរលង់ណាស់មកហើយ ភ្លើងត្រូវបានគេប្រើជាមធ្យោបាយសម្រាប់ដុតសំអាតព្រៃលិចទឹកដែលទើបនឹងកាប់ឆ្ការដើម្បីយកដីដាំដំណាំ សំអាតសំណល់ដំណាំនៅលើដីស្រែ-ចំការក្រោយពេលប្រមូលផល រកសត្វគោ-ក្របី ចាប់សត្វព្រៃ និងប្រមូលទឹកឃ្មុំ។

ខណ្ឌរដ្ឋបាលជលផលបាត់ដំបងបានរាយការណ៍ថា នៅឆ្នាំ២០១៦ ផ្ទៃដីព្រៃលិចទឹកសរុបទំហំ១០.៩៩២ ហិកតា ត្រូវបានឈូសឆាយ ដុត និងបម្លែងទៅជាដីកសិកម្ម។ ផ្អែកលើទិន្នន័យដែលប្រមូលបាននៅថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០២០ ដោយក្រុមការងារគាំទ្រការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបងបានឱ្យដឹងថា ផ្ទៃដីព្រៃលិចទឹកទំហំ១៤.៥៦២ហិកតា ក្នុងតំបន់២ និងតំបន់៣ ត្រូវបានដុតបំផ្លាញដើម្បីទន្ទ្រានយកដីធ្វើកសិកម្ម នៅចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០២០ ក្នុងស្រុកគោលដៅទាំង៤។

ភ្លើងឆេះព្រៃលិចទឹកដែលបានកើតជាយូរមកហើយនេះ មានផលប៉ះពាល់អវិជ្ជមានដល់ធនធានជលផល រួមមានព្រៃលិចទឹក ស្មៅ និងព្រៃលិចទឹកនៅតាមមាត់អូរ/បឹង ដែលជាជម្រកដ៏សមស្រប និងមានសុវត្ថិភាព សម្រាប់មច្ឆជាតិ ពពួកសត្វល្មូន និងសត្វស្លាបដើម្បីបង្កាត់ពូជ ពងកូន និងចិញ្ចឹមជីវិតទៅតាមរដូវវស្សា។ ផលប៉ះពាល់អវិជ្ជមានចុងក្រោយបំផុតគឺប្រភេទត្រីមួយចំនួនស្ទើរបាត់ពូជ ការថយចុះទាំងទំហំត្រី និងបរិមាណផលត្រីចាប់ និងការធ្លាក់ចុះនូវប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជានេសាទ ដែលជាកត្តាបង្ខំឱ្យពួកគាត់បង្វែរមុខរបរនេសាទទៅធ្វើកសិកម្មវិញ ហើយឈានទៅដល់ការឈូសឆាយព្រៃលិចទឹកយកដីធ្វើស្រែប្រាំង និងដាំដំណាំផ្សេងៗ ទៅតាមតម្រូវការលើទីផ្សារដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ។

តាមរយៈការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ ស្រុក និងខេត្ត បញ្ហាសំខាន់ៗដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកត្រូវបានកំណត់ ដូចមានរៀបរាប់ជូនខាងក្រោមនេះ។

## ៨.១ មូលហេតុនៃភ្លើងឆេះព្រៃលិចទឹក

ផ្អែកលើរបាយការណ៍នៃកិច្ចប្រជុំលើកទីមួយនៅក្នុងឃុំគោលដៅទាំង១៩ ដែលបានចងក្រងដោយក្រុមការងារ ដែលមានសមាសភាពមកពីនាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផលនៃរដ្ឋបាលជលផល ទទួលបន្ទុកគាំទ្រការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបង បានបញ្ជាក់អំពីមូលហេតុសំខាន់ៗនៃភ្លើងឆេះព្រៃលិចទឹកនៅរដូវប្រាំង នៅក្នុងខេត្តបាត់ដំបង មានដូចខាងក្រោមនេះ៖

- ការកាប់ឆ្ការ និងដុតសំណល់នៅក្នុងដីស្រែ-ចំការដែលមានទីតាំងស្ថិតនៅជាប់នឹងវាលស្មៅ ឬព្រៃលិចទឹក ធ្វើឱ្យរាលដាលឆេះវាលស្មៅ និងព្រៃលិចទឹកដោយអចេតនា។ សកម្មភាពនេះត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់បំផុតនៃមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក
- ការដុតស្មៅស្ងួត និងរុក្ខជាតិព្រៃលិចទឹក (ព្រៃលិចទឹក ព្រៃគុម្ពោត) ដែលបានកាប់ឆ្ការដោយចេតនាក្នុងគោលបំណងប៉ុនប៉ងពង្រីកផ្ទៃដីស្រែ-ចំការខុសច្បាប់។ មូលហេតុនេះត្រូវបានចាត់ទុកថាជាហានិភ័យខ្ពស់បំផុតផងដែរ ព្រោះវាបានកើតឡើងជាទូទៅនៅក្នុងតំបន់បឹងទន្លេសាបទាំងមូល
- ការចំអិនអាហារដោយមិនបានពន្លត់ភ្លើងមុនពេលចាកចេញដោយអ្នកនេសាទ អ្នកប្រមាញ់សត្វ និងក្រុមអ្នកឃ្វាលគោ-ក្របី ក៏ត្រូវបានចាត់ទុកថាជាមូលហេតុចំបងដែលបណ្តាលឱ្យមានភ្លើងឆេះព្រៃលិចទឹកផងដែរ
- ការដុតចំបើងនៅក្នុងវាលស្រែដើម្បីបង្កើនជី (ផេះ) ក្នុងដី និងសំអាតដីមុនពេលភ្ជួររាស់ បានរាលដាលចូលវាលស្មៅ និងព្រៃលិចទឹកដែលស្ថិតនៅក្បែរ ក៏ត្រូវបានគេឃើញកើតមានឡើងជាច្រើនករណី
- ការបោះចោលកន្ទុយបារីដោយមិនបានពន្លត់ទៅក្នុងស្មៅ ព្រៃគុម្ពោត និងគំនរសរីរាង្គស្ងួត ដែលជាសកម្មភាពធ្វេសប្រហែសរបស់អ្នកជក់បារី បានបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកជាញឹកញាប់ ជាពិសេសនៅតាមដងផ្លូវធ្វើដំណើរក្នុងតំបន់ទំនាបព្រៃលិចទឹក
- ការប្រើភ្លើង និងផ្សែងដើម្បីប្រមូលទឹកឃ្មុំនៅរដូវប្រាំង ប៉ុន្តែដោយសារការធ្វេសប្រហែស ភ្លើងបានរាលដាលក្នុងទ្រង់ទ្រាយធំមិនអាចគ្រប់គ្រងបាន ហើយឆេះបំផ្លាញព្រៃលិចទឹក និងវាលស្មៅ
- ការប្រែប្រួលអាកាសធាតុ ជាពិសេសការអូសបន្លាយនៃភាពរាំងស្ងួតនៅរដូវប្រាំងដែលជាកត្តាមួយធ្វើឱ្យសំណល់សរីរាង្គនៅបន្តភាពស្ងួត ងាយឆេះនៅពេលប៉ះនឹងភ្លើង ហេតុដូច្នេះហើយបានជាគេឃើញនៅមានមានភ្លើងឆេះព្រៃលិចទឹកក្នុងកំឡុងខែមិថុនា
- មិនមានព័ត៌មាន ឬសេចក្តីរាយការណ៍ណាមួយអំពីបាតុភូតធម្មជាតិដូចជា ព្យុះ ផ្គរ និងរន្ទះ ដែលបានបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកទេ។

មូលហេតុដែលបង្កឱ្យមានឆេះព្រៃលិចទឹកដូចបានរៀបរាប់ខាងលើ គឺជាសកម្មភាពរបស់មនុស្សដែលបានប្រព្រឹត្តទៅដោយចេតនា និងអចេតនា ការធ្វេសប្រហែស និងការមិនយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ភ្លើងនៅក្នុងតំបន់ទំនាបព្រៃលិចទឹក។ ព័ត៌មានលម្អិតអំពីឫសគល់នៃមូលហេតុទាំងអស់នេះត្រូវបានគេស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅសម្រាប់ប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការវិភាគ ការបកស្រាយ និងការកំណត់សកម្មភាពសមស្របដើម្បីដោះស្រាយបញ្ហាភ្លើងឆេះព្រៃលិចទឹកនៅក្នុងទីតាំងជាក់លាក់ក្នុងឃុំគោលដៅឱ្យមានប្រសិទ្ធភាព។

រាល់មូលហេតុ និងបញ្ហានៃភ្លើងឆេះព្រៃលិចទឹកដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់ខេត្តបាត់ដំបង ដើម្បីធានាថាបញ្ហាទាំងអស់នឹងត្រូវបានដោះស្រាយដោយជោគជ័យនៅក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តផែនការនេះ។

## ៤.២ ទីតាំងភ្លើងឆេះព្រៃលិចទឹក

ផ្អែកលើផែនទីភ្លើងឆេះព្រៃលិចទឹក (ឧបសម្ព័ន្ធ៣៖ ផែនទីតំបន់ភ្លើងឆេះព្រៃលិចទឹកនៅក្នុងស្រុកគោលដៅ) ដែលបានផលិតក្រោយពីការប្រមូលព័ត៌មាន និងនិយាមកានៃទីតាំងភ្លើងឆេះព្រៃលិចទឹក ដោយសមាជិកក្រុមការងារចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ បានបង្ហាញឱ្យដឹងថា មានទីតាំងភ្លើងឆេះព្រៃលិចទឹកចំនួន៤៦កន្លែង ដែលមានផ្ទៃដីសរុបចំនួន៧.៧៥៥ហិកតា ស្ថិតនៅក្នុងឃុំចំនួន១៩នៃស្រុកគោលដៅទាំង៤ ដូចមានបញ្ជាក់ជូននៅក្នុងតារាងទី១ ខាងក្រោមនេះ។

**តារាងទី១៖ បញ្ជីឈ្មោះទីតាំង និងផ្ទៃដីព្រៃលិចទឹកដែលបានឆេះនៅក្នុងខេត្តបាត់ដំបង**

| ស្រុក | ឃុំ | ចំនួនទីតាំងភ្លើងឆេះព្រៃលិចទឹក | ផ្ទៃដីតំបន់ភ្លើងឆេះព្រៃលិចទឹក | ពេលវេលាភ្លើងឆេះព្រៃលិចទឹក |
|---|---|---|---|---|
| ស្រុកឯកភ្នំ | ១. ឃុំព្រៃនរិន្ទ<br>២. ឃុំព្រែកហ្លួង<br>៣. ឃុំពាមឯក<br>៤. ឃុំព្រៃចាស់<br>៥. ឃុំកោះជីវាំង | ១១ | ៥.២១៤ ហ.ត | ខែមិនា - ខែឧសភា<br>២០១៦ - ២០២០ |
| ស្រុកសង្កែ | ៦. ឃុំកំពង់ព្រះ<br>៧. ឃុំកំពង់ព្រៀង<br>៨. ឃុំតាប៉ុន<br>៩. ឃុំរកា<br>១០. ឃុំអន្លង់វិល | ២១ | ១.២៧៤ ហ.ត | ខែមិនា - ខែឧសភា<br>២០១៦ - ២០២០ |
| ស្រុកមោងឫស្សី | ១១. ឃុំជ្រៃ<br>១២. ឃុំកកោះ<br>១៣. ឃុំឫស្សីក្រាំង<br>១៤. ឃុំព្រៃតូច<br>១៥. ឃុំតាលាស់ | ៩ | ៩៧៧ហ.ត | ខែមិនា - ខែឧសភា<br>២០១៦ - ២០២០ |
| ស្រុកថ្មគោល | ១៦. ឃុំបឹងព្រីង<br>១៧. ឃុំជ្រោយស្ដៅ<br>១៨. ឃុំតាពូង<br>១៩. ឃុំតាម៉ឺន | ៥ | ២៩០ហ.ត | ខែមេសា - ខែឧសភា<br>២០១៦ - ២០២០ |
| ៤ស្រុក | ១៩ឃុំ | ៤៦ទីតាំង | ៧.៧៥៥ហ.ត | |

## ៤.៣ ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

ព្រៃលិចទឹក វាលស្មៅ វាលទំនាប ប្រព័ន្ធផ្លូវទឹកធម្មជាតិ និងវារីរុក្ខជាតិ មានសារៈសំខាន់សម្រាប់ជីវិតសត្វនិងរុក្ខជាតិដែលអាចរស់នៅលើដី និងក្នុងទឹក និងជីវៈចម្រុះនៃតំបន់ទំនាបបឹងទន្លេសាប ដែលមានសារៈប្រយោជន៍សម្រាប់ការរស់នៅ និងការចិញ្ចឹមជីវិតរបស់មនុស្ស ដូចជាការផ្ដល់ប្រភពអាហារដែលមានប្រូតេអ៊ីនខ្ពស់ និងប្រភពចំណូលប្រចាំគ្រួសារ និងរបស់ប្រទេសជាតិ។

ដោយសារតែធនធានជលផលក្នុងតំបន់ទំនាបបឹងទន្លេសាបផ្ដល់ផលប្រយោជន៍ដល់សង្គមជាតិច្រើនបែបនេះហើយបានជាមានប្រជាពលរដ្ឋជាច្រើនកំពុងពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផលដោយផ្ទាល់ និងដោយ

ប្រយោលត្រូវបានកំណត់ ព្រមទាំងត្រូវបានធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់នោះចូលរួមក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ដើម្បីធានាថាឱ្យបានធនធានជលផលនឹងត្រូវបានប្រើប្រាស់ដោយចីរភាព បើមិនដូច្នេះទេ ធនធានជលផល និងទ្រព្យសម្បត្តិប្រជាពលរដ្ឋមួយចំនួននឹងត្រូវបំផ្លាញដោយភ្លើងឆេះព្រៃលិចទឹក។ ស្ថាប័នសំខាន់ៗមួយចំនួនដែលរកឃើញថាពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកមានរៀបរាប់នៅក្នុងតារាងខាងក្រោម។

**តារាងទី២៖ ស្ថាប័នពាក់ព័ន្ធនឹងការទប់ស្កាត់ និងជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបង**

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | កាត់បន្ថយហានិយភាព | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| ប្រជាពលរដ្ឋក្នុងមូលដ្ឋាន | តាមដានព័ត៌មានស្តីពីការព្យាករណ៍អាកាសធាតុដែលទាក់ទងនឹងការអូសបន្លាយរដូវប្រាំង និងការពន្យារពេលរដូវវស្សា។ | កាត់បន្ថយការចេញ-ចូលទៅក្នុងតំបន់ព្រៃលិចទឹក។ | ផ្សព្វផ្សាយព័ត៌មានស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ។ | ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>គាំទ្រមធ្យោបាយ និងសម្ភារៈពន្លត់ភ្លើងឆេះព្រៃលិចទឹក (គោយន្ត ត្រាក់ទ័រម៉ាស៊ីនបូមទឹក ធុងទឹក ទុយោ ....) ដែលអាចធ្វើទៅបាន។ | -សហការរួមគ្នាដាំកូនឈើព្រៃលិចទឹកនៅក្នុងទីតាំងព្រៃដែលខូចខាតដោយភ្លើងឆេះ និងការកាប់រានធ្វើកសិកម្ម<br>-ការពារ និងថែរក្សាដំណុះរុក្ខជាតិ និងកូនឈើដែលបានដាំឡើងវិញ<br>-ថែទាំបង្គោល និងស្លាកសញ្ញាដែលដាក់នៅតាមព្រំតំបន់ស្តារព្រៃលិចទឹក។ |
| ប្រជាការពារភូមិ | សិក្សា និងអង្កេតអត្តសញ្ញាណកម្មមនុស្សចេញចូលក្នុងតំបន់ព្រៃលិចទឹក។ | -ចូលរួមក្នុងការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ និងជួយផ្សព្វផ្សាយបន្ត<br>-ចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ជលផល។ | -ផ្តល់សម្ភារៈល្បាតនិងពន្លត់ភ្លើងឆេះព្រៃដល់ក្រុមល្បាត<br>-អនុវត្តការល្បាត និងត្រួតពិនិត្យភ្លើងឆេះព្រៃដោយមានការចូលរួម។ | -កៀងគរប្រជាជនចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>-ចូលរួមក្នុងការពន្លត់ ភ្លើងឆេះព្រៃលិចទឹក<br>-គាំទ្រមធ្យោបាយ និងសម្ភារៈពន្លត់ភ្លើងឆេះព្រៃលិចទឹក (គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ធុងទឹក ទុយោ ......) ដែលអាចធ្វើទៅបាន។ | -ចូលរួមក្នុងការដាំ ការពារ និងថែទាំកូនឈើព្រៃលិចទឹកក្នុងតំបន់ស្តារព្រៃលិចទឹក<br>-ចូលរួមបោះ និងថែរក្សាបង្គោលព្រំ និងស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ស្តារព្រៃលិចទឹក។ |
| សហគមន៍នេសាទ | កត់ត្រាឈ្មោះមនុស្ស និងគោលបំណងនៃការចេញ-ចូលក្នុងតំបន់ទំនាបព្រៃលិចទឹកនៅក្នុងរដូវប្រាំងនៅក្នុងដែនគ្រប់គ្រងរបស់សហគមន៍។ | ចូលរួមក្នុងការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក | -ចូលរួមក្នុងការស្តារបឹង/អូរ រក្សាទឹកសម្រាប់ពន្លត់ភ្លើងឆេះព្រៃ<br>-បោះបង្គោលព្រំទីតាំងដែលប៉ះពាល់ដោយភ្លើងឆេះដើម្បីស្តារឡើងវិញ។ | -ចូលរួមក្នុងការពន្លត់ ភ្លើងឆេះព្រៃលិចទឹក<br>-កៀរគរឱ្យប្រជាជនចូលរួម និងគាំទ្រមធ្យោបាយ និងសម្ភារៈ ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | -ចូលរួមក្នុងការដាំ ការពារ និងថែទាំកូនឈើព្រៃលិចទឹកក្នុងតំបន់ស្តារព្រៃលិចទឹក<br>-ចូលរួមបោះ និងថែរក្សាបង្គោលព្រំ និងស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ស្តារព្រៃលិចទឹក។ |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | កាត់បន្ថយហានិយភាព | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| ក្រុមប្រឹក្សាឃុំ | សិក្សា និងអង្កេតអត្តសញ្ញាណកម្មមនុស្សដែលចេញចូលតំបន់ព្រៃលិចទឹក។ | -ផ្សព្វផ្សាយពីវិធានការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក និងផ្តល់សម្ភារៈជូនក្រុមល្បាត<br>-បញ្ជូនកម្លាំងគាំទ្រក្រុមល្បាតភ្លើងឆេះព្រៃតាមការស្នើរបស់ក្រុមល្បាត<br>-ពង្រឹងការអនុវត្តច្បាប់ជលផលដោយផ្អែកទៅលើអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការតួនាទីអំណាច និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ | - បម្រុងថវិកាមូលនិធិឃុំ/សង្កាត់មួយចំនួនសម្រាប់ចំណាយលើការពន្លត់ភ្លើងឆេះព្រៃលិចទឹក (ប្រត្តិបត្តិការ សម្ភារៈ ស្តារបឹង/អូរ)<br>- ជួសជុល និងត្រៀមឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់តម្រូវការបន្ទាន់។ | -កៀរគរប្រជាជនចូលរួម និងគាំទ្រមធ្យោបាយ និងសម្ភារៈដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>- ចូលរួមចាត់ចែងពន្លត់ភ្លើងឆេះព្រៃ<br>-ប្រមូលផ្តុំ និងបញ្ជូនឧបករណ៍ពន្លត់ភ្លើងឆេះព្រៃទៅកន្លែងកើតហេតុនៅពេលមានសំណើពីក្រុមល្បាត។ | -ចូលរួមសហការដាំកូនឈើព្រៃលិចទឹកនៅក្នុងតំបន់ ភ្លើងឆេះព្រៃ។<br>-គាំទ្រថវិកាក្នុងការផលិត និងដាក់ស្លាកសញ្ញាការពារព្រៃលិចទឹក<br>-ផ្សព្វផ្សាយអំពីការការពារ និងថែទាំតំបន់ស្តារព្រៃលិចទឹកដល់ប្រជាពល រដ្ឋ។ |
| សង្គមស៊ីវិល | សិក្សាអំពីស្ថានភាពព្រៃលិចទឹក និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ទំនាបព្រៃលីចទឹកដើម្បីរៀបចំផែនការគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃលិចទឹករបស់រដ្ឋបាលជលផលនិងក្រសួងបរិស្ថាន។ | ផលិតសម្ភារៈ និងជួយផ្សព្វផ្សាយអំពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។ | ផ្តល់ថវិកា និងធនធានមនុស្សដើម្បីគាំទ្រវគ្គ បណ្តុះបណ្តាល ស្តីពីវិធានការគ្រប់គ្រងភ្លើងឆេះព្រៃដល់ក្រុមល្បាត។ | គាំទ្រថវិកា និងភស្តុភារតាមដែលអាចធ្វើបាន។ | គាំទ្រថវិកា និងចូលរួមក្នុងការពារ ថែទាំ និងដាំកូនឈើព្រៃលិចទឹកក្នុងតំបន់ ស្តារព្រៃលិចទឹក។ |
| នគរបាលប៉ុស្តិ៍ និងអធិការនគរបាលស្រុក | រៀបចំបញ្ជីឈ្មោះម្ចាស់ត្រាក់ទ័រ សត្វពាហនៈ ស្រែ-ចំការ និងអ្នកស្នាក់អាស្រ័យបណ្តោះអាសន្ន នៅក្នុងតំបន់៣ ដើម្បីងាយស្រួលក្នុងការស្វែងរកអត្តសញ្ញាណកម្មជនសង្ស័យដែលបង្កភ្លើងឆេះព្រៃ។ | សហការជាមួយខណ្ឌរដ្ឋបាលជលផល ហាមឃាត់ និងត្រួតពិនិត្យយ៉ាងតឹងរឹងនូវការប្រើប្រាស់ដី និងព្រៃលិចទឹកនៅក្នុងតំបន់៣។ | រៀបចំ និងត្រៀមកម្លាំង និងរថយន្តពន្លត់អគ្គីភ័យដើម្បីគាំទ្រការពន្លត់ភ្លើងឆេះព្រៃជាបន្ទាន់។ | គាំទ្រ និងចូលរួមក្នុងការល្បាតភ្លើងឆេះព្រៃ<br>ផ្តល់មធ្យោបាយ និងសម្ភារៈសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | គាំទ្រ និងចូលរួមក្នុងការដាំកូនព្រៃលិចទឹក |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | កាត់បន្ថយហានិយភាព | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| រដ្ឋបាលស្រុក | -ប្រមូល និងរក្សាទុកឯកសារនិងទិន្នន័យដែលទាក់ទងនឹងការគ្រប់គ្រងព្រៃលិចទឹក<br>-ចេញសេចក្តីប្រកាស<br>-ឬការណែនាំអំពីការគ្រប់គ្រងព្រៃលិចទឹក រួមទាំងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក | ផ្សព្វផ្សាយពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់បណ្តាលពីភ្លើងឆេះព្រៃ និងបទដ្ឋានច្បាប់ពាក់ព័ន្ធ រួមទាំងច្បាប់ស្តីពីជលផល។ | សហការជាមួយខណ្ឌ រដ្ឋបាលជលផលផ្តល់គ្រូបង្គោលនៃក្រុមពន្លត់អគ្គីភ័យសម្រាប់វគ្គបណ្តុះ បណ្តាលស្តីពីវិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃ។ | បញ្ជូនសម្ភារៈពន្លត់ អគ្គីភ័យ និងមន្ត្រីឱ្យចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃ | ចូលរួមក្នុងការដាំកូនឈើ និងជំរុញឱ្យអាជ្ញាធរភូមិ ឃុំ ជួយការពារ និងថែរក្សាតំបន់ស្តារព្រៃលិចទឹក |
| មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ត្រួតពិនិត្យរបាយ-ការណ៍ភ្លើងឆេះព្រៃលិចទឹកដែលរៀបចំដោយខណ្ឌរដ្ឋបាលជលផលដើម្បីផ្តល់អនុសាសន៍ និងចាត់វិធានការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកឱ្យមានប្រសិទ្ធិភាព | គាំទ្រការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។<br>គាំទ្រ និងពង្រឹងការអនុវត្តច្បាប់។ | រាយការណ៍ជូនអភិបាលនៃគណៈអភិបាលខេត្តអំពីបញ្ហាភ្លើងឆេះព្រៃលិចទឹកដើម្បីឱ្យស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្តត្រៀមជួយអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ។ | ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងស្នើសុំកម្លាំងអន្តរាគមន៍ពីអភិបាលនៃគណៈអភិ-បាលខេត្ត និងស្រុក។ | ចូលរួម និងគាំទ្រការដាំកូនឈើ និងជំរុញឱ្យអាជ្ញាធរភូមិ ឃុំ ស្រុកជួយការពារ និងថែរក្សាទីតាំង ស្តារព្រៃលិចទឹកឡើងវិញ |
| អង្គភាពពាក់ព័ន្ធនៅថ្នាក់ខេត្ត | កំណត់អង្គភាពពាក់ព័ន្ធនិងរៀបចំគោលនយោបាយគាំទ្រការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ | -ផ្សព្វផ្សាយអំពីការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកដល់អង្គភាពពាក់ព័ន្ធ<br>-ចាត់វិធានការដល់រូបវន្តបុគ្គល និង និតិបុគ្គល ដែលបានបំផ្លាញព្រៃលិចទឹកតាមនិតិវិធីច្បាប់។ | -ត្រៀមកម្លាំង មធ្យោបាយ និងសម្ភារៈពន្លត់ភ្លើងឆេះព្រៃលិចទឹកដើម្បីធ្វើអន្តរាគមន៍ជាបន្ទាន់<br>-ផ្តល់សម្ភារៈពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត និងសហគមន៍នេសាទ។ | បញ្ជូនមធ្យោបាយពន្លត់អគ្គីភ័យ និងកម្លាំងចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | -ចូលរួមក្នុងពិធីដាំកូនឈើព្រៃលិចទឹក<br>-គាំទ្រថវិកាក្នុងការស្តារព្រៃលិចទឹក។ |
| អាជ្ញាធរទន្លេសាប | សិក្សាអំពីស្ថានភាពព្រៃលិចទឹក និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ទំនាបព្រៃលីចទឹកដើម្បីរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងព្រៃលិចទឹក។<br>ត្រួតពិនិត្យបង្គោលព្រំប្រទល់តំបន់៣ និងបោះបង្គោលបន្ថែមនៅទីតាំងដែលគម្លាតពីបង្គោល១ទៅបង្គោល | ផលិតសម្ភារៈ និងរៀបចំការផ្សព្វផ្សាយពីសារៈសំខាន់ព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកដល់មនុស្សសត្វ ជីវៈចម្រុះ និងអេកូឡូស៊ីនៃទំនាបបឹងទន្លេសាប។ | ផ្តល់សម្ភារៈពន្លត់ភ្លើងឆេះព្រៃដល់ក្រុមល្បាតភ្លើងឆេះព្រៃ និងសហ-គមន៍នេសាទ។ | ចូលរួមអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | ចូលរួម និងគាំទ្រការដាំកូនឈើ និងជំរុញឱ្យស្ថាប័នពាក់ព័ន្ធជួយការពារ និងថែរក្សាទីតាំងស្តារព្រៃលិចទឹក។ |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | កាត់បន្ថយហានិយភាព | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| | ១ទៀតស្ថិតនៅឆ្ងាយពីគ្នាពេក។ | | | | |
| រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | -ប្រមូល និងរក្សាទុកឯកសារដែលទាក់ទងនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម និងកំណត់អំពីមូលហេតុ ទំហំនៃការខូចខាត វិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃ និងផែនទីភ្លើងឆេះព្រៃ<br>-ចុះត្រួតពិនិត្យព្រៃលិចទឹកជាទៀងទាត់ដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពព្រៃលិចទឹក<br>-សិក្សាស្រាវជ្រាវចងក្រងឯកសារ អំពីធនធានជលផល អេកូឡូស៊ី និងការចិញ្ចឹមជីវិតនៅក្នុងតំបន់ព្រៃលិចទឹក ជាពិសេសនៅក្នុងតំបន់៣។ | ផលិតសម្ភារៈ និងរៀបចំការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។<br>ពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល។ | - សម្របសម្រួល និងគាំទ្រសកម្មភាពល្បាត ភ្លើងឆេះព្រៃលិចទឹក<br>-សម្របសម្រួលនិងស្វែងរកថវិកាសម្រាប់គាំទ្រសកម្មភាពគ្រប់ គ្រងនិងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក<br>-ផ្តល់សម្ភារៈ មធ្យោបាយ និងត្រួតពិនិត្យការប្រើប្រាស់ និងថែរក្សាសម្ភារៈពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់តម្រូវការ បន្ទាន់។ | -ដឹកនាំ និងសម្របសម្រួលពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>-រាយការណ៍ទៅអង្គភាពពាក់ព័ន្ធដើម្បីស្នើសុំកិច្ចអន្តរាគមន៍បន្ទាន់។<br>-ស៊ើបអង្កេត តាមដានស្រាវជ្រាវ និងកសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់ស្តីពីជលផល។ | -រៀបចំ ដាំកូនឈើព្រៃលិចទឹកឡើងវិញ<br>-ការពារ និងថែរក្សាកូនឈើព្រៃលិចទឹកបានដាំ និងទីកន្លែងព្រៃលិចទឹកដែលបានឆេះ<br>-វាយតម្លៃអត្រារស់ និងលូតលាស់របស់កូនឈើនៅក្នុងទីកន្លែងស្តារព្រៃលិចទឹក។ |
| ក្រសួងបរិស្ថាន | ធ្វើការសិក្សាស្តីពីប្រព័ន្ធអេកូឡូស៊ី និងការចិញ្ចឹមជីវិតនៅក្នុងតំបន់ទំនាបព្រៃលិចទឹក ដើម្បីរៀបចំផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់តំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាបដោយផ្សារភ្ជាប់ទៅនឹងផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹករបស់រដ្ឋ-បាលជលផលនៃ។ | ផលិតសម្ភារៈ និងធ្វើការផ្សព្វផ្សាយស្តីពីសារៈសំខាន់ព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាល មកពីភ្លើងឆេះព្រៃលិចទឹក ច្បាប់ស្តីពីតំបន់ការពារ និងបទដ្ឋានគតិយុទ្ធពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។ | - ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសល្បាតដល់មន្ត្រីឧទ្យានុរក្ស និងសហគមន៍តំបន់ការពារធម្មជាតិ<br>- ផ្គត់ផ្គង់ និងត្រួតពិនិត្យការប្រើប្រាស់ និងការថែទាំឧបករណ៍ពន្លត់ ភ្លើងឆេះព្រៃ សម្រាប់តម្រូវការបន្ទាន់។ | - ចាត់កម្លាំងមន្ត្រីឧទ្យានុរក្សឱ្យចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃដែលកើតមានឡើងទាំងនៅក្នុង និងក្រៅឋបនីយជីវមណ្ឌល<br>- ជូនដំណឹងឱ្យមន្ទីរបរិស្ថានតាមដាន និងចូលរួមនៅក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកទៅតាមសំណើពីរដ្ឋបាល ខេត្ត | ចូលរួមដាំកូនឈើ និងថែទាំទីកន្លែង ស្តារព្រៃលិចទឹកនៅក្នុង និងក្រៅតំបន់រ៉ាមសារ និងឋបនីយ ជីវមណ្ឌលបឹងទន្លេសាប។ |

ការកំណត់អត្តសញ្ញាណរបស់អ្នកពាក់ព័ន្ធគឺជាការចាំបាច់មិនអាចខ្វះបាន សម្រាប់ការរៀបចំផែនការដែលគិតអំពីក្រុមគោលដៅ និងការចូលរួមរបស់ពួកគេនៅក្នុងដំណាក់កាលផ្សេងៗគ្នា (ការទប់ស្កាត់ បង្កា ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹក) នៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលបានលើកឡើងនៅក្នុងផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃ រយៈពេល៥ឆ្នាំ គិតពីឆ្នាំ២០១១ដល់ឆ្នាំ២០១៥។

ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកត្រូវបានគិតបញ្ចូលចាប់ពីក្រុមដែលសង្ស័យថា បានបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ដែលនឹងទទួលបាននូវការអប់រំផ្សព្វផ្សាយ ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក ក្រុមអ្នកប្រើប្រាស់ធនធានជលផល (សហគមន៍ប្រជាកសិករ អ្នកនេសាទ អ្នកចិញ្ចឹមសត្វ ក្រុមហ៊ុនរៀបចំប្រព័ន្ធស្រោចស្រប់ស្រែ។ល។) ស្ថាប័ន/អង្គភាពគ្រប់គ្រង (ពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ យន្តការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត និងក្រុមល្បាតថ្នាក់ឃុំ) សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជំនួយដល់ការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងស្តារព្រៃលិចទឹក។

## ៤.៤ បញ្ហាប្រឈមក្នុងការចាត់វិធានការពន្លត់ភ្លើងឆេះព្រៃ

យោងតាមប្រវត្តិនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងខេត្តបាត់ដំបងបានបង្ហាញឱ្យដឹងថា មិនទាន់មានភ្លើងឆេះព្រៃលិចទឹកណាមួយត្រូវបានពន្លត់ដោយសារបទអន្តរាគមន៍ឱ្យទាន់ពេលវេលាពីស្ថាប័នពាក់ព័ន្ធ ហើយថែមទាំងមិនទាន់មានរចនាសម្ព័ន្ធគ្រប់គ្រងភ្លើងឆេះព្រៃនៅថ្នាក់ខេត្ត ស្រុក ឬឃុំ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាភ្លើងឆេះព្រៃនៅឡើយ។ បញ្ហាប្រឈមទាំងនេះគឺបណ្តាលមកពីកត្តា និងបុព្វហេតុមួយចំនួនដូចបង្ហាញជូននៅខាងក្រោមនេះ៖

- **មិនមានយន្តការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក៖** ភ្លើងឆេះព្រៃលិចទឹកបានកើតមានឡើងជារៀងរាល់ឆ្នាំ និងជាច្រើនទស្សវត្សមកហើយ ជាពិសេសនៅក្នុងទស្សវត្សទី២០ និងទី២១ ខណៈពេលដែលតម្លៃដីបានឡើងខ្ពស់។ តាមការរាយការណ៍ដោយសហគមន៍នេសាទ និងសហគមន៍មូលដ្ឋានទៅសង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-ស្រុក និងសមត្ថកិច្ចជំនាញពាក់ព័ន្ធ ដើម្បីស្វែងរកការជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក ប៉ុន្តែមិនមានបទអន្តរាគមន៍ដ៏មានប្រសិទ្ធភាពណាមួយបានផ្តល់ជូនឱ្យទាន់នៅឡើយ។ នេះប្រហែលជាបណ្តាលមកពីការមិនមានយន្តការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកបានបង្កើតនៅថ្នាក់ឃុំ ឬស្រុក ដើម្បីត្រៀមកម្លាំង សម្ភារៈ និងថវិកាសម្រាប់ការទប់ស្កាត់ និងការពន្លត់ភ្លើងឆេះព្រៃលិចទឹកឱ្យបានទាន់ពេលវេលា។
- **<u>មិនមានផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក</u>៖** ដោយសារអវត្តមាននៃយន្តការ ឬក្រុមចម្រុះដែលមានភាគីពាក់ព័ន្ធសំខាន់ៗជាសមាជិកបានបង្កើតឡើង សម្រាប់ការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ដូច្នេះផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកជាប្រព័ន្ធមិនត្រូវបានបង្កើត បណ្តាលឱ្យភ្លើងឆេះព្រៃលិចទឹកនៅតែកើតមានឡើងជារៀងរាល់ឆ្នាំ។ កន្លងមក ទោះបីជាមានការខិតខំប្រឹងប្រែងពីសហគមន៍នេសាទដើម្បីពន្លត់ភ្លើងឆេះព្រៃដែលមានទ្រង់ទ្រាយធំ និងមធ្យមដែលបានកើតមានឡើងនៅក្នុងដែនគ្រប់គ្រងរបស់ខ្លួនក៏ដោយ ក៏កិច្ចប្រឹងប្រែងនេះមិនសូវទទួលបានជោគជ័យទេ ដោយហេតុថាមិនមានកម្លាំងត្រៀម និងឧបករណ៍ពន្លត់ភ្លើងឆេះព្រៃគ្រប់គ្រាន់។
- **<u>ចំណេះដឹងសហគមន៍មូលដ្ឋានពីមាត្រាច្បាប់ទាក់ទងនឹងភ្លើងឆេះព្រៃលិចទឹក និងផលប៉ះពាល់</u>៖** ប្រជាពលរដ្ឋភាគច្រើនយល់ដឹងអំពីមាត្រាច្បាប់ដែលទាក់ទងនឹងការនេសាទខុសច្បាប់ ដោយសារកន្លងមកមានការប្រជុំលើកកម្ពស់ការយល់ដឹងអំពីប្រធានបទនេះជាច្រើនបានរៀបចំនៅមូលដ្ឋាន និងការចែករំលែកព័ត៌មានជាសាធារណៈតាមរយៈផ្ទាំងរូបភាព ស្លាករូបភាព វិទ្យុ ទូរទស្សន៍ ការប្រជុំនានា ការនិយាយតគ្នា ហ្វេសប៊ុក តេឡេក្រាម។ល។ ប៉ុន្តែប្រជាសហគមន៍ហាក់ដូចជាមានការយល់ដឹងតិចតួចអំពីច្បាប់បទដ្ឋានដែលពាក់ព័ន្ធនឹងភ្លើងឆេះព្រៃលិចទឹក ដែលបណ្តាលមកពីយុទ្ធនាការផ្សព្វផ្សាយ និងសម្ភារៈផ្សព្វផ្សាយអំពីការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលបានអនុវត្ត និងចែកចាយនៅមានកម្រិតក្នុងខណៈដែលពួកគាត់កំពុងផ្តោតអារម្មណ៍ទៅលើការប្រើប្រាស់ដីធ្លី និងការនេសាទ។

ទន្ទឹមនឹងនេះ ដោយសារការមិនយល់ដឹងអំពីយន្តការនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះ ហើយ បានជានៅពេលដែលប្រជាកសិករ ឬ ប្រជានេសាទមួយចំនួនបានជួបប្រទះនឹងហេតុការដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងភ្លើងឆេះព្រៃលិចទឹកដែលកំពុងកើតឡើង ហើយមានបំណងចង់រាយការណ៍ និងជួយពន្លត់ភ្លើងឆេះព្រៃ តែមិនដឹងធ្វើត្រូវដូចម្តេចដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹក ឬ រាយការណ៍ទៅអ្នកណាដើម្បីសុំជំនួយពន្លត់ភ្លើងឆេះព្រៃលិចទឹក។

- **<u>ការដែលមិនអាចចូលទៅដល់តំបន់ភ្លើងឆេះព្រៃលិចទឹក</u>**៖ ដោយសារភូមិសាស្ត្រតំបន់ព្រៃលិចទឹកតែងតែលិចទឹកក្នុងរដូវវស្សាជារៀងរាល់ឆ្នាំ ហើយមានព្រៃស្បាតដុះក្រាស់មិនអាចចូលបាន សូម្បីតែដើរថ្មើរជើង ដូច្នេះភាគច្រើននៃតំបន់ព្រៃលិចទឹកមិនសូវមានផ្លូវសម្រាប់បើកបរម៉ូតូ គោយន្ត និងយានយន្តកៃច្នៃទេ។ ម៉្យាងវិញទៀត មានតំបន់មួយចំនួនដែលមានរយៈកម្ពស់ទាប ហើយស្ថិតនៅក្នុងតំបន់វាលភក់ ស្ថានភាពដីនៅជ្រាយ និងជាំទឹក មិនអាចប្រើម៉ូតូ ឬគោយន្តឆ្លងកាត់បាន តែអាចចេញចូលបានដោយសារថ្មើរជើងតាមកន្លែងប៉ុណ្ណោះ។

ភាពខ្វះខាតផ្លូវសម្រាប់យានយន្តធ្វើដំណើរឆ្លងកាត់នៅក្នុងតំបន់ព្រៃលិចទឹក គឺជាឧបសគ្គធំមួយរារាំងកិច្ចខិតខំប្រឹងប្រែងក្នុងការដឹកទឹក និងឧបករណ៍ពន្លត់ភ្លើងឆេះព្រៃចូលទៅទីតាំងកើតហេតុ ដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលកំពុងកើតឡើងនៅឆ្ងាយពីប្រភពទឹក។ ការមិនអាចចូលទៅដល់នេះបានផ្តល់ឱកាសឱ្យភ្លើងឆេះព្រៃលិចទឹកកាន់តែរីករាលដាលធំឡើងៗ មិនអាចគ្រប់គ្រងបាន និងទុកឱ្យភ្លើងឆេះព្រៃលិចទឹករលត់ដោយខ្លួនឯងតាមយថាផល។

- **<u>ខ្វះប្រភពទឹក</u>**៖ ប្រភពទឹកមានច្រើន ឬតិច ប្រែប្រួលអាស្រ័យទៅលើលក្ខណៈភូគព្ភសាស្ត្រ ជលសាស្ត្ររូបសាស្ត្រ ប្រភេទដី ចលនាជោរនិងនាចនៃទឹកសមុទ្រ។ ភាគច្រើននៃប្រភពទឹក ក្រៅពីស្ទឹងសំខាន់ៗទាំង៣ ត្រូវបានរីងស្ងួតនៅរដូវប្រាំង ហើយបរិមាណនៃទឹកច្រើន ឬតិច ក៏អាស្រ័យនឹងការប្រើប្រាស់ទឹកសម្រាប់ដំណាំស្រូវប្រាំង។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញថា បរិមាណទឹកនៅក្នុងប្រព័ន្ធផ្លូវទឹកធម្មជាតិបានថយចុះ ហើយប្រព័ន្ធទឹកទាំងនោះកំពុងតែរីងរាក់ជាបណ្តើរៗដោយសារការកើនឡើងនូវដីល្បាប់ដែរហូរមកពីតំបន់ខាងលើខ្សែទឹក ដែលជាលទ្ធផលនៃការខូចខាត និងបាត់បង់គម្របដី និងព្រៃលិចទឹកនៅទីនោះ។

ក្នុងរយៈពេល០៥ឆ្នាំកន្លងមក អ្នកនេសាទបានឱ្យដឹងថា ស្រះស្ទើរតែទាំងអស់នៅក្នុងតំបន់ទំនាបលិចទឹកនៃតំបន់បឹងទន្លេសាបក្នុងខេត្តបាត់ដំបង បានរីងស្ងួតទាំងស្រុង ដោយហេតុផលមួយចំនួនរួមមាន ការរីងរាក់ដោយការហូរចាក់នៃដីល្បាប់ជាយូរឆ្នាំណាស់មកហើយ ដែលជាលទ្ធផលនៃការប្រែប្រួលអាកាសធាតុ ការកាប់ព្រៃនៅតំបន់ខាងលើខ្សែទឹក ការរៀបចំដីសម្រាប់ការដាំដុះ ការបូមទឹកបញ្ចូលស្រែប្រាំង និងការបូមបាចចាប់ត្រី។ ដោយហេតុថាទឹកគឺជាកត្តាចំបងសម្រាប់ពន្លត់ព្រៃឆេះលិចទឹក កង្វះប្រភពទឹកនៅក្នុង ឬក្បែរព្រៃលិចទឹកដែលងាយរងគ្រោះដោយភ្លើងឆេះព្រៃ ជាក្តីបារម្ភចម្បងបង្កការរាំងស្ទះដល់ការពន្លត់ភ្លើងឆេះព្រៃលិចទឹក។

ការស្តារប្រព័ន្ធផ្លូវទឹកធម្មជាតិ (បឹង ស្រះ និងអូរ) នៅក្នុងតំបន់ដែលមានព្រៃលិចទឹក និងវាលស្មៅត្រូវបានលើកឡើងជាសកម្មភាពអាទិភាព ព្រោះថាទឹកដែលស្ថិតនៅក្នុងបឹង ស្រះ និងអូរដែលបានស្តារនឹងត្រូវប្រើប្រាស់ដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹក និងជាកន្លែងអភិរក្សត្រីមេពូជ និងសត្វស្លាបផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការប្រើប្រាស់ទឹកនៃប្រព័ន្ធផ្លូវធម្មជាតិដែលបានស្តារដើម្បីផលិតកម្មកសិកម្ម ដែលនឹងឈានទៅដល់ការកាប់រានទន្ទ្រាន និងដុតព្រៃលិចទឹកពង្រីកដីស្រែ និងចំការ។

- **កង្វះថវិកា និងឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក៖** ការពន្លត់ភ្លើងឆេះព្រៃលិចទឹកគឺជាការងារដ៏លំបាក ដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ (ឃុំ ស្រុក និងខេត្ត) ចូលរួមអនុវត្តក្រោមយន្តការគ្រប់គ្រងមួយប្រកបដោយប្រសិទ្ធភាពដោយមានថវិកា និងសម្ភារៈគ្រប់គ្រាន់។ ភាគីពាក់ព័ន្ធរួមមានសមត្ថកិច្ចជំនាញ អាជ្ញាធរមូលដ្ឋាន អង្គការជាតិនិងអន្តរជាតិ សហគមន៍នេសាទ និងសហគមន៍មូលដ្ឋាន ប៉ុន្តែអង្គភាពដែលនាំមុខក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកមាន ខណ្ឌរដ្ឋបាលជលផល មន្ទីរបរិស្ថាន អាជ្ញាធរស្រុក និងឃុំ ប៉ុន្តែកន្លងមក អង្គភាពទាំងអស់នេះមិនអាចបំពេញតួនាទីរបស់ខ្លួនឱ្យបានពេញលេញក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ដោយសារមូលហេតុពុំមានថវិកាតិចគ្រប់គ្រាន់សម្រាប់ចំណាយទៅលើការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលមានតម្លៃខ្ពស់។

ដោយសារឧបសគ្គមានមួយចំនួនដូចបានរៀបរាប់ជូនខាងលើ នៅពេលមានភ្លើងឆេះព្រៃលិចទឹក អង្គភាពពាក់ព័ន្ធទាំងអស់ ជាពិសេសសង្កាត់រដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យទីតាំងភ្លើងឆេះព្រៃដោយផ្ទាល់ បានត្រឹមរាយការណ៍ជូនស្ថាប័ន/អង្គភាពពាក់ព័ន្ធដើម្បីជួយធ្វើអន្តរាគមន៍ និងផ្តល់គំនិតអំពីវិធីសាស្រ្តទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃលិចទឹកប៉ុណ្ណោះ ប៉ុន្តែមិនមានជម្រើសឯកភាពណាមួយត្រូវបានជ្រើសរើសយកមកអនុវត្តជាក់ស្តែងសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានទ្រង់ទ្រាយមធ្យម និងធំឱ្យមានប្រសិទ្ធភាពទេ។

### ៤.៥ ការអនុវត្តច្បាប់ជលផលដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក

ករណីភ្លើងឆេះព្រៃលិចទឹកជាច្រើនកន្លែងបានកើតឡើងនៅក្នុងខេត្តបាត់ដំបងជារៀងរាល់ឆ្នាំ ដែលភាគច្រើនទំនងជាបង្កដោយប្រជាជនដែលរស់នៅក្នុងភូមិ-ឃុំសាមី ជាជាងអ្នកដែលមកពីខាងក្រៅ។ ទោះយ៉ាងណាក៏ដោយ មានអ្នកនេសាទ និងកសិករមួយចំនួនមកពីតំបន់ខ្ពង់រាបចូលទៅក្នុងតំបន់២ និងតំបន់៣នៃបឹងទន្លេសាបក្នុងរដូវប្រាំង ដើម្បីនេសាទត្រី រកអុស និងសំអាតសំណល់នៅក្នុងស្រែ-ចំការ ដើម្បីធ្វើការដាំដុះបន្ត។ ដូច្នេះភ្លើងឆេះព្រៃលិចទឹកមួយចំនួនអាចត្រូវបានបង្កដោយក្រុមនេះផងដែរ តាមរយៈសកម្មភាពចំអិនអាហារ ដុតសំណល់នៅក្នុងដីស្រែចំការ និងបោះកន្ទុយបារីដែលមិនបានពន្លត់។

កន្លងមក ខណ្ឌរដ្ឋបាលជលផលបាត់ដំបងបានធ្វើការស៊ើបអង្កេត និងចាប់ជនសង្ស័យមួយចំនួនដែលទាក់ទងនឹងករណីភ្លើងឆេះព្រៃលិចទឹក និងការកាប់ទន្រ្ទានព្រៃលិចទឹក ព្រមទាំងបានចងក្រងសំណុំរឿង បញ្ជូនជនសង្ស័យទៅតុលាការ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់អនុវត្តបន្ត។ សូមបញ្ជាក់ថា មិនមែនគ្រប់ករណីល្មើសទាំងអស់ត្រូវបានស៊ើបអង្កេត និងចងក្រងសំណុំរឿងបទល្មើសជលផលនោះទេ ព្រោះមានតំបន់ទំនាស់មួយចំនួនស្ថិតនៅឆ្ងាយ មិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីឈានដល់ការសន្និដ្ឋានកំណត់មុខសញ្ញាជនសង្ស័យ។ ទៅបីជាមានការជួយធ្វើអន្តរាគមន៍ពីតុលាការក្នុងការដោះស្រាយសំណុំរឿងទាំងនោះក៏ដោយ ក៏និតិវិធីនៃការកាត់ក្តីនៅតែមិនទាន់មានតម្លាភាព និងឯកភាព ព្រោះថាមានជនសង្ស័យជាច្រើននាក់ត្រូវបានដោះលែងដោយមិនមានមូលហេតុច្បាស់លាស់ និងមិនដាក់ទណ្ឌកម្មតាមច្បាប់ស្តីពីជលផល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការដោះស្រាយតាមប្រព័ន្ធតុលាការក៏មានប្រសិទ្ធភាព និងឥទ្ធិពលខ្លាំងក្នុងការកាត់បន្ថយបទល្មើសជលផល រួមទាំងករណីភ្លើងឆេះព្រៃលិចទឹកផងដែរ។

## ៥. ដំណើរការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបាត់ដំបង

ដើម្បីធានាការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួមត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា ស្របតាមគោលការណ៍ 5"R" និង៣ដំណាក់កាលសំខាន់៖ ការទប់ស្កាត់ (ការពិនិត្យឡើងវិញ ការកាត់បន្ថយហានិភ័យ និងការត្រៀមរួចជាស្រេច) ការឆ្លើយតបនឹងការកាត់បន្ថយករណីភ្លើងឆេះព្រៃ

លិចទឹក និងការស្តារព្រៃលិចទឹកឡើងវិញដើម្បីបង្កើនគម្របព្រៃ ផែនការនេះគួរតែត្រូវបានអនុវត្តតាមនីតិវិធីដូចការ

ពិពណ៌នាលម្អិតជូនខាងក្រោម។

## ៥.១ ការទប់ស្កាត់

### ៥.១.១ ការពិនិត្យឡើងវិញ

មានការពិនិត្យឡើងវិញនូវបទពិសោធន៍ ព័ត៌មាន ទិន្នន័យ និងការយល់ដឹងអំពីលទ្ធភាពនៃការបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក រូបភាពនៃភ្លើងឆេះព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកនៅកន្លែងផ្សេងៗគ្នា ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកក្នុងខេត្តបាត់ដំបង។ លទ្ធភាពនៃការបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងរូបភាពនៃភ្លើងឆេះព្រៃលិចទឹក រួមបញ្ចូលទាំង លក្ខខណ្ឌឧតុនិយម (ស្ថានភាពភ្លៀងធ្លាក់ និងគ្រោះរាំងស្ងួត) ស្ថានភាពសំណើម/ស្ងួត សារធាតុដែលងាយឆេះនៅក្នុងតំបន់ ទីតាំងដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ និងមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក បាតុភូតធម្មជាតិ ទិដ្ឋភាពភូមិសាស្ត្រ ជលសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធសង្គម។

ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹក គឺជាទំហំនៃការខូចខាតដែលអាចកើតមានចំពោះតម្លៃសង្គម សេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងអភិរក្ស ជាពិសេសជីវៈចម្រុះរបស់តំបន់ទេសភាពនៃទំនាបបឹងទន្លេសាបទាំងមូល។ និយាយជារួម ភ្លើងឆេះព្រៃលិចទឹកប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជននិងសាធារណៈ ធនធានជលផល (ត្រី វារីរុក្ខជាតិ) សត្វព្រៃ (បក្សី ល្មូន ថនិកសត្វ និងឧរង្គសត្វ) ទីកន្លែងកំសាន្ត តំបន់ទេសចរណ៍ធម្មជាតិ បរិស្ថាន (ដី ទឹក រុក្ខជាតិ និងបរិយាកាស) ការស្តុកកាបូន សុខភាពមនុស្សនិងសត្វ និងជីវភាពរស់នៅរបស់ប្រជានេសាទ។ ការពិនិត្យឡើងវិញនេះ ត្រូវធ្វើឡើងទៅតាមសកម្មភាពមួយចំនួនដូចខាងក្រោម៖

***ក) ការប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យឡើងវិញនូវបញ្ហាភ្លើងឆេះព្រៃលិចទឹក***

ការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដូចជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរ

បរិស្ថាន ខណ្ឌរដ្ឋបាលជលផល ការិយាល័យកសិកម្ម បរិស្ថាន និងធនធានធម្មជាតិ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍នេសាទ និងសហគមន៍មូលដ្ឋាន ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដើម្បីពិភាក្សា ប្រមូលព័ត៌មាន ទិន្នន័យដែលទាក់ទងទៅនឹងមូលហេតុ និងឥរិយាបថនៃភ្លើងឆេះព្រៃលិចទឹក ធាតុរួមផ្សំបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក (ភាពរាំងស្ងួត កំដៅ សំណើម ខ្យល់ សំណល់រុក្ខជាតិ និងសារធាតុសរីរាង្គស្ងួត) អ្នកពាក់ព័ន្ធដែលសង្ស័យថាជាអ្នកបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកចំពោះទ្រព្យសម្បត្តិ សុខភាពនិងជីវិតរបស់មនុស្ស-រុក្ខជាតិ-សត្វ បរិស្ថាន និងតំបន់ទេសភាពទាំងមូល ការទប់ស្កាត់ និងការពន្លត់ភ្លើងព្រៃលិចទឹក វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក ព្រមទាំងអ្នកពាក់ព័ន្ធនឹងដំណើរការនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។

ព័ត៌មានដែលប្រមូលបាន និងលទ្ធផលដែលបានរកឃើញនៅក្នុងដំណាក់កាលនេះនឹងត្រូវប្រើប្រាស់ដើម្បីកំណត់វិធីសាស្ត្រដ៏មានប្រសិទ្ធិភាពសម្រាប់ការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ជាពិសេសនៅក្នុងដំណាក់កាលទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក។

***ខ) ការចុះអង្កេតទីតាំងភ្លើងឆេះព្រៃ***

ការចុះអង្កេតនៅទីតាំងភ្លើងឆេះព្រៃលិចទឹកដោយផ្ទាល់ ត្រូវបានធ្វើឡើងបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់បានបញ្ចប់ ដើម្បីប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពរូបសាស្ត្រ ការប្រើប្រាស់ដី ទីតាំងស្នាក់នៅបណ្តោះអាសន្ន

នៅក្នុង ឬក្បែរតំបន់ភ្លើងឆេះព្រៃលិចទឹក សញ្ញាណនៃមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក រុក្ខជាតិគម្របដីប្រភេទព្រៃលិចទឹក ទំហំនៃការខូចខាត។ និយាមកាព្រំប្រទល់នៃទីតាំងភ្លើងឆេះព្រៃលិចទឹកត្រូវប្រមូលនៅក្នុងការអង្កេតនេះ ដើម្បីយកទៅផលិតផែនទីនៃភ្លើងឆេះព្រៃលិចទឹក។

### ៥.១.២ ការកាត់បន្ថយហានិភ័យ

សកម្មភាពកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃលិចទឹក គឺក្នុងបំណងកាត់បន្ថយទំហំភ្លើងឆេះព្រៃចាប់ពីចំណុច ដំបូង ដែលជាផ្នែកមួយដ៏សំខាន់បំផុតនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ព្រមទាំងជាវិធីដែលចំណាយតិចបំផុត ក្នុងការកាត់បន្ថយការខូចខាតនិងការបាត់បង់ដោយភ្លើងឆេះព្រៃលិចទឹក។ ដោយផ្តោតលើមូលហេតុចំបងដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងការពារកុំឱ្យមូលហេតុទាំងនោះកើតមានឡើង គឺអាចជួយកាត់បន្ថយចំនួនភ្លើងឆេះព្រៃលិចទឹកបានអតិបរមា។

*ក) ការផលិតសម្ភារៈផ្សព្វផ្សាយ*

ដើម្បីទទួលបានសំភារៈផ្សព្វផ្សាយសាមញ្ញ ងាយយល់ និងមានអត្ថន័យគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សហគមន៍មូលដ្ឋាន ក្រុមការងារដែលទទួលបន្ទុកការងារនេះត្រូវពិចារណានូវសកម្មភាពមួយចំនួនដែលបានរៀបរាប់ខាងក្រោម៖

- រៀបចំរូបភាព និងសារអប់រំ សម្រាប់ផលិតជាសម្ភារៈផ្សព្វផ្សាយ
- ផលិតសម្ភារៈផ្សព្វផ្សាយ
- រៀបចំប្រជុំជាមួយអភិបាលស្រុក ក្រុមប្រឹក្សាឃុំ សហគមន៍នេសាទ និងក្រុមការងារល្បាតភ្លើងឆេះព្រៃ ដើម្បីកំណត់ទីតាំងសម្រាប់តម្លើងប៉ាណូ និងប្រជាពលរដ្ឋគោលដៅសម្រាប់ចែកចាយសម្ភារៈផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការអប់រំផ្សព្វផ្សាយ។ ផ្តល់ផ្ទាំងរូបភាព និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយមួយចំនួនទៅមន្ត្រីនស្រុក និងឃុំ ដើម្បីឱ្យពួកគេជួយចែកចាយនិងផ្សព្វផ្សាយបន្ត
- តម្លើងប៉ាណូអប់រំផ្សព្វផ្សាយនៅទីតាំងដែលបានកំណត់។

*ខ) បង្កើនការយល់ដឹងនិងជំរុញឱ្យមានការចូលរួមក្នុងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក*

- កំណត់ភូមិ ទីតាំង និងក្រុមគោលដៅ (កសិករដែលមានដីស្រែនៅក្នុងតំបន់២ និងតំបន់៣ អ្នកនេសាទ អ្នករកឃ្មុំ អ្នកប្រមាញ់សត្វ អ្នកឃ្វាលគោ-ក្របី) សម្រាប់យុទ្ធនាការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម
- ប្រមូលឯកសារពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋគោលដៅ ដូចជាប្រជាពលរដ្ឋដែលមានដីអាស្រ័យផលនៅក្នុងតំបន់២និងតំបន់៣ ម្ចាស់ត្រាទ័រ អ្នកនេសាទ និងអ្នកប្រម៉ាញ់សត្វ
- រៀបចំប្រជុំផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋគោលដៅ និងបង្កើនការចូលរួមគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក
- ចែកចាយខិត្តប័ណ្ណ និងផ្ទាំងរូបភាពដល់ប្រជាពលរដ្ឋមូលដ្ឋានដែលរស់ក្នុងភូមិកៅលដៅ

*ឃ) ធ្វើការល្បាតទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកជាប្រចាំ*

ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកត្រូវបានបង្កើតឡើង និងដំណើរការយាមល្បាតដោយផ្អែកលើផែនការល្បាតប្រចាំសប្តាហ៍ដែលបានរៀបចំដោយមានការព្រមព្រៀងគ្នារវាងសមាជិកក្រុមល្បាត។ សមាជិកក្រុមល្បាតនីមួយៗត្រូវ យកឧបករណ៍ពន្លត់ភ្លើងឆេះព្រៃចល័តទៅជាមួយ ដើម្បីត្រៀមខ្លួនជាស្រេចក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក

ដែលអាចធ្វើទៅបាននៅពេលបានជួបប្រទះក្នុងពេលល្បាត។ ក្រៅពីនេះ នៅក្នុងកំឡុងពេលល្បាត ក្រុមល្បាតនីមួយៗត្រូវកត់ត្រារាល់សកម្មភាព និងព្រឹត្តិការណ៍នានាដែលបានឃើញ និងគិតថាអាចបង្កឱ្យមានភ្លើងឆេះព្រៃ នៅក្នុងទម្រង់របាយការណ៍ដែលបានចែកជូន។ រូបភាពនៃភ្លើងឆេះព្រៃលិចទឹក ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងសកម្មភាពដែលសង្ស័យថាអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកត្រូវតែថតទុកជាភស្តុតាងផងដែរ។ ប្រធានក្រុមល្បាតត្រូវផ្តល់ដំណឹងជូនមេឃុំ និងសង្កាត់រដ្ឋបាលជលផលពាក់ព័ន្ធដោយទៀងទាត់អំពីស្ថានភាពល្បាត ករណីសង្ស័យ ការកាប់ឆ្ការព្រៃលិចទឹក និងករណីភ្លើងឆេះព្រៃលិចទឹកជាក់ស្តែង ដើម្បីស្នើសុំជំនួយអន្តរាគមន៍ពីអង្គភាពពាក់ព័ន្ធនៅថ្នាក់ឃុំ ស្រុក និងខេត្ត ឱ្យបានទាន់ពេលវេលា។

មេឃុំ និងនាយសង្កាត់រដ្ឋបាលជលផលត្រូវចាត់ចែងត្រៀមប្រចាំការ តាមដាន និងរក្សាទំនាក់ទំនងជាមួយក្រុម ល្បាតតាមរយៈទូរស័ព្ទ ឬវិទ្យុទាក់ទងជាប្រចាំ ដូច្នេះអាចចាត់វិធានការឆ្លើយតបនឹងសំណើសុំការជួយធ្វើអន្តរាគមន៍ បន្ទាន់ពីក្រុមល្បាត។ ការស្នើសុំជំនួយអន្តរាគមន៍បន្ទាន់ពីក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក ឬខេត្ត សម្រាប់ករណីដែលភ្លើងឆេះព្រៃលិចទឹកមានទំហំធំ មិនអាចគ្រប់គ្រងបានដោយក្រុមល្បាត។

### ៥.១.៣ ការត្រៀមរួចជាស្រេច

ការត្រៀមរួចជាស្រេច គឺជាការរៀបចំទុកជាមុននូវរចនាសម្ព័ន្ធក្រុមការងារនៅថ្នាក់ភូមិ-ឃុំ-ស្រុក-ខេត្ត ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់សម្ភារៈនិងឧបករណ៍ចាំបាច់សម្រាប់ឆ្លើយតបជាបន្ទាន់ទៅនឹងភ្លើងឆេះព្រៃលិចទឹក ដែលអាចកើតមានឡើងជាយថាហេតុ។ ការត្រៀមនេះក៏មានគោលបំណងធ្វើការវាយតម្លៃ និងកំណត់ចំនួនមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ដែលត្រូវការសម្រាប់ជួយធ្វើអន្តរាគមន៍ទាន់ពេលវេលា និងសមស្របទៅនឹងទំហំនៃភ្លើងឆេះព្រៃលិចទឹកដែលអាចកើតមានឡើង ដើម្បីកាត់បន្ថយការចំណាយខ្ពស់សម្រាប់ការពន្លត់ភ្លើងឆេះព្រៃ។

*ក) បង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ ស្រុក និងខេត្ត*

- រៀបចំសេចក្តីព្រាងសេចក្តីសម្រេច តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅគ្រប់កំរិត
- សហការជាមួយអភិបាលខេត្ត និងអភិបាលស្រុកពាក់ព័ន្ធ រៀបចំកិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្ត និងស្រុកដើម្បីបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត និងស្រុក ស្របច្បាប់
- បង្កើតក្រុមការងារនិងក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។

- *ខ) ប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត*

យោងទៅតាមតួនាទី និងភារកិច្ចរបស់ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ដែលមានចែងនៅក្នុងសេចក្តីសម្រេច និងចុះហត្ថលេខាដោយអភិបាលខេត្ត ខណ្ឌរដ្ឋបាលជលផលកំពង់ធំគួររៀបចំកិច្ចប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ក្រោមគណៈអធិបតីភាពនៃគណៈអភិបាលខេត្តកំពង់ធំ នៅរៀងរាល់ដើមឆ្នាំ ដើម្បីជួយជំរុញ និងពង្រឹងការអនុវត្តការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា ដោយមានកិច្ចសហការល្អពីអ្នកពាក់ព័ន្ធទាំងអស់។ អ្នកចូលរួមនៅក្នុងអង្គប្រជុំនេះរួមមានសមាជិកទាំងអស់នៃក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងមេឃុំ។

របៀបវារៈ និងគោលបំណងនៃកិច្ចប្រជុំគឺធ្វើបទបង្ហាញអំពីផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រចាំឆ្នាំនៅថ្នាក់ខេត្ត និងស្រុក រំលឹកឡើងវិញអំពីតួនាទី និងភារកិច្ចរបស់ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក លើកបញ្ហាប្រឈមសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ (ទំនាក់ទំនង ការពង្រឹងច្បាប់ មធ្យោបាយពន្លត់ភ្លើងឆេះព្រៃ និង

ថវិកា) ដាក់ជូនឯកឧត្តមអភិបាលខេត្តពិនិត្យ និងផ្តល់យោបល់ ដើម្បីធានាថាការអនុវត្តកិច្ចគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រព្រឹត្តទៅបានរលូន និងមានភាពប្រសើរឡើង។

ក្រោយពីការប្រជុំបានបញ្ចប់ ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំរបាយការណ៍ប្រជុំ និងផ្ញើជូនទៅឯកឧត្តមអភិបាលខេត្តដើម្បីពិនិត្យ និងចុះហត្ថលេខា។ បន្ទាប់មករបាយការណ៍នេះនឹងត្រូវផ្ញើជូនទៅរដ្ឋបាល និងអង្គភាពពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត ស្រុក និងឃុំដើម្បីចាត់វិធានការអនុវត្ត។

### *គ) ប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក*

ខណ្ឌរដ្ឋបាលជលផលកំពង់ធំគួរសហការជាមួយអាជ្ញាធរស្រុករៀបចំការប្រជុំប្រចាំត្រីមាស ឬតាមការចាំបាច់នៅថ្នាក់ស្រុក ដើម្បីផ្តល់ឱកាសឱ្យក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក និងខណ្ឌរដ្ឋបាលជលផល ជួបជុំគ្នាពិភាក្សាអំពីលទ្ធផលនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងរយៈកាល០៣ខែកន្លងមក និងលើកយកបញ្ហាដែលបានជួបប្រទះ ដើម្បីឱ្យអាជ្ញាធរស្រុក ជាពិសេស គណៈបញ្ជាការឯកភាពស្រុក ផ្តល់យោបល់ អនុសាសន៍ និងចាត់វិធានការដោះស្រាយបញ្ហាទាំងនោះឱ្យទាន់ពេលវេលា។ តំណាងរដ្ឋបាលជលផល និងប្រធានក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្តគួរតែត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះ ដើម្បីឱ្យដំណោះស្រាយកាន់តែមានប្រសិទ្ធភាព និងកិច្ចសហការខ្ពស់។

បន្ទាប់ពីកិច្ចប្រជុំនេះ ខណ្ឌរដ្ឋបាលជលផលបាត់ដំបងត្រូវរៀបចំរបាយការណ៍នៃការប្រជុំប្រចាំត្រីមាសនេះ ហើយបញ្ជូនរបាយការណ៍នេះទៅអភិបាលស្រុកដើម្បីពិនិត្យ និងចុះហត្ថលេខា។ បន្ទាប់មករបាយការណ៍នឹងត្រូវចម្លងជូនទៅអង្គភាពពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីជ្រាបជាព័ត៌មាន និងចាត់វិធានការអនុវត្ត។

### *ឃ) ប្រជុំក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ*

ការប្រជុំក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកប្រចាំខែដែលដឹកនាំដោយមេឃុំ និងមានការចូលរួមពីនាយសង្កាត់រដ្ឋបាលជលផល ត្រូវបានរៀបចំឡើងជាទៀងទាត់ ដើម្បីចែករំលែកបទពិសោធន៍ដែលបានទទួលក្នុងចំណោមសមាជិក ក្រុមល្បាត ពិភាក្សាអំពីបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងពេលល្បាត និងស្វែងរកដំណោះស្រាយសមស្របដើម្បីដោះស្រាយ។

ដោយក្រុមល្បាតបានទទួលវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសគ្រប់គ្រងភ្លើងឆេះព្រៃលិចរួចមកហើយ ក្រុមល្បាតបានយល់ដឹងអំពីតួនាទីនិងភារកិច្ចរបស់ក្រុមល្បាត ការរៀបចំផែនការល្បាតប្រចាំប្រចាំខែ ការកត់ត្រាកំណត់ហេតុ វិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃលិចទឹក ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃនិងការប្រើប្រាស់ និងច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធមួយចំនួនដូចជា ច្បាប់ស្តីពីជលផល ច្បាប់ភូមិបាល អនុក្រឹត្យលេខ១៩៧។ល។ ដូច្នេះកិច្ចប្រជុំប្រចាំខែនេះក៏មានគោលបំណងរំលឹកឡើងវិញនូវចំណេះដឹង និងបន្ថែមនូវព័ត៌មានថ្មីដែលទើបនឹងទទួលបាន។

ទន្ទឹមនឹងនេះដែរ កិច្ចប្រជុំប្រចាំខែរបស់ក្រុមល្បាតក៏មានគោលបំណងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមល្បាតដើម្បីពង្រឹងតួនាទី និងភារកិច្ចរបស់ក្រុមល្បាត ដែលអាចបណ្តាលមកពីមានសមាជិកក្រុមល្បាតមួយចំនួនអសកម្ម មានជំងឺ មានធុរៈ ឬលាឈប់ពីក្រុម។ ក្រៅពីនេះ កិច្ចប្រជុំប្រចាំខែក៏ត្រូវបានរៀបចំឡើងសម្រាប់ធ្វើការត្រួតពិនិត្យស្ថានភាពឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ ដើម្បីឱ្យដឹងថាឧបករណ៍ណានៅប្រើបាន បាត់បង់ត្រូវទិញថ្មី ខូចត្រូវជួសជុល ឬ ទិញឧបករណ៍ថ្មីបន្ថែម សំដៅធានាថាក្រុមល្បាតមានឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកគ្រប់គ្រាន់យកទៅតាមខ្លួនក្នុងពេលល្បាត និងពន្លត់ភ្លើងឆេះព្រៃជាបន្ទាន់។ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងក្រុមល្បាតទៅតាមកាលៈទេសៈ និងស្ថានភាព។

កំណត់ហេតុនៃការប្រជុំប្រចាំខែត្រូវបានរៀបចំនៅពេលបញ្ចប់កិច្ចប្រជុំដើម្បីរាយការណ៍ទៅក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក និងនាយខណ្ឌរដ្ឋបាលជលផលបាត់ដំបង ដើម្បីជ្រាបជាព័ត៌មាន និងចាត់វិធានការឆ្លើយតបនឹងបញ្ហាប្រឈម។

### *ង) សាងសង់រចនាសម្ព័ន្ធសម្រាប់ការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក*

ដូចដែលបានរៀបរាប់ជូនខាងលើ រចនាសម្ព័ន្ធរូបវ័ន្តចាំបាច់ដែលត្រូវសាងសង់សម្រាប់ការងារទប់ស្កាត់ និងពន្លត់ភ្លើងឆេះ ដូចជា ការតម្លើងបង្គោលព្រំតំបន់៣បន្ថែម ការដាំបង្គោលនៅតាមព្រំប្រទល់ព្រៃលិចទឹកដែលបានឆេះ ការសាងសង់ប៉មត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក ការស្តារស្រះអូរធម្មជាតិ។ ដោយសារតែថវិកាមានកំណត់ ដូច្នេះមិនមែនរាល់តម្រូវការរូបវ័ន្តទាំងអស់នឹងត្រូវបានរៀបចំតែក្នុងមួយឆ្នាំដំបូងនោះទេ ប៉ុន្តែត្រូវបានរៀបចំពីមួយឆ្នាំទៅមួយឆ្នាំ តាមតម្រូវការអាទិភាពដែលបានកំណត់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ។ យោង ទៅតាមគោលការណ៍លទ្ធកម្ម និងបច្ចេកទេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវបានអនុវត្តជាជំហានៗដូចខាង ក្រោមនេះ៖

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងជាមួយមេឃុំ មេភូមិ សហគមន៍នេសាទ និងក្រុមល្បាតភ្លើងឆេះព្រៃ ដើម្បីកំណត់ទីតាំងសម្រាប់សាងសង់ប៉មអង្កេតភ្លើងឆេះព្រៃ ស្តារបឹង/អូរធម្មជាតិ និងតំបន់ភ្លើងឆេះព្រៃលិចទឹក ដែលត្រូវបោះបង្គោលនិងដាក់សញ្ញា។
- សិក្សាពីទំហំ បច្ចេកទេស និងតម្លៃប៉ាន់ស្មាននៃការស្តារបឹង/អូរធម្មជាតិ បង្គោលស៊ីម៉ងត៍ និងប៉មអង្កេតភ្លើង ឆេះព្រៃលិចទឹក សម្រាប់ការដេញថ្លៃ។
- រៀបចំឯកសារ និងដំណើរការលទ្ធកម្ម (ឯកសារប្រកាសដេញថ្លៃ ការជ្រើសរើសក្រុមហ៊ុនវិស្វកម្ម ត្រួតពិនិត្យការដេញថ្លៃ ប្រកាសក្រុមហ៊ុនវិស្វកម្មដែលត្រូវបានជ្រើសរើស) សម្រាប់ការស្តារស្រះ សាងសង់ប៉មយាម និងផលិតបង្គោលស៊ីម៉ងត៍។

### *ច) បង្កើនចំណេះដឹង និងជំនាញល្បាតភ្លើងឆេះព្រៃលិចទឹក*

- **រៀបចំឯកសារមេរៀនពីការល្បាតភ្លើងឆេះព្រៃលិចទឹកដែលមានការចូលរួម៖** ការបណ្តុះបណ្តាលនេះផ្តោតលើប្រធានបទស្តីអំពី តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមល្បាត សារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកចំពោះប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ទំនាបបឹងទន្លេសាបនិងមនុស្សជាតិ យុទ្ធសាស្ត្រល្បាតភ្លើងឆេះព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍វៃឆ្លាតដើម្បីធ្វើការត្រួតពិនិត្យ និងរាយការណ៍ (SMART Connection) ការប្រើប្រាស់និងថែរក្សាឧបករណ៍ល្បាត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដោយប្រើប្រាស់ទូរស័ព្ទដៃ ច្បាប់ជលផលនិងលិខិតបទដ្ឋានច្បាប់ទាក់ទងនឹងភ្លើងឆេះព្រៃលិចទឹក ការធ្វើផែនការ និងការសរសេររបាយការណ៍។
- **រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការល្បាតភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម ជូនក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក៖** ការបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅថ្នាក់ឃុំ ដើម្បីផ្តល់ឱកាសដល់សមាជិកក្រុមល្បាតទាំងអស់បានចែករម្លែក និងរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក ជាពិសេសពីគ្រូបង្គោល អំពីវិធីសាស្ត្រគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយប្រើប្រាស់បច្ចេកទេសទំនើប
- **ប្រជុំរៀបចំផែនការល្បាតប្រចាំខែ និងប្រចាំសប្តាហ៍នៅថ្នាក់ឃុំ** ដើម្បីអនុញ្ញាតឱ្យសមាជិកក្រុមល្បាតទាំងអស់ចូលរួមពិភាក្សាអំពីផែនការល្បាតដោយការស្ម័គ្រចិត្ត និងម្ចាស់ការ ដើម្បីអនុវត្តក្រោយពីកិច្ចប្រជុំនេះ។ ផែនការល្បាតនេះត្រូវបានពិនិត្យ និងចុះហត្ថលេខាដោយមេឃុំសាមី
- តាមដាន និងកែលម្អការអនុវត្តចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលស្តីពី "**ការល្បាតភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម**" របស់ក្រុមល្បាត ដើម្បីធានាបាននូវគុណភាពនៃប្រសិទ្ធភាពល្បាត។

### *ឆ) បំពាក់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត*

ឧបករណ៍ល្បាតសម្រាប់ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំប្រើប្រាស់ជារួម និងប្រើប្រាស់ជាបុគ្គល ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរួមមាន បំពង់ពន្លត់អគ្គីភ័យ ទូរស័ព្ទវៃឆ្លាត (BlackView) ប្រើប្រាស់សម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃ ដ្រូន វិទ្យុទាក់ទង ប្រអប់សង្គ្រោះបឋម ម៉ាស់បិទច្រមុះ វ៉ែនតាការពារភ្លើង ស្រោមដៃ ធុងបាញ់ទឹកចល័តដែលមានចំណុះ២៥លីត្រ មួកសុវត្ថិភាព កាបូបស្ពាយ ស្បែកជើងពន្លត់អគ្គីភ័យ អង្រឹង កាំបិតដងវែង ប៉ែល ពិល ម៉ូតូ គោយន្តបំពាក់ដោយម៉ាស៊ីនបូមទឹក ស៊ីទែនទឹក ទុយោ និងក្បាលបាញ់ទឹក នឹងត្រូវទិញ និងចែកជូនដល់ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកដើម្បីប្រើប្រាស់ទៅតាមការចាំបាច់។

បទបញ្ញត្តិសម្រាប់ការប្រើប្រាស់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ ដែលត្រូវប្រើប្រាស់ដោយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកត្រូវតែបង្កើត និងផ្សព្វផ្សាយដល់សមាជិកទាំងអស់តាមរយៈការប្រជុំនៅថ្នាក់ឃុំ ដើម្បីធានាថាឧបករណ៍ទាំងអស់នោះត្រូវបានប្រើប្រាស់តាមគោលការណ៍ និងត្រូវបានថែរក្សាប្រើប្រាស់បានយូរ។ ការបណ្តុះបណ្តាលបន្ថែមនៅថ្នាក់ឃុំស្តីពីការប្រើប្រាស់ និងថែរក្សាឧបករណ៍ពន្លត់ភ្លើងឆេះព្រៃឱ្យបានត្រឹមត្រូវនឹងត្រូវបានរៀបចំជូនសមាជិកក្រុមល្បាតទាំងអស់ ដើម្បីធានាថាឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងយូរអង្វែង។

## ៥.២ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក

ដំណាក់ការនៃការជួយធ្វើអន្តរាគមន៍នេះផ្តោតសំខាន់លើការល្បាតព្រៃលិចទឹកជាប្រចាំ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការអនុវត្តច្បាប់ស្តីពីជលផល ក្រោមការគាំទ្រដោយផ្ទាល់ពីប្រធានក្រុមប្រឹក្សាឃុំ និងនាយសង្កាត់រដ្ឋបាលជលផលនៃភូមិសាស្ត្រសាមី។ ដើម្បីពង្រឹង និងផ្តល់អំណាចដល់ក្រុមល្បាតធ្វើការល្បាតភ្លើងឆេះព្រៃប្រកបដោយប្រសិទ្ធភាព មេឃុំ និងនាយសង្កាត់ត្រូវណែនាំក្រុមល្បាតឱ្យគិតគូរពិចារណាអនុវត្តសកម្មភាពសំខាន់នៅពេលដែលក្រុមល្បាតជួបប្រទះនឹងករណីភ្លើងឆេះព្រៃលិចទឹកកំពុងកើតឡើងក្នុងទ្រង់ទ្រាយខុសៗគ្នាក្នុងពេលល្បាត សមាជិកក្រុមល្បាតត្រូវចាត់វិធានការពន្លត់ភ្លើងឆេះព្រៃតាមការណែនាំដូចខាងក្រោមៈ

### *ក) ករណីភ្លើងឆេះព្រៃលិចទឹកទ្រង់ទ្រាយតូច*

ក្នុងករណីដែលក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកជួបប្រទះនឹងភ្លើងឆេះព្រៃលិចទឹកមានទ្រង់ទ្រាយតូច អាចគ្រប់គ្រងបាន ក្រុមល្បាតត្រូវប្រើប្រាស់ឧបករណ៍ចល័តដែលបានយកមកជាមួយ ឬវត្ថុដែលអាចរកបាននៅទីនោះតាមការណែនាំដូចខាងក្រោមៈ

- បិទមាត់ និងច្រមុះដោយប្រើម៉ាស់ ក្រម៉ា ឬ អាវយឺត ដើម្បីកាត់បន្ថយការស្រូបយកផ្សែង ផេះ និងធូលី
- ប្រើមែកឈើដើម្បីវាយពន្លត់ភ្លើង
- ប្រើប៉ែល ឬចបកាប់ ដើម្បីជីកដីលប់ភ្លើង ឬកាយជាផ្លូវភ្លើងជុំវិញកុំឱ្យភ្លើងរាលដាលបន្ត
- ប្រើធុងបាញ់ទឹកចល័តដើម្បីពន្លត់ភ្លើង ហើយត្រូវប្រាកដថាភ្លើងបានរលត់ទាំងស្រុងមុននឹងចាកចេញពីកន្លែងកើតហេតុ ដើម្បីចៀសវាងកុំឱ្យភ្លើងឆេះឡើងវិញ
- ថតរូបភាព និងរាយការណ៍ពីហេតុការនេះជូនមេឃុំ និងសង្កាត់រដ្ឋបាលជលផលដែលនៅជិតបំផុតតាមរយៈទូរស័ព្ទ វិទ្យុទាក់ទង ឬកម្មវិធីស្មាតហ្វូន (SAMRT-BalckView)។

### ខ) ករណីភ្លើងឆេះព្រៃលិចទឹកទ្រង់ទ្រាយមធ្យម ឬ ធំ

ប្រសិនបើជាភ្លើងឆេះព្រៃលិចទឹកមានកម្រិតមធ្យម ឬធំ ទាំងក្រុមល្បាត និងអ្នកចូលរួមពន្លត់ភ្លើងឆេះព្រៃលិចទឹកទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន ដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន ដោយចាត់វិធានការពន្លត់ភ្លើងឆេះព្រៃតាមវិធីដូចខាងក្រោមៈ

- រាល់សមាជិកក្រុមល្បាតត្រូវតែបិទមាត់ និងច្រមុះឱ្យបានរហ័សដោយប្រើម៉ាស់ ក្រម៉ា ឬអាវយឺតដើម្បីកាត់បន្ថយការស្រូបយកនូវផ្សែង ផេះ និងធូលី ដែលមានផលប៉ះពាល់អវិជ្ជមានដល់សុខភាព
- ជូនដំណឹងដល់មេភូមិ មេឃុំ និងសង្កាត់រដ្ឋបាលជលផលដែលនៅជិតបំផុតតាមរយៈទូរស័ព្ទ វិទ្យុទាក់ទង ឬកម្មវិធីស្មាតហ្វូន (SAMRT-BalckView) អំពីព្រឹត្តិការណ៍ភ្លើងឆេះព្រៃលិចទឹកដែលកំពុងកើតមានឡើង ដើម្បីទទួលបាននូវបទអន្តរាគមន៍ទាំងកម្លាំង និងសម្ភារៈសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានស្រាប់នៅក្នុងឃុំ ព្រមទាំងជំនួយពីស្រុក ឬខេត្តបន្ថែម
- ប្រើឧបករណ៍ពន្លត់អគ្គិភ័យចល័តដែលបានយកមកជាមួយ ពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលអាចធ្វើទៅបានដើម្បីទប់ស្កាត់ការរាលដាលភ្លើងឆេះព្រៃ។ នៅក្នុងពេលពន្លត់ភ្លើង ត្រូវស្ថិតនៅឱ្យឆ្ងាយពីភ្លើងបន្តិចដើម្បីចៀសវាងគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ
- ប្រមូលផ្តុំមនុស្សមួយចំនួនដែលកំពុងស្នាក់នៅ ឬធ្វើស្រែ ចំការ ឬនេសាទ នៅក្បែរកន្លែងកើតហេតុឱ្យជួយពន្លត់ភ្លើងឆេះព្រៃលិចទឹក ដោយប្រើឧបករណ៍ដែលមានស្រាប់ដូចជា ម៉ាស៊ីនបូមទឹក គោយន្តត្រាក់ទ័រ ស៊ីទែនទឹក ធុងទឹក ទុយោ។ល។
- មេឃុំត្រូវជូនដំណឹងទៅលោកអភិបាលស្រុកជាបន្ទាន់ដើម្បីសុំជំនួយរថយន្តពន្លត់អគ្គិភ័យ និងកងកម្លាំងពន្លត់អគ្គិភ័យមកកាន់កន្លែងកើតហេតុដើម្បីរួមគ្នាពន្លត់ភ្លើងឆេះព្រៃលិចទឹក
- មេឃុំក៏ស្នើសុំឱ្យប្រធានភូមិជួយប្រមូលប្រជាជនដែលស្ថិតនៅភូមិដែលជិតបំផុត ដោយយកឧបករណ៍ដែលអាចប្រើបានមកជាមួយ ដូចជាគោយន្ត ម៉ាស៊ីនបូមទឹក ទុយោ ធុងទឹក ជួយពន្លត់ភ្លើងឆេះព្រៃជាបន្ទាន់។ សុំឱ្យពួកគាត់បិទមាត់ និងច្រមុះដោយប្រើម៉ាស់ កន្សែង ឬក្រម៉ា ដើម្បីរក្សាសុខភាពផ្ទាល់ខ្លួន។
- បើសិនជារថយន្តពន្លត់អគ្គិភ័យមិនអាចចូលទៅដល់ទីតាំងភ្លើងឆេះព្រៃបានទេ យានយន្តទាំងនោះអាចត្រូវបានប្រើជាអ្នកផ្គត់ផ្គង់ទឹក បំពេញស៊ីទែនដែលផ្ទុកនៅលើគោយន្ត ឬយានយន្តកែច្នៃដើម្បីដឹកយកទៅពន្លត់ភ្លើងឆេះព្រៃលិចទឹក
- គោយន្ត និងត្រាក់ទ័រអាចប្រើសម្រាប់ឈូសជាផ្លូវភ្លើង បោសសំអាតសំណល់សរីរាង្គស្ងួតដែលងាយឆេះ នៅតំបន់ខាងក្រោមទិសខ្យល់បក់តាមដែលអាចធ្វើបាន (វាលស្មៅ ឬព្រៃស្បាត) ដើម្បីបញ្ឈប់ការរាលដាលនៃភ្លើងឆេះព្រៃលិចទឹក
- ត្រូវប្រាកដថាភ្លើងឆេះព្រៃលិចទឹកត្រូវបានពន្លត់ទាំងស្រុង ដើម្បីចៀសវាងការកើតឡើងវិញនូវភ្លើងឆេះព្រៃ មុនពេលចាកចេញពីកន្លែងកើតហេតុ
- រៀបចំរបាយការណ៍ស្តីពីភ្លើងឆេះព្រៃលិចទឹកដែលមានរៀបរាប់អំពីទីតាំងនៃភ្លើងឆេះព្រៃ ផ្ទៃដីព្រៃដែលបានឆេះ មូលហេតុ អ្នកចូលរួម ចំនួនមនុស្សដែលបានចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃ ឧបករណ៍ពន្លត់អគ្គិភ័យដែលបានប្រើប្រាស់ ទំហំនៃការខូចខាត និងអនុសាសន៍សម្រាប់ពិចារណាដើម្បីចាត់វិធានការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនាពេលខាងមុខ

- គួរពិចារណាពីការទូទាត់ថ្លៃប្រេងឥន្ធនៈសម្រាប់គោយន្ត រថយន្តកែច្នៃ ត្រាក់ទ័រ ដែលបានប្រើដោយអ្នកចូលរួមដើម្បីដឹកទឹកពន្លត់ភ្លើងឆេះព្រៃលិចទឹក និងឈូសឆាយបង្កើតផ្លូវភ្លើងទប់ស្កាត់ការរាលដាលភ្លើងឆេះព្រៃលិចទឹកទៅតាមការប្រើប្រាស់ជាក់ស្តែង បើសិនជាមានថវិកា។ ការទូទាត់នេះគឺជាវិធីសាស្ត្រមួយជួយធានាបាននូវការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួមប្រកបដោយនិរន្តរភាព។

## ៥.៣ ការស្តារព្រៃលិចទឹក

យោងទៅតាមថវិកាសម្រាប់ស្តារព្រៃលិចទឹកមានកំណត់ ស្ថានភាពរូបភូមិសាស្ត្រ និងជីវៈចម្រុះនៃតំបន់ព្រៃលិចទឹកដែលបានឆេះនៅក្នុងខេត្តបាត់ដំបង វិធីសាស្ត្រនៃការស្តារព្រៃលិចទឹកឡើងវិញនៅទីនេះគួរត្រូវពិចារណាលើជម្រើសពីរគឺ ការស្តារឡើងវិញតាមរយៈការការពារ និងថែរក្សាដំណុះរុក្ខជាតិតាមបែបធម្មជាតិ និងការដាំកូនឈើព្រៃលិចទឹកបន្ថែមនៅកន្លែងដែលមិនមានដើមមេពូជ។

### ៥.៣.១ ការសិក្សាអំពីវិធីសាស្ត្រស្តារព្រៃលិចទឹកទៅតាមស្ថានភាពជាក់ស្តែង

***ក) ការសិក្សាអំពីវិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានឆេះ***

ការវាយតម្លៃតំបន់ភ្លើងឆេះព្រៃលិចទឹកដោយឆាប់រហ័ស ត្រូវបានអនុវត្តដើម្បីប្រមូលព័ត៌មានអំពីវិសាលភាពនៃការខូចខាតដោយភ្លើងឆេះ គូសផែនទីទីតាំងព្រៃលិចទឹកដែលត្រូវស្តារ ទិដ្ឋភាពភូមិសាស្ត្រ រូបសាស្ត្រ ជីវសាស្ត្រ ជីវៈចម្រុះ និងអេកូឡូស៊ីនៃតំបន់ភ្លើងឆេះព្រៃ ប្រភេទរុក្ខជាតិដើមដែលត្រូវជ្រើសរើសសម្រាប់ដាំ វិធីសាស្ត្រស្តារ (ដាំឡើងវិញ ដាំបន្ថែម និងជំនួយដំណុះធម្មជាតិ) និងថៃទាំដែលចំណាយតិច គម្លាតនៃការដាំ ចំនួនកូនឈើដែលត្រូវដាំ ផែនការស្តារ និងចំណាយប៉ាន់ស្មាន។ ការវាយតម្លៃនេះនឹងត្រូវធ្វើឡើងនៅដើមរដូវប្រាំង (ខែធ្នូ ឬ ខែមករា) ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំ និងអនុវត្តការស្តារព្រៃលិចទឹក។

***ខ) ការប្រជុំថ្នាក់ឃុំលើកទី១ដើម្បីរៀបចំផែនការស្តារព្រៃលិចទឹក***

នេះគឺជាការប្រជុំលើកដំបូងក្នុងចំណោមអ្នកពាក់ព័ន្ធ រួមមាន សង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សហគមន៍នេសាទ ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក និងអង្គការដៃគូក្រៅរដ្ឋាភិបាលដែលមានថវិកាគាំទ្រ ដើម្បីពិភាក្សាអំពីផែនការសកម្មភាពដើម្បីស្តារព្រៃលិចទឹកដែលបានឆេះ ដោយសង្កត់ធ្ងន់ទៅលើការជ្រើសរើសទីតាំងស្តារដោយការការពារនិងថែទាំសម្រាប់ដំណុះធម្មជាតិ ការដាំកូនឈើឡើងវិញ ការដាំកូនឈើបន្ថែម ការជ្រើសរើសប្រភេទព្រៃលិចទឹកសម្រាប់ដាំ ការបង្កើតថ្នាលបណ្តុះកូនឈើ ការបណ្តុះកូនឈើ ការរៀបចំកន្លែងដាំកូនឈើ ការដឹកជញ្ជូនកូនឈើ ការកៀរគរប្រជាជនឱ្យចូលរួមដាំកូនឈើ ការគាំទ្រនិងតាមដានដំណើរការដាំកូនឈើ ការរៀបចំពិធីដាំដើមឈើ ការវាយតម្លៃអត្រារស់និងការលូតលាស់នៃកូនឈើ ការបង្កើតក្រុមការងារនៅមូលដ្ឋានដើម្បីគាំទ្រការស្តារព្រៃលិចទឹក ថវិកា និងការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការស្តារព្រៃលិចទឹក។

***គ) ការកំណត់ព្រំប្រទល់ និងគូរផែនទីតំបន់ព្រៃលិចទឹកដែលត្រូវស្តារ***

មន្ត្រីខណ្ឌរដ្ឋបាលជលផល ធ្វើការជាមួយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក កំណត់ព្រំប្រទល់ និងគូរផែនទីតំបន់ព្រៃលិចទឹកដែលត្រូវភ្លើងឆេះ ដើម្បីកាន់តែយល់ដឹងច្បាស់ពីទីតាំងភ្លើងឆេះព្រៃដែលត្រូវស្តារ ចំនួនបង្គោល និងស្លាកសញ្ញាការពារតំបន់ភ្លើងឆេះព្រៃលិចទឹកដែលចាំបាច់ត្រូវដាក់នៅតាមព្រំប្រទល់ ដើម្បីទប់ស្កាត់ការប៉ុនប៉ងការប្រើប្រាស់ដីក្នុងតំបន់ទាំងនោះសម្រាប់ដាំស្រូវ ឬដំណាំនានា។ ផែនទីដែលត្រូវផលិតនេះ ត្រូវដាក់បញ្ចូលនិយាមកានៃចំណុចដែលត្រូវដាំបង្គោល និងដាក់ស្លាកសញ្ញា។

ក្នុងពេលជាមួយគ្នានេះ មេភូមិ និងមេឃុំគួរតែធ្វើការផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីការកំណត់ និងការការពារតំបន់ភ្លើងឆេះព្រៃលិចទឹកទាំងអស់នៅក្នុងដែនរដ្ឋបាលគ្រប់គ្រងរបស់ខ្លួន សម្រាប់ការស្តារព្រៃលិចទឹក និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនល្មើសណាដែលទន្ទ្រានដីព្រៃលិចទឹកធ្វើជាកម្មសិទ្ធិ តាមរយៈការប្រជុំនានានៅថ្នាក់ភូមិ និងថ្នាក់ឃុំ។

***ង) ការការពារតំបន់ស្តារព្រៃលិចទឹក***

ការការពារទីតាំងស្តារព្រៃលិចទឹកពីការលែងសត្វគោ ក្របី ឱ្យចូលស៊ីស្មៅ ត្រូវបានហាមឃាត់ ព្រោះសត្វនឹងដើរជាន់បំផ្លាញកូនឈើដែលនៅតូចៗ ដូច្នេះការដាក់ស្លាកសញ្ញាដើម្បីជូនដំណឹងដល់អ្នកឃ្វាលគោ ក្របី អំពីការហាមឃាត់មិនឱ្យសត្វចូលក្នុងតំបន់ស្តារព្រៃលិចទឹកគឺជាការចាំបាច់។ មេឃុំ និងប្រធានភូមិពាក់ព័ន្ធទាំងអស់ត្រូវជួយផ្សព្វផ្សាយបន្ថែមអំពីព័ត៌មានអំពីការការពារទីតាំងស្តារព្រៃលិចទឹកដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនការចូលរួមក្នុងការស្តារព្រៃលិចទឹកទាំងអស់គ្នា សំដៅទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត។

***ច) ការល្បាតតំបន់ស្តារព្រៃលិចទឹក***

វាមានសារៈសំខាន់ខ្លាំងណាស់ដែលក្រុមល្បាតត្រូវបញ្ចូលការត្រួតពិនិត្យទីតាំងស្តារព្រៃលិចទឹកទាំងអស់ គិតទាំងតំបន់ស្តារឡើងវិញដោយការការពារដើម្បីដំណុះរុក្ខជាតិដោយធម្មជាតិ និងដាំកូនឈើឡើងវិញ នៅក្នុងផែនការល្បាតប្រចាំសប្តាហ៍ និងប្រចាំខែ ដើម្បីធានាថាទីតាំងស្តារព្រៃលិចទឹកទាំងអស់មានសុវត្ថិភាព ចៀសផុតពីសកម្មភាពរំខាននានាដែលធ្វើឱ្យប៉ះពាល់ដល់ការរស់រាន និងលូតលាស់របស់កូនឈើដូចជា ការលែងគោ-ក្របីឱ្យស៊ីស្មៅ ការដាំដំណាំកសិកម្ម និងភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់ស្តារព្រៃលិចទឹក។

ទន្ទឹមនឹងនេះដែរ នៅពេលត្រួតពិនិត្យទីតាំងស្តារព្រៃលិចទឹក ក្រុមល្បាតត្រូវរាយការណ៍ទៅនាយសង្កាត់រដ្ឋបាលជលផលសាមី អំពីផលប៉ះពាល់អវិជ្ជមានទៅលើកូនឈើដែលទើបនឹងដុះដូចជា ស្មៅក្រាស់ ឬកំប្លោកគ្របសង្កត់លើកូនឈើ សត្វល្អិតបំផ្លាញកូនឈើ និងស្មៅរាតត្បាតធ្វើឱ្យកូនឈើស្រេស ឬងាប់ដោយសារមិនមានពន្លឺថ្ងៃ ខ្វះទឹក សម្ពាធនៃគំលាត និងមិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដើម្បីចាត់វិធានការសង្គ្រោះកូនឈើតាមបែបសុវ្បឌ្ឍិកម្មព្រៃលិចទឹក ដែលមានប្រយោជន៍ដល់ការធ្វើឱ្យប្រសើរឡើងនូវការរស់រាន និងអត្រាកំណើនលូតលាស់នៃកូនឈើព្រៃលិចទឹក។

***៥.៣.២ ការស្តារព្រៃលិចទឹកដោយវិធីសាស្ត្រជំនួយដំណុះធម្មជាតិ***

បើសិនជាតំបន់ភ្លើងឆេះព្រៃលិចទឹកស្ថិតនៅក្បែរព្រៃលិចទឹកដែលមានដើមឈើមេពូជច្រើន តំបន់នោះមិនចាំបាច់ត្រូវស្តារឡើងវិញដោយការដាំកូនឈើបន្ថែមទេ ព្រោះថាដើមឈើមេពូជនឹងទម្លាក់គ្រាប់ពូជ ពង្រាយពាសពេញព្រៃនៅក្នុងខែធ្នូ និងមានកូនដំណុះធម្មជាតិក្នុងខែធ្នូ និងមករា បើសិនជាដីនៅសើម ប៉ុន្តែបើដីស្ងួត គ្រាប់ព្រៃលិចទឹកនឹងពន្យារការចេញពន្លករហូតដល់ដើមរដូវវស្សា ក្រោយពីមានភ្លៀងធ្លាក់៣ ឬ ៤ដងរួចមក។ ទោះបីជាមានកូនដំណុះធម្មជាតិច្រើនក៏ដោយ តំបន់ភ្លើងឆេះលិចទឹកដែលត្រូវស្តារក៏ត្រូវការថែរក្សាទៅតាមការណែនាំដូចខាងក្រោម។

សហគមន៍មូលដ្ឋានបានរាយការណ៍មកថា កូនព្រៃលិចទឹកធម្មជាតិភាគច្រើនបានងាប់ក្រោមសម្ពាធនៃព្រៃស្បាត និងស្មៅក្រាស់ កំប្លោកជាន់ពេលទឹកស្រក និងភ្លើងឆេះព្រៃលិចទឹក។ ដូច្នេះការថែទាំ ឬរំដោះកូនឈើនៅក្នុងតំបន់ស្តារព្រៃលិចទឹកដោយការសំអាតស្មៅក្នុងបរិវេណ១ម៉ែត្រជុំវិញវា ជាន់ពង្រាបស្មៅ យកចេញនូវកំប្លោកដែលគ្របសង្កត់លើកូនឈើ និងហាមគោ-ក្របីចូលក្នុងរយៈពេល៣ឆ្នាំដំបូង គឺជាការជាចាំបាច់។ សកម្មភាពទាំងនេះមិនត្រឹមតែជួយសង្គ្រោះជីវិតកូនឈើប៉ុណ្ណោះទេ ព្រមទាំងទាំងជួយបង្កើនការលូតលាស់នៃកូនឈើផងដែរ។

វិធីសាស្ត្រថែទាំកូនឈើបែបនេះហៅថា "ជំនួយដំណុះរុក្ខជាតិតាមបែបធម្មជាតិ" ដែលត្រូវអនុវត្តយ៉ាងតិចក្នុងរយៈពេល៣ឆ្នាំដំបូង ដើម្បីថែរក្សាកូនឈើឱ្យមានកម្លាំងគ្រប់គ្រាន់ យកឈ្នះលើការប្រកួតប្រជែងដណ្ដើមយកពន្លឺថ្ងៃ លំហ ទឹក សារធាតុចិញ្ចឹម ប្រឆាំងនឹងស្មៅ និងរុក្ខជាតិនានាដែលនៅជុំវិញវា។

## ៥.៣.៣ ការស្ដារព្រៃលិចទឹកដោយការដាំកូនឈើបន្ថែម

### *ក) រៀបចំសិក្ខាសាលាស្ដីពីការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើ និងវិធីសាស្ត្រស្ដារព្រៃលិចទឹក*

មន្ត្រីជំនាញនៃរដ្ឋបាលជលផល សហការជាមួយមន្ត្រីជំនាញផ្សេងៗ រៀបចំឯកសារដែលទាក់ទងនឹងការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើព្រៃលិចទឹក និងវិធីសាស្ត្រស្ដារព្រៃលិច ទឹក។ ឯកសារនេះផ្ដោតទៅលើ៖

- **ការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើ៖** ការជ្រើសរើសទីតាំង ការបង្កើតក្រុមបណ្ដុះកូនឈើ (យ៉ាងតិច៤០% នៃសមាជិកក្រុមជាស្ត្រី) ការគ្រោងនិងសាងសង់ថ្នាលបណ្ដុះកូនឈើខ្នាតតូច តម្រូវការសម្ភារៈសាងសង់ ការជ្រើសរើស/លាយដីដាក់ក្នុងថង់ ការប្រមូលគ្រាប់ ការបណ្ដុះគ្រាប់ពូជ ការប្រមូលកូនឈើដែលដុះដោយធម្មជាតិ កូនស្ទូងកូនឈើនៅក្នុងថង់ ការថែទាំកូនឈើ ការដឹកជញ្ជូនកូនឈើ និងការកត់ត្រាអំពីចំណាយ វត្តមានសមាជិក ចំនួនថង់ ចំនួនគ្រាប់ពូជ ចំនួនកូនឈើ។ល។

- **វិធីសាស្ត្រស្ដារព្រៃលិចទឹក៖** ការជ្រើសរើសទីតាំងស្ដារនិងផលិតផែនទី ការសិក្សាអំពីរុក្ខជាតិ គម្របដី គម្របព្រៃ ភូមិសាស្ត្រ រូបសាស្ត្រ និងជីវសាស្ត្រនៃតំបន់ស្ដារព្រៃលិចទឹកដើម្បីកំណត់វិធីសាស្ត្រស្ដារព្រៃលិចទឹកសមស្របទៅនឹងតំបន់នីមួយៗ ដូចជា ជំនួយដំណុះរុក្ខជាតិតាមបែបធម្មជាតិ ការដាំជួស និងការដាំកូនឈើបន្ថែម។ វិធីសាស្ត្រស្ដារព្រៃលិចទឹកគិតបញ្ចូលទាំងការវាយតម្លៃទីតាំងស្ដារព្រៃលិចទឹក ការជ្រើសរើសប្រភេទកូនឈើដែលត្រូវដាំតាមតំបន់ ការផលិតកូនឈើ ការដឹកជញ្ជូនកូនឈើ គម្លាតរវាងកូនឈើដែលត្រូវដាំ ទំហំ រណ្ដៅ របៀបដាំ ការការពារនិងថែទាំ ការរៀបចំផែនការស្ដារ ការបង្កើតការងារក្រុមនៅមូលដ្ឋានដើម្បីជួយការងារស្ដារព្រៃលិចទឹក និងទម្រង់ឯកសារសម្រាប់កត់ត្រាសកម្មភាពស្ដារព្រៃលិចទឹក។

### *ខ) គាំទ្រសហគមន៍រៀបចំថ្នាលបណ្ដុះកូនឈើ*

កូនឈើព្រៃលិចទឹកសម្រាប់ការស្ដារព្រៃលិចទឹក គួរតែត្រូវបានបណ្ដុះដោយសហគមន៍នេសាទដែលស្ថិតនៅក្បែរទីតាំងស្ដារ ព្រោះវាជាផ្នែកមួយនៃការអភិវឌ្ឍសមត្ថភាពមូលដ្ឋានក្នុងការផលិតកូនព្រៃលិចទឹក និងការធានានិរន្តរភាពនៃការស្ដារព្រៃលិចទឹក។ ដូច្នេះមន្ត្រីខណ្ឌរដ្ឋបាលជលផលដែលបានចូលរួមសិក្ខាសាលា ត្រូវចុះទៅភូមិគោលដៅ ដើម្បីគាំទ្រសហគមន៍នេសាទរៀបចំថ្នាលបណ្ដុះកូនឈើខ្នាតតូច និងផលិតកូនព្រៃលិចទឹកទៅតាមការណែនាំដូចខាងក្រោម៖

- **ការជ្រើសរើសទីតាំងថ្នាលបណ្ដុះកូនឈើ៖** ជ្រើសរើសយកកន្លែងដែលសមស្របបំផុតសម្រាប់រៀបចំថ្នាលបណ្ដុះកូនឈើដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងថ្នាលបណ្ដុះកូនឈើ។ ទំហំនៃទីតាំងគឺអាស្រ័យទៅតាមចំនួនកូនឈើដែលត្រូវផលិត

- **ការបង្កើតក្រុមបណ្ដុះកូនឈើ៖** យ៉ាងហោចណាស់ក៏មានមនុស្សយ៉ាងតិច១០នាក់ ក្នុងនោះស្ត្រីមានយ៉ាងតិច៥នាក់ ត្រូវបានជ្រើសរើស និងចងក្រងជាក្រុមបណ្ដុះកូនឈើ។ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាលបណ្ដុះកូនឈើរួមមាន តួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុម ការបែងចែកផលប្រយោជន៍ត្រូវបានរៀបចំឡើងតាមរយៈការប្រជុំពិគ្រោះយោបល់ក្នុងចំណោមសមាជិកក្រុម ដើម្បីធានាថាការងារនេះត្រូវបានដំណើរការដោយរលូន និងមានតម្លាភាព។

- **ការបង្កើនសមត្ថភាពក្រុមបណ្ដុះកូនឈើ៖** ខណ្ឌរដ្ឋបាលជលផលផ្ដល់ការបណ្ដុះបណ្ដាលតាមរយៈការអនុវត្តផ្ទាល់ស្ដីពីការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើ ជាមួយនឹងសកម្មភាពការតំឡើងថ្នាលបណ្ដុះកូនឈើ ការលាយដីច្រកថង់ ការប្រមូលគ្រាប់ពូជព្រៃលិចទឹក ការបណ្ដុះគ្រាប់ពូជ ការស្ទូងកូនឈើក្នុងថង់ និងការថែរក្សាកូនឈើ ដល់សមាជិកទាំងអស់នៃក្រុមបណ្ដុះកូនឈើ ដើម្បីធានាថាក្រុមនេះអាចដំណើរការបណ្ដុះកូនឈើដោយខ្លួនឯងបាន។ នៅពេលជាមួយគ្នានេះដែរ ខណ្ឌរដ្ឋបាលជលផលក៏ត្រូវផ្ដល់ចំណេះដឹងដល់ក្រុមបណ្ដុះកូនឈើនូវការរៀបចំផែនការបណ្ដុះកូនឈើ ការរៀបចំបញ្ជីកត់ត្រាតាមដានអំពីពេលវេលា និងសកម្មភាពដែលបានអនុវត្តដោយសមាជិកក្រុមនីមួយៗ សម្ភារៈដែលបានប្រើប្រាស់សម្រាប់ការងារបណ្ដុះកូនឈើ ចំនួនកូនឈើតាមប្រភេទ និងការចំណាយ
- **ការគាំទ្របច្ចេកទេសដល់ក្រុមបណ្ដុះកូនឈើ៖** ខណ្ឌរដ្ឋបាលជលផលត្រូវចាត់តាំងមន្ត្រីបង្គោលម្នាក់ចុះជួយក្រុមបណ្ដុះកូនឈើជាប្រចាំ ដើម្បីរៀបចំថ្នាលបណ្ដុះ ផលិត និងថែរក្សាកូនឈើព្រៃលិចទឹកទៅតាមដំណាក់កាលជាក់ស្ដែង។

### *គ) ការប្រជុំថ្នាក់ឃុំលើកទី២ដើម្បីរៀបចំផែនការសកម្មភាពស្ដារព្រៃលិចទឹក*

កិច្ចប្រជុំពិគ្រោះយោបល់លើកទី២នៅថ្នាក់ឃុំដើម្បីពិនិត្យ និងបញ្ចប់ផែនការស្ដារព្រៃលិចទឹកដែលបានរៀបចំក្នុងការប្រជុំលើកទី១ គឺជាការចាំបាច់ដើម្បីយកផែនការនេះទៅអនុវត្តនៅខែបន្ទាប់។ អ្វីដែលសំខាន់នៃអង្គប្រជុំនេះ គឺការពិនិត្យមើលការរៀបចំការងារនៅមូលដ្ឋានដែលសន្យាថានឹងត្រូវបានធ្វើក្រោយពីការប្រជុំលើកដំបូង និងបញ្ជាក់អំពីការកៀរគរសហគមន៍មូលដ្ឋានឱ្យចូលរួមក្នុងព្រឹត្តិការណ៍ដាំកូនឈើនាពេលខាងមុខនេះ។ អ្នកចូលរួមនៃកិច្ចប្រជុំនេះរួមមាន ក្រុមការងារស្ដារព្រៃលិចទឹកនៅមូលដ្ឋានដែលទើបនឹងបានបង្កើត ខណ្ឌ/សង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សហគមន៍នេសាទ ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក និងក្រុមផលិតកូនឈើព្រៃលិចទឹក។

### *ឃ) រៀបចំពិធីដាំកូនព្រៃលិចទឹក*

ព្រឹត្តិការណ៍នៃពិធីដាំព្រៃលិចទឹកគួរត្រូវបានរៀបចំឡើងនៅក្នុងស្រុកគោលដៅនីមួយៗ ដើម្បីផ្សព្វផ្សាយឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការទប់ស្កាត់ ពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្ដារព្រៃលិចទឹកឡើងវិញ ជាពិសេស លើកកម្ពស់ការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការទប់ស្កាត់ ការការពារ ការស្ដារ និងការថែរក្សាព្រៃលិចទឹកពីការប៉ុនប៉ងបំផ្លិចបំផ្លាញណាមួយ។

ពិធីដាំកូនព្រៃលិចទឹកនេះគួរត្រូវស្ថិតនៅក្រោមគណៈអធិបតីភាពរបស់លោកអភិបាលស្រុកដែលជាប្រធាន

ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃនៅថ្នាក់ស្រុក។ ប្រសិនបើជាអាច ការចូលរួមរបស់ឯកឧត្តមគណៈអភិបាលនៃអភិបាលខេត្ត និង/ឬឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ជាគណៈអធិបតី នឹងធ្វើឱ្យព្រឹត្តិការណ៍នេះកាន់តែសំខាន់ជាប្រវត្តិសាស្ត្រ និងត្រូវបានគេចាត់ទុកថាជាយុទ្ធនាការផ្សព្វផ្សាយដ៏ទូលំទូលាយសម្រាប់ការគ្រប់គ្រងធនធានជលផល និងការស្ដារព្រៃលិចទឹកនៅទូទាំងប្រទេសកម្ពុជា។

ព័ត៌មាន សារជាអក្សរ និងរូបភាពនៃពិធីដាំកូនព្រៃលិចទឹកត្រូវបានចែករម្លែកឱ្យបានទូលំទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈដូចជា ទូរទស្សន៍ វិទ្យុ ហ្វេសប៊ុក តេឡេក្រាម។ល។ ដែលជាផ្នែកមួយនៃការអប់រំបង្កើនការយល់ដឹងសាធារណៈអំពីការគ្រប់គ្រងធនធានជលផល ជាពិសេសការគ្រប់គ្រងព្រៃលិចទឹកនៅក្នុងតំបន់បឹងទន្លេសាបទាំងមូល។

ខណ្ឌរដ្ឋបាលជលផលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលកិច្ចពិភាក្សាជាមួយអាជ្ញាធរស្រុក និងឃុំ ដើម្បីរៀបចំពិធីដាំកូនព្រៃលិចទឹកនេះដោយផ្ដោតទៅលើ ការកំណត់និងអញ្ជើញភ្ញៀវកិត្តិយស ការរៀបចំ

វេទិកាទីកន្លែងដាំកូនឈើ ការដឹកជញ្ជូន ការធ្វើពិធីការ សម្ភារៈសម្រាប់ដាំកូនឈើ អាហារសម្រន់ ការប្រមូលនិងចែកចាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងភស្តុភារ។

***ង) គាំទ្រ និងត្រួតពិនិត្យការដាំកូនព្រៃលិចទឹក***

ដើម្បីធានាថាការដាំដើមឈើត្រូវអនុវត្តបានល្អ ក្រោយពីបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលាស្តីពី *"ការគ្រប់គ្រងថ្នាលបណ្តុះកូនព្រៃលិចទឹក និងវិធីសាស្ត្រស្តារព្រៃលិចទឹក"* នៅមុនពេលចាប់ផ្តើមដំណើរការដាំកូនឈើ មន្ត្រីនៃខណ្ឌរដ្ឋបាលជលផលដែលទទួលបន្ទុកគាំទ្រ និងត្រួតពិនិត្យការដាំកូនព្រៃលិចទឹកនៅក្នុងតំបន់ភ្លើងឆេះ ត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ១ ឬ២ថ្ងៃ មុនដាំកូនឈើ ក្រុមការងារទទួលបន្ទុកការដាំកូនឈើ ត្រូវដោតកំណាត់ឈើ/ឬស្សីដើម្បីសម្គាល់ចំណុចដែលត្រូវជីករណ្តៅ ដើម្បីជៀសវាងកុំឱ្យកូនឈើត្រូវបានដាំជិត/ឆ្ងាយពីគ្នាពេក នៅជិត ឬជាប់នឹងដំណុះធម្មជាតិ នៅក្រោមម្លប់ដើមឈើ ឬក្នុងព្រៃគុម្ពោត
- រាល់ការដឹកកូនឈើពីថ្នាលទៅកន្លែងដាំគឺត្រូវបានកត់ត្រានូវចំនួនកូនឈើតាមប្រភេទ និងចំនួនកូនឈើ

  ដែលបានខូចខាតក្នុងកំឡុងពេលដឹកជញ្ជូនដោយគោយន្ត និង/ឬ ដោយទូក ដើម្បីងាយស្រួលដល់ការគណនាចំនួនកូនឈើជាក់ស្តែងដែលបានដាំ និងការទូទាត់ថវិកាជូនក្រុមអ្នកដាំ។ ទិន្នន័យកូនឈើដែលបានការកត់ត្រានេះក៏មានសារៈសំខាន់ផងដែរ ព្រោះវាចាត់ទុកថាជាទិន្នន័យដើមសម្រាប់ការត្រួតពិនិត្យអត្រារស់នៃកូនព្រៃលិចទឹកដែលបានដាំ
- បែងចែកតំបន់ស្តារព្រៃលិចទឹកជាអនុតំបន់សម្រាប់ដាំកូនឈើទៅតាមក្រុម ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យដោយក្រុមការងារគ្រប់គ្រងដាំកូនឈើ។ វិធីសាស្ត្រនេះនឹងជួយសម្រួលក្រុមការងារក្នុងការកំណត់ចំនួនកូនឈើដែលបានដាំ ចំនួនកូនឈើដែលបានដាំមិនត្រូវបច្ចេកទេសដើម្បីឱ្យក្រុមនោះដាំឡើងវិញ ចំនួនកូនឈើដែលបានខូចនៅពេលដាំ និងការទូទាត់តម្លៃកូនឈើដែលបានដាំជាក់ស្តែង
- មុនពេលចាប់ផ្តើមដាំកូនឈើ មន្ត្រីខណ្ឌរដ្ឋបាលជលផលត្រូវរំលឹកដោយសង្ខេបនូវបច្ចេកទេសដាំកូនឈើដែលបញ្ជាក់នូវការដឹកជញ្ជូនកូនឈើដោយសុវត្ថិភាព ទំហំរណ្តៅដែលត្រូវជីក គម្លាតពីរណ្តៅមួយទៅរណ្តៅមួយ ទំហំរណ្តៅ ការជីករណ្តៅ ការហែកថង់ ការដាំកូនឈើ ការលុបរណ្តៅ ការបង្ហាប់ដីក្នុងរណ្តៅ ការពង្រឹងកូនឈើដែលបានដាំ ការស្រោចទឹកបើសិនជាដីស្ងួតពេក និងការថែរក្សាក្រោយពេលដាំ
- គាំទ្រ និងតាមដានការដាំដើមឈើដោយប្រជាសហគមន៍ ដើម្បីធានាឱ្យបាននូវទំហំរណ្តៅដែលបានជីក

  ការដាំ ការលប់រណ្តៅ ការពង្រឹងដើមកូនឈើ និងការប្រមូលថង់កូនឈើ ត្រូវបានអនុវត្តសមស្របទៅតាមការណែនាំបច្ចេកទេស
- រៀបចំរបាយការណ៍៖ នាយសង្កាត់រដ្ឋបាលជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការដាំកូនឈើបន្ទាប់ពីការដាំកូនដើមឈើបានបញ្ចប់។ របាយការណ៍នេះត្រូវបានពិនិត្យ និងចុះហត្ថលេខាដោយនាយខណ្ឌរដ្ឋបាលជលផល ព្រមទាំងចំលងជូនប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្តនិងស្រុក និងមេឃុំពាក់ព័ន្ធ ដើម្បីជ្រាបជាព័ត៌មាន។ របាយការណ៍ស្តីពីការដាំដើមឈើត្រូវតែផ្តល់នូវព័ត៌មានច្បាស់លាស់អំពីទីតាំង និងទំហំព្រៃលិចទឹកដែលបានស្តារ ចំនួនកូនឈើតាមប្រភេទដែលបានដាំ ពេលវេលាដាំ ចំនួននិងសមាសភាពអ្នកចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ ព្រមទាំងបញ្ហាប្រឈមរកឃើញក្នុងពេលដាំ ដោយហេតុថាវាមានសារៈសំខាន់សម្រាប់ការងារតាមដាន និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។

***ច) ការថែរក្សាតំបន់ស្តារព្រៃលិចទឹក***

ដើម្បីធានាបាននូវអត្រារស់ និងកំណើនលូតលាស់ខ្ពស់ទាំងកូនឈើដែលបានដាំ និងកូនឈើដែលដុះដោយធម្មជាតិ (ដំណុះធម្មជាតិ) តំបន់ស្តារព្រៃលិចទឹកចាំបាច់ត្រូវតែបានថែទាំល្អ។ ផ្អែកលើស្ថានភាពជាក់ស្តែងនៃជីវៈចម្រុះនៅក្នុងតំបន់ស្តារព្រៃលិចទឹក វិធីសាស្រ្តមួយចំនួនដែលនឹងត្រូវបានអនុវត្តដើម្បីថែទាំកូនឈើដែលបានដាំ និងដំណុះធម្មជាតិនៅទីនោះគឺ ការការពារតំបន់ស្តារព្រៃលិចទឹកពីការទន្ទ្រានយកដីដាំដំណាំ ការលុកលុយរបស់សត្វគោ-ក្របី ការរំដោះកូនឈើឱ្យរួចផុតពីការសង្កត់ដោយស្មៅ ឬ កំប្លោក និងការការពារកុំឱ្យមានភ្លើងឆេះព្រៃម្តងទៀត។ បច្ចេកទេសលម្អិតសម្រាប់ការការពារ និងថែរក្សាតំបន់ស្តារព្រៃលិចទឹកនឹងត្រូវបានដាក់បញ្ចូលនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី **ការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ និងវិធីសាស្រ្តស្តារព្រៃលិចទឹក** សម្រាប់មន្ត្រីបង្គោលរបស់ខណ្ឌរដ្ឋបាលជលផល ដែលអាចនឹងត្រូវធ្វើឡើងនៅដើមឆ្នាំ២០២២។

***ឆ) ការវាយតម្លៃអត្រារស់ និងលូតលាស់នៃកូនឈើក្នុងតំបន់ស្តារព្រៃលិចទឹក***

វាជាចាំបាច់ណាស់ក្នុងការត្រួតពិនិត្យអត្រារស់ និងកំណើនលូតលាស់របស់កូនឈើនៅដើមរដូវប្រាំងនៃឆ្នាំទី២នៃអាយុកូនឈើ ដើម្បីឱ្យដឹងពីអត្រារស់ និងកំណើនលូតលាស់របស់កូនឈើតាមប្រភេទ និងទីតាំង។ ការវាយ

តម្លៃនេះគួរអនុវត្តរាល់២ឆ្នាំម្តង នៅលើទីតាំងសំណាកដដែល។

គោលបំណងចម្បងនៃការវាយតម្លៃអត្រារស់ និងកំណើនលូតលាស់របស់កូនឈើគឺការស្វែងយល់អំពីកត្តាដែលនាំឱ្យកូនឈើងាប់ លូតលាស់យឺត និងផ្តល់អនុសាសន៍អំពីវិធីសាស្រ្តដើម្បីធ្វើឱ្យកូនឈើដែលបានដាំ និងត្រូវដាំនៅពេលខាងមុខមានអត្រារស់ និងកំណើនលូតលាស់ខ្ពស់ ទៅតាមលក្ខខណ្ឌភូមិសាស្រ្ត និងជីវសាស្រ្តជាក់ស្តែងនៃតំបន់នីមួយៗ ដូចជាការការពារតំបន់ស្តារព្រៃលិចទឹកពីសកម្មភាពរំខាននានា ការការពារភ្លើងឆេះព្រៃលិចទឹក ការដាំជួស ការដាំបន្ថែម ការថែទាំ ការរំដោះកូនឈើ ការពង្រាបស្មៅ។ល។

## ៦. សមភាពយេនឌ័រនៅក្នុងការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

នៅក្នុងការអនុវត្តផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ការបញ្ជ្រាបយេនឌ័រ និងការការពារកុមារនឹងត្រូវបានយកចិត្តទុកដាក់ នៅគ្រប់សកម្មភាពរួមមាន ដំណើរការរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដោយអនុលោមតាមក្របខ័ណ្ឌការងារស្តីពីសមភាពយេនឌ័ររបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាពិសេសផែនការសកម្មភាពរបស់រដ្ឋបាលជលផល សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងកុមារ ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល (ឆ្នាំ២០១៦-២០២០)។

ដើម្បីរួមចំណែកលើកកម្ពស់ក្នុងការចូលរួមដោយសមភាពរវាងបុរស និងស្រ្តី នៅក្នុងសកម្មភាព និងការសម្រេចចិត្តនៅក្នុងក្រុមការងារទាំងបីថ្នាក់ (ឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត) ជាពិសេសនៅថ្នាក់ឃុំ សង្កាត់ដែលជាអ្នកអនុវត្តគម្រោងផ្ទាល់។ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នឹងធ្វើការសម្របសម្រួលជា មួយក្រុមការងារយេនឌ័រនៃរដ្ឋបាលជលផល ដើម្បីធានាថាផលប៉ះពាល់អវិជ្ជមាននៃវិសមភាពយេនឌ័រត្រូវបានដោះស្រាយនៅក្នុងការអនុវត្តផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ដោយផ្តល់ឱកាសស្មើភាពគ្នារវាងបុរស និងស្រ្តី នៅក្នុងសមាសភាពរចនាសម្ព័ន្ធគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក/ក្រុង និងឃុំ/សង្កាត់ និងការគិតគូរពិចារណាអំពីតម្រូវការ និងឧបសគ្គរបស់ស្រ្តីនៅក្នុងដំណើរការអនុវត្តផែនការនេះ។

ការពិចារណាមួយចំនួនទាក់ទងនឹងការកំណត់យន្តការអនុវត្តច្បាស់លាស់ ដើម្បីសម្រេចបាននូវសមភាពយេនឌ័រតាមរយៈការផ្សព្វផ្សាយ សេវាកម្ម និងការគាំទ្រផ្លូវច្បាប់ មានដូចខាងក្រោម៖

- ធានាឱ្យមានការចូលរួមស្មើភាពគ្នារវាងស្ត្រី និងបុរសនៅក្នុងគ្រប់សកម្មភាពនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនិងដំណើរការធ្វើសេចក្តីសម្រេចចិត្ត (ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ) ដោយបញ្ជាក់ពីការចូលរួម និងបន្ទុកការងាររបស់ស្ត្រីក្នុងកិច្ចការនេះ
- លើកទឹកចិត្តស្ត្រីឱ្យចូលរួមយ៉ាងសកម្មក្នុងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក និងឃុំ ដោយយកចិត្តទុកដាក់ចំពោះគោលបំណង សមត្ថភាព និងផលប្រយោជន៍របស់ពួកគេ
- ផ្តល់ឱកាសស្មើភាពគ្នាដល់ស្ត្រីក្នុងការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ពិចារណាការផ្តល់យោបល់អំពីតម្រូវការ និងចំណាប់អារម្មណ៍របស់ពួកគេ
- ការជំរុញការអនុវត្តបច្ចេកវិទ្យាទំនើបដែលសមស្របទៅនឹងការងាររបស់ស្ត្រី
- ការពារកុមារដែលមានអាយុក្រោម១៨ឆ្នាំ និងស្ត្រីមានផ្ទៃពោះពីការងារដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងជំនាញសម្រាប់យុវជន ដោយធានាបាននូវសុខភាព សុវត្ថិភាពការងារទាំងនៅកន្លែងធ្វើការ និងនៅមូលដ្ឋាន
- បង្ហាញពីតួនាទីដ៏មានតម្លៃរបស់ស្ត្រី និងបុរសនៅក្នុងវិស័យជលផល និងការអភិរក្សនៅក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលមានការចូលរួម។

## ៧. ក្របខណ្ឌការងារនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

បច្ចុប្បន្ននេះ ខណ្ឌរដ្ឋបាលជលផលបាត់ដំបង មិនទាន់មានផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅឡើយ ហើយក៏មិនមានធនធានគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹកដែរ។ ព័ត៌មានអំពីភ្លើងឆេះព្រៃលិចទឹកជាច្រើនករណីត្រូវបានចែករំលែក និងរាយការណ៍ដោយសហគមន៍នេសាទ និងប្រជាជនមូលដ្ឋានជូនស្ថាប័ន/អង្គភាពពាក់ព័ន្ធ ជាពិសេសខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមិនមានការជួយធ្វើអន្តរាគមន៍បន្ទាន់ណាមួយបានអនុវត្តដោយមានប្រសិទ្ធភាពក្នុងការពន្លត់ភ្លើងឆេះព្រៃដែលបានរាយការណ៍ជូននោះទេ ដោយហេតុថា តំបន់ភ្លើងឆេះស្ថិតនៅឆ្ងាយ មិនមានផ្លូវចេញចូល ព្រមទាំងមិនមានកម្លាំង ថវិកា និងឧបករណ៍គ្រប់គ្រាន់។ សូមបញ្ជាក់ថា នៅក្នុងឆ្នាំ២០២០ និង២០២១នេះ រដ្ឋបាលជលផល បានផ្តល់ជូននូវបំពង់ពន្លត់អគ្គីភ័យមួយចំនួនដល់សហគមន៍នេសាទ សម្រាប់ប្រើប្រាស់ពន្លត់ភ្លើងឆេះព្រៃលិចទឹកនៅពេលចាំបាច់។

ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលបានអនុវត្តកន្លងមកដោយស្ថាប័នពាក់ព័ន្ធ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល សហការជាមួយអង្គការ FAO នៃគម្រោងCAPFIS-Cature បានរៀបចំផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ដែលមានរយៈពេល៥ឆ្នាំ (ឆ្នាំ២០២១-២០២៥) ជាមួយនឹងក្របខ័ណ្ឌការងារដូចខាងក្រោមនេះ។

### ៧ ១.ពេលវេលាអនុវត្ត៖ ឆ្នាំ២០២១-២០២៥

### ៧.២ គោលបំណង

ព្រៃលិចទឹកក្នុងខេត្តបាត់ដំបងត្រូវបានការពារ និងលូតលាស់បានយ៉ាងល្អ ហើយគម្របព្រៃលិចទឹកបានកើនឡើងក្រោមយន្តការគ្រប់គ្រងភ្លើងឆេះព្រៃលិចដ៏មានប្រសិទ្ធភាពនៅថ្នាក់ខេត្ត ស្រុក និងឃុំ ជាមួយនឹងការប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម។

## ៧.៣ គោលដៅ

ដើម្បីឆ្លើយតបនឹងគោលដៅខាងលើ ការសម្រេចបាននូវគោលបំណងខាងក្រោមនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ដើម្បីឈានដល់គោលដៅដែលបានកំណត់៖

- ការយល់ដឹង និងការចូលរួមក្នុងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករបស់សហគមន៍ និងស្ថាប័នពាក់ព័ន្ធបានលើកកំពស់
- ផ្ទៃដីព្រៃលិចទឹក និងវាលស្មៅដែលរងផលប៉ះពាល់ដោយភ្លើងឆេះព្រៃលិចទឹកបានថយចុះ
- តំបន់ព្រៃលិចទឹកទាំងអស់ដែលរងការខូចខាតដោយភ្លើងឆេះបានស្តារឡើងវិញតាមរយៈការការពារថែទាំ និងដាំកូនឈើឡើងវិញដើម្បីទទួលបាននូវអត្ថប្រយោជន៍ទាំងប្រព័ន្ធអេកូឡូស៊ី និងប្រភពអាហារសរីរាង្គដែលមានសារធាតុចិញ្ចឹមខ្ពស់

## ៧.៤ លទ្ធផលរំពឹងទុក

### លទ្ធផលទី១៖ ការពិនិត្យឡើងវិញ ការកាត់បន្ថយហានិយភាព និងភាពត្រៀមរួចជាស្រេចសម្រាប់ទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកដ៏មានប្រសិទ្ធភាពបានរៀបចំ

លទ្ធផលទី១ឆ្លើយតបនឹង 3"R" នៅក្នុង 5"R" គឺការពិនិត្យឡើងវិញនូវបញ្ហាប្រឈមនៃភ្លើងឆេះព្រៃលិចទឹក

ការកាត់បន្ថយហានិភ័យភាពនៃភ្លើងឆេះព្រៃលិចទឹក និងការត្រៀមកម្លាំង សម្ភារៈរួចជាស្រេចដើម្បីជួយអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកជាបន្ទាន់ ដោយមានកិច្ចសហការល្អជាមួយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការដៃគូ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ។

សកម្មភាពដែលបានគ្រោងនឹងអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលទី១នេះរួមមាន ការប្រជុំជាមួយស្ថាប័នពាក់ព័ន្ធដើម្បីពិភាក្សាអំពីការបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត ការបង្កើតក្រុមល្បាតភ្លើងឆេះព្រៃថ្នាក់ឃុំ តម្រូវការសម្ភារៈផ្សព្វផ្សាយ ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់សហគមន៍មូលដ្ឋានឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសពន្លត់ភ្លើងឆេះព្រៃ ការគាំទ្រនិងការពង្រឹងការងារល្បាតភ្លើងឆេះព្រៃ ការពង្រឹងការអនុវត្តច្បាប់ជលផលដើម្បីទប់ស្កាត់ការកាប់ទន្ទ្រានព្រៃលិចទឹក និងការបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក។

### លទ្ធផលទី២៖ វិធានការ និងសកម្មភាពពន្លត់ភ្លើងឆេះព្រៃលិចទឹកមានភាពប្រសើរជាងមុន

លទ្ធផលទី២នេះផ្តោតលើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទស្ថាប័ននិងសមត្ថកិច្ចរាជរដ្ឋាភិបាលពាក់ព័ន្ធ សហគមន៍នេសាទ សហគមន៍មូលដ្ឋាន និងអង្គការដៃគូ ដើម្បីទទួលបាននូវបទអន្តរាគមន៍ដ៏ឆាប់រហ័សក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលកំពុងឆេះគំរាមកំហែងព្រៃលិចទឹក និងវាលស្មៅឱ្យបានទាន់ពេលវេលា។ លទ្ធផលនេះក៏មានគោលបំណងពង្រឹងការអនុវត្តច្បាប់ជលផល និងការបង្កើនតួលេខនៃភាពជោគជ័យចំពោះការកាត់ទោសប្រឆាំងនឹងសកម្មភាពខុសច្បាប់នៅក្នុងតំបន់ព្រៃលិចទឹក ទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ។

### លទ្ធផលទី៣៖ ព្រៃលិចទឹកដែលបានឆេះទាំងអស់បានស្តារឡើងវិញ

លទ្ធផលទី៣គឺផ្តោតលើការធ្វើឱ្យមានគម្របព្រៃលិចទឹកឡើងវិញនៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយសារភ្លើងឆេះ តាមរយៈការស្តារឡើងវិញដោយប្រើវិធីសាស្ត្រផ្សេងៗគ្នាដូចជា ការការពារនិងទប់ស្កាត់ការទន្ទ្រានយកដីធ្វើកសិកម្ម ការការពារកុំឱ្យគោ-ក្របីចូលក្នុងតំបន់ស្តារព្រៃលិចទឹក ការទប់ស្កាត់កុំឱ្យមានភ្លើងឆេះ

ព្រៃលិចទឹកឡើងវិញម្តងទៀតដើម្បីទុកឱ្យរុក្ខជាតិដុះឡើងវិញតាមបែបធម្មជាតិ ការថែរក្សាកូនឈើតាមរយៈជំនួយដំណុះរុក្ខជាតិ និងការដាំឡើងវិញ។

ការធ្វើសុវត្ថិកម្មព្រៃលិចទឹកតាមរយៈវិធីសាស្ត្រជំនួយដំណុះធម្មជាតិ នឹងត្រូវបានអនុវត្តនៅទីតាំងណាដែលដំណុះធម្មជាតិមិនសូវដុះលូតលាស់បានល្អដូចជា គ្រាប់ពូជមិនចេញពន្លក កូនឈើងាប់ទៅវិញក្រោយពេលដុះលូតលាស់មួយរយៈ ដំណុះកូនឈើព្រៃលិចទឹកតិច (ដង់ស៊ីតេទាប<២០០ដើម/ហ.ត) និងអត្រាលូតលាស់នៃកូនព្រៃលិចទឹកមានកម្រិតទាប ដោយសារឧបសគ្គធម្មជាតិ។ ការដាំបន្ថែមកូនព្រៃលិចទឹក ប្រភេទរាំង ត្រស់ តាសែង គ្ឍូរ និងច្រកែង នឹងត្រូវបានអនុវត្តនៅកន្លែងដែលមិនមានដើមមេពូជនៅក្បែរ ឬ មិនមានកូនព្រៃលិចទឹកដុះ។

## ៧.៨ ថវិកាប៉ាន់ស្មានសរុប៖ ៨៨៦.២០៥ ដុល្លារ ក្នុងរយៈពេល០៥ឆ្នាំ (២០២១-២០២៥)

ផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់ខេត្តបាត់ដំបងត្រូវបានចងក្រង អនុលោមតាមគោលការណ៍ណែនាំស្តីពី "**ការរៀបចំផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់បឹងទន្លេសាប**" របស់គម្រោង CAPFISH-Capture និងគោលការណ៍ 5"R"៖ ការពិនិត្យឡើងវិញ (Review) ការកាត់បន្ថយហានិភ័យ (Risk Reduction) ការត្រៀមខ្លួនរួចជាស្រេច (Readiness) ការឆ្លើយតបទៅនឹងភ្លើងឆេះព្រៃលិចទឹក (Response) និងការស្តារឡើងវិញព្រៃលិចទឹកដែលរិចរឹលដោយសារភ្លើងឆេះព្រៃលិចទឹក (Recovery/Restoration) ដោយប្រើវិធីសាស្ត្រសមស្រប។ គោលការណ៍នេះមានប្រយោជន៍ខ្លាំងណាស់សម្រាប់ការសរសេរផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដើម្បីផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់អ្នកអនុវត្តអំពីដំណើរការនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងស្តារព្រៃលិចទឹកឡើងវិញដើម្បីជានាបាននូវការសម្រេចលទ្ធផលរំពឹងទុកទាំងបីខាងលើ។

ផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះក៏ត្រូវបានបង្កើតឡើង ដោយស្របទៅនឹងផែនការគ្រប់គ្រងរបស់សហគមន៍នេសាទពាក់ព័ន្ធ ដែលជាវិធីសាស្ត្រមួយបញ្ជ្រាបការសម្រេចចិត្តរបស់សហគមន៍ទៅក្នុងការអនុវត្តផែន-ការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក តាមរយៈការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ។ ផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះមិនត្រឹមតែធ្វើឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសសហគមន៍មូលដ្ឋាន ឱ្យចូលរួមក្នុងយុទ្ធសាស្ត្រគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសពន្លត់ភ្លើងឆេះព្រៃលិចទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនការយល់ដឹងស្តីពីផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិច វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានឆេះ និងច្បាប់បទដ្ឋានគតិយុទ្ធដែលទាក់ទងនឹងការកាប់ឈូសឆាយព្រៃលិចទឹកដែលមានចែងក្នុងមាត្រាទី២៦ ២៧ និង២៨ នៃជំពូកទី៦ របស់ច្បាប់ជលផល ព្រមទាំងអនុក្រឹត្យលេខ១៩៧ ស្តីពីការកំណត់ដែនព្រៃលិចទឹកនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប។

ទាំងបុរស និងស្ត្រី ជាពិសេសក្រុមដែលងាយរងគ្រោះដោយសារភ្លើងឆេះព្រៃលិចទឹក មានតួនាទីសំខាន់ដូចគ្នាក្នុងការចូលរួមអនុវត្តដំណាក់កាលទាំង៥ (5Rs) នៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ ទោះបីយ៉ាងនេះក្តីក្នុងបរិបទបែបនេះ ការការពារស្ត្រី និងកុមារពីការងារដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដោយភ្លើងឆេះព្រៃលិចទឹកត្រូវបានធានា។

មួយវិញទៀត សង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន និងសហគមន៍នេសាទដែលពាក់ព័ន្ធនឹងភាពដែលអាចកើតមានឡើងនូវភ្លើងឆេះព្រៃលិចទឹកនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវពិចារណាអំពីវិធីសាស្ត្រដ៏សមស្របណាមួយដើម្បីឱ្យប្រជាពលរដ្ឋយល់ឃើញអំពីសារៈសំខាន់នៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលផ្សារភ្ជាប់នឹងធនធានជលផលនៅក្នុងតំបន់ ដោយហេតុថាសហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់នោះពឹងផ្អែកទាំងស្រុងទៅលើធនធានជលផល ជាពិសេសព្រៃលិចទឹកក្នុងការកាត់បន្ថយគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិនៅក្នុងតំបន់ទេសភាពបឹងទន្លេសាបទាំងមូល។

## ៨. ការត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីតាមដាន និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកឱ្យបានគ្រប់ជ្រុងជ្រោយ ក្រុមត្រួតពិនិត្យ និងវាយតម្លៃមួយត្រូវបានបង្កើតឡើង ដោយមានសមាសភាពមកពីតំណាងស្ថាប័នពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងក្រោមជាតិ រួមមាន៖

- **ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ៖** រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អាជ្ញាធរទន្លេសាប, នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន, និងអង្គការដៃគូ អង្គការក្រៅរដ្ឋាភិបាល
- **ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ៖** ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផល មន្ទីរបរិស្ថាន មន្ទីរធនធានទឹកនិងឧតុនិយម ការិយាល័យកសិម្ម ធនធានធម្មជាតិ និងបរិស្ថាន សហគមន៍នេសាទ និងអង្គការដៃគូក្រៅរដ្ឋាភិបាលពាក់ព័ន្ធនៅក្នុងខេត្តបាត់ដំបង។

រដ្ឋបាលជលផលត្រូវការទិន្នន័យ និងព័ត៌មានដើមបន្ថែម ដើម្បីប្រើប្រាស់ក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការនេះ។ ដើម្បីទទួលបានទិន្នន័យនិងព័ត៌មាននេះ រដ្ឋបាលជលផលត្រូវការការគាំទ្រទាំងបច្ចេកទេស និងថវិកាពីដៃគូអភិវឌ្ឍន៍នានា។

ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅមូលដ្ឋាននឹងត្រូវបានអនុវត្តដោយក្រុមត្រួតពិនិត្យ និងវាយតម្លៃនៃរដ្ឋបាលជលផល ដើម្បីឱ្យដឹងអំពីកម្រិតនៃគោលបំណង និងគោលដៅនៃផែនការដែលសម្រេចបាន ប្រសិទ្ធភាពនៃការចំណាយដោយប្រត្តិបត្តិករ និងផលប៉ះពាល់នៃសកម្មភាពអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងខេត្តបាត់ដំបង។

លើសពីនេះទៅទៀត ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃត្រូវប្រមូលព័ត៌មានថ្មីៗអំពីចំនួនករណីភ្លើងឆេះព្រៃលិចទឹក ទីតាំងនិងទំហំព្រៃដែលបានឆេះ ប្រភេទរុក្ខជាតិដែលរងការឆេះ ជនសង្ស័យដែលពាក់ព័ន្ធនឹងការបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក កម្លាំងមនុស្ស ឧបករណ៍ដែលបានប្រើប្រាស់ ប្រសិទ្ធភាពនៃការជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក និងចំណាយជាក់ស្តែង ដើម្បីផ្តល់អនុសាសន៍ជួយសម្រួល តម្រែតម្រង់ទិសការអនុវត្តផែនការឱ្យមានភាពល្អប្រសើរជាងមុន។

ការវាយតម្លៃផ្ទៃក្នុងនឹងត្រូវបានធ្វើឡើងដោយទៀងទាត់ជារៀងរាល់ឆ្នាំ រីឯការវាយតម្លៃដោយអ្នកជំនាញមកពីខាងក្រៅគួរត្រូវបានធ្វើ២ដង នៅពាក់កណ្តាលអាណត្តិ និងនៅមុនពេលបញ្ចប់ការអនុវត្តផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក។ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នៃរដ្ឋបាលជលផលជាអ្នករៀបចំឯកសារដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់អ្នកជំនាញវាយតម្លៃមកពីខាងក្រៅ (ខ្មែរ ឬបរទេស) និងគ្រប់គ្រងដំណើរការជ្រើសរើសអ្នកជំនាញការ។ លទ្ធផលដែលទទួលបានពីការវាយតម្លៃនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើនបទពិសោធន៍ ចំណេះដឹងសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ការស្តារព្រៃលិចទឹកនៅក្នុងខេត្តនាពេលអនាគត។ រាល់ចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមដែលបានរកឃើញក្នុងពេលអនុវត្តផែនការនឹងត្រូវបានយកមកពិចារណាសម្រាប់កិច្ចប្រឹងប្រែងក្នុងការកសាងសមត្ថភាពបច្ចេកទេស និងការរៀបចំផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកបន្ត។

រូបភាពដែលថតដោយដ្រូនក្នុងពេលចុះបំពេញការងារនៅទីវាល បានជួយសម្រួលដល់ការមើលលម្អិតនៅក្នុងទៅតំបន់នីមួយៗអំពីសំណល់សរីរាង្គស្ងួតដែលងាយឆេះ ទីតាំងសំខាន់ៗដែលជាប្រភពបង្ក និងរាលដាលភ្លើងឆេះព្រៃលិចទឹក ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងតំបន់ ជាពិសេសប្រព័ន្ធផ្លូវទឹក ផ្លូវធ្វើដំណើរដោយ

ថ្មើរជើងនិងយានយន្ត សំណើមដី សណ្ឋានដីប្រើប្រាស់ និងគម្របព្រៃ។ រូបភាពបែបនេះនឹងជួយសម្រួលដល់ការកំណត់អត្តសញ្ញាណនៃទីតាំង និងធាតុដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ផ្តល់ឱកាសងាយស្រួលដល់ការរៀបចំផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងការចេញចូលក្នុងតំបន់ដើម្បីជួយធ្វើអន្តរាគមន៍ជួយពន្លត់ភ្លើងឆេះព្រៃលិចទឹក។

មន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលជលផល អភិបាលខេត្ត អភិបាលស្រុកដែលជាប្រធាន និងអនុប្រធានក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនឹងចុះធ្វើការត្រួតពិនិត្យ វាយតម្លៃទៅតាមការចាំបាច់នៅទីតាំងអនុវត្តផ្ទាល់ ដោយប្រើប្រាស់ក្របខណ្ឌការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលបានរៀបចំរួចជាស្រេច។ ការត្រួតពិនិត្យ និងវាយតម្លៃនេះរួមបញ្ចូលទាំងការត្រួតពិនិត្យលទ្ធផល ផលប៉ះពាល់ជាក់ស្តែង និងគណនេយ្យភាពនៅមូលដ្ឋាន។

# ៩. សកម្មភាព និងថវិកានៃផែនការគ្រប់គ្រង និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត ឆ្នាំ២០២១-២០២៥

| ល.រ | សកម្មភាព | សូចនាករ (៥ឆ្នាំ) | ភាគីពាក់ព័ន្ធ | | ថវិកា (2021-2025) | ២០២១ (ត្រីមាស) | | | | ២០២២ ((ត្រីមាស) | | | | ២០២៣ (ត្រីមាស) | | | | ២០២៤ (ត្រីមាស) | | | | ២០២៥ (ត្រីមាស) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អ្នកដឹកនាំ | អ្នកគាំទ្រ | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | **លទ្ធផលទី១៖ ការសិក្សាពិនិត្យឡើងវិញនូវការកាត់បន្ថយហានិភ័យ និងភាពត្រៀមខ្លួនរួចជាស្រេចក្នុងការបង្កា ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានប្រសិទ្ធភាព។** | | | | **៤៨៣.៨៥៥** | | | | | | | | | | | | | | | | | | | | |
| ១.១ | **ការសិក្សាពិនិត្យឡើងវិញអំពីទម្រង់ បទពិសោធន៍ និងយុទ្ធសាស្ត្រនៃការទប់ស្កាត់ ការពន្លត់ភ្លើងឆេះព្រៃ និងស្តារព្រៃលិចទឹកឡើងវិញ ដែលបានអនុវត្តកន្លងមក។** | | | | **១៨.៣០០** | | | | | | | | | | | | | | | | | | | | |
| ១.១.១ | ប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំដើម្បីប្រមូលព័ត៌មានអំពីបញ្ហានៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និ វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក (៤៥$ x ១៩ប្រជុំ x ៥ឆ្នាំ) | ៩៥ប្រជុំថ្នាក់ឃុំ ៥របាយការណ៍ប្រជុំថ្នាក់ខេត្ត | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ភូមិ និងឃុំ | ៤.២៧៥ | ៨៥៥ | | | | ៨៥៥ | | | | ៨៥៥ | | | | ៨៥៥ | | | | ៨៥៥ | | | |
| | | | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | |
| | | | | | | H | | | H | | | | H | | | | H | | | | H | | | | H |
| ១.១.២ | ចុះអង្កេតតំបន់ភ្លើងឆេះព្រៃលិចទឹកដើម្បីប្រមូលនិយាមកា និងព័ត៌មានស្តីពីទិដ្ឋភាពភូមិ-រូបសាស្ត្រ-ឋានលេខា ទំហំនៃការខូចខាត ការប្រើប្រាស់ដី និងគម្របដីមុន និងក្រោយពេលភ្លើងឆេះ (៤៥$ x ៣ថ្ងៃ x ១៩ឃុំ x ៥ឆ្នាំ) | ៩៥ដងនៅថ្នាក់ឃុំ ៥របាយការណ៍ថ្នាក់ខេត្ត | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | សង្កាត់រដ្ឋបាលជលផល អាជ្ញាធរឃុំ និងសហគមន៍នេសាទ | ១២.៨២៥ | ២.៥៦៥ | | | | ២.៥៦៥ | | | | ២.៥៦៥ | | | | ២.៥៦៥ | | | | ២.៥៦៥ | | | |
| | | | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | | ១៩ប្រជុំ ១របាយការណ៍ | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |
| ១.១.៣ | ផលិតផែនទីភ្លើងឆេះព្រៃលិចទឹកនៅក្នុងស្រុកគោលដៅ (៦០$ x ៤ផែនទីx៥ឆ្នាំ) | ១៦ផែនទីថ្នាក់ស្រុក | នាយកដ្ឋានកិច្ចការជលផល | ខណ្ឌរដ្ឋបាលជលផល | ១.២០០ | ២៤០ | | | | ២៤០ | | | | ២៤០ | | | | ២៤០ | | | | ២៤០ | | | |
| | | | | | | ៤ផែនទី | | | | ៤ផែនទី បច្ចុប្បន្នភាព | | | | ៤ផែនទី បច្ចុប្បន្នភាព | | | | ៤ផែនទី បច្ចុប្បន្នភាព | | | | ៤ផែនទី បច្ចុប្បន្នភាព | | | |
| | | | | | | H | | | H | H | | | H | H | | | H | H | | | H | H | | | H |
| ១.២ | **ការកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃលិចទឹកដោយការលើកកំពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **១៦០.១៧០** | | | | | | | | | | | | | | | | | | | | |
| ១.២.១ | ផលិតផ្ទាំងរូបភាពផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធក្នុងការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក (១,៥$ x ១០០សន្លឹក x ១៩ឃុំ x ៥ឆ្នាំ) | ៩.៥០០សន្លឹក | រដ្ឋបាលជលផល | អង្គការ FAO | ១៤.២៥០ | ២.៨៥០ | | | | ២.៨៥០ | | | | ២.៨៥០ | | | | ២.៨៥០ | | | | ២.៨៥០ | | | |
| | | | | | | ១.៩០០សន្លឹក | | | | ១.៩០០សន្លឹក | | | | ១.៩០០សន្លឹក | | | | ១.៩០០សន្លឹក | | | | ១.៩០០សន្លឹក | | | |
| | | | | | | H | | | | H | | | | H | | | | H | | | | H | | | |
| ១.២.២ | ផលិត និងតម្លើងស្លាកសញ្ញាផ្សព្វផ្សាយនៅកន្លែងដែលមានមនុស្សកុះករ និងតាមដងផ្លូវចេញចូលសំខាន់ៗនៅក្នុងតំបន់ទំនាបព្រៃលិចទឹក (៣០០$ x ២ស្លាក x ១៩ឃុំ) | ៣៨ស្លាក | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ១១.៤០០ | ២.៧០០ | | | | ៥.៧០០ | | | | ៣.០០០ | | | | | | | | | | | |
| | | | | | | ៩ស្លាក | | | | ១៩ស្លាក | | | | ១០ស្លាក | | | | | | | | | | | |
| | | | | | | M | | | M | | | | M | | | | M | | | | M | | | | M |
| ១.២.៣ | រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមអ្នកពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផលនៅក្នុងតំបន់២ និងតំបន់៣ (១០០$ x ១៩ឃុំ x ៥ឆ្នាំ) | ១៩ច្បាប់ | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៩.៥០០ | ១.៩០០ | | | | ១.៩០០ | | | | ១.៩០០ | | | | ១.៩០០ | | | | ១.៩០០ | | | |
| | | | | | | ១៩ច្បាប់ | | | | ១៩ច្បាប់ បច្ចុប្បន្នភាព | | | | ១៩ច្បាប់ បច្ចុប្បន្នភាព | | | | ១៩ច្បាប់ បច្ចុប្បន្នភាព | | | | ១៩ច្បាប់ បច្ចុប្បន្នភាព | | | |
| | | | | | | | | | H | | | | H | | | | H | | | | H | | | | H |
| ១.២.៤ | ផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីការចូលរួមគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ច្បាប់ជលផល អនុក្រឹត្យ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធ (១៥០$ x ២ប្រជុំ x១៩ឃុំ x ៥ឆ្នាំ) | ១៩០ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២៨.៥០០ | ៥.៧០០ | | | | ៥.៧០០ | | | | ៥.៧០០ | | | | ៥.៧០០ | | | | ៥.៧០០ | | | |
| | | | | | | ៣៨ប្រជុំ | | | | ៣៨ប្រជុំ | | | | ៣៨ប្រជុំ | | | | ៣៨ប្រជុំ | | | | ៣៨ប្រជុំ | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១.២.៥ | ប្រជុំបង្កើត និងរៀបចំរចនាសម្ព័ន្ធក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក ថ្នាក់ឃុំ និងផែនការល្បាត (៨០$ x ១៩ឃុំ) | ១៩ក្រុម | ខណ្ឌរដ្ឋបាល ជលផល | អាជ្ញាធរមូលដ្ឋាន | ១.៥២០ | ១.៥២០<br>១៩ក្រុម<br>H | | | | |
| ១.២.៦ | ចុះល្បាតឃ្លាំមើលភ្លើងព្រៃឆេះលិចទឹកដោយក្រុមល្បាត៖ ៥ថ្ងៃ/ខែ (២៥០$ x ៤ខែ x ១៩ឃុំ x ៥ឆ្នាំ) | ១.៩០០ដង | ក្រុមល្បាត និង សង្កាត់រដ្ឋបាល ជលផល | អាជ្ញាធរមូលដ្ឋាន | ៩៥.០០០ | ១៩.០០០<br>៣៨០ដង<br>H H | ១៩.០០០<br>៣៨០ចដង<br>H H | ១៩.០០០<br>៣៨០ដង<br>H H | ១៩.០០០<br>៣៨០ដង<br>H H | ១៩.០០០<br>៣៨០ដង<br>H H |
| **១.៣** | **<u>ការត្រៀមខ្លួនជាស្រេច</u>៖ រៀបចំរចនាសម្ព័ន្ធការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក និងខេត្ត និងសម្ភារៈសំរាប់ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៣០៥.៣៨៥** | | | | | |
| **១.៣.១** | **បង្កើត និងពង្រឹងទំនាក់ទំនងរវាងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត និងក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ ដើម្បីជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ និងបំពាក់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត** | | | | **២១១.៣៨៥** | | | | | |
| ១.៣.១.១ | ប្រជុំជាមួយរដ្ឋបាលខេត្ត និងស្រុកគោលដៅពិភាក្សាអំពីការរៀបចំឯកសារចាំបាច់សម្រាប់ការបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ស្រុក និងខេត្ត (៦៥$ x ៦ប្រជុំ/ស្រុក) | ៤ប្រជុំ & សេចក្តីព្រាងToRs របស់ក្រុមការងារថ្នាក់ខេត្ត និងស្រុក | រដ្ឋបាលរដ្ឋបាល ខណ្ឌរដ្ឋបាល ជលផល និង មន្ទីរក.រ.ន | រដ្ឋបាលខេត្ត និង ស្រុកគោលដៅ | ២៦០ | ២៦០<br>៤ប្រជុំ<br>H | | | | |
| ១.៣.១.២ | ប្រជុំជាមួយរដ្ឋបាលខេត្ត និងស្រុកគោលដៅដើម្បីបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ស្រុក និងខេត្ត (៦៥$ x ៤ប្រជុំ/ស្រុក) | ៤ក្រុម | រដ្ឋបាលរដ្ឋបាល ខណ្ឌរដ្ឋបាល ជលផល និង មន្ទីរក.រ.ន | រដ្ឋបាលខេត្ត និង ស្រុកគោលដៅ | ២៦០ | ២៦០<br>៤ក្រុម<br>H | | | | |
| ១.៣.១.៣ | រៀបចំប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្តដើម្បីពិភាក្សាពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ និង ស្វែងរកដំណោះស្រាយបញ្ហា (១.៥០០$x ១ប្រជុំ/x ៥ឆ្នាំ) | ៥ប្រជុំ | រដ្ឋបាលរដ្ឋបាល ខណ្ឌរដ្ឋបាល ជលផល និង មន្ទីរក.រ.ន | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត | ៧.៥០០ | ១,៥០០<br>១ប្រជុំ<br>H H | ១,៥០០<br>១ប្រជុំ<br>H H | ១,៥០០<br>១ប្រជុំ<br>H H | ១,៥០០<br>១ប្រជុំ<br>H H | ១,៥០០<br>១ប្រជុំ<br>H H |
| ១.៣.១.៤ | រៀបចំប្រជុំជាមួយក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកដើម្បីពិភាក្សាពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ ស្វែងរកដំណោះស្រាយបញ្ហា និងលើកផែនការគាំទ្រការល្បាតឃ្លាំមើលភ្លើងឆេះព្រៃនៅថ្នាក់ឃុំ (៣២០$ x ២ប្រជុំ x ៤ស្រុក x ៥ឆ្នាំ) | ៤០ប្រជុំ | ខណ្ឌរដ្ឋបាល ជលផល និង មន្ទីរក.រ.ន | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ១២.៨០០ | ២.៥៦០<br>៨ប្រជុំ<br>H H | ២.៥៦០<br>៨ប្រជុំ<br>H H | ២.៥៦០<br>៨ប្រជុំ<br>H H | ២.៥៦០<br>៨ប្រជុំ<br>H H | ២.៥៦០<br>៨ប្រជុំ<br>H H |
| ១.៣.១.៥ | ទិញគោយន្តកែច្នៃបំពាក់ដោយម៉ាស៊ីនបូមទឹក២គ្រឿង ធុងទឹកចំណុះ១.០០០លីត្រ កាំភ្លើងបាញ់ទឹក២ និងទុយោ២ដុំ (៣.៦០០$ x ១៥គ្រឿង) | ១៥គ្រឿង | រដ្ឋបាល ជលផល | ខណ្ឌរដ្ឋបាល ជលផល | ៥៤.០០០ | | ២៨.៨០០<br>៨គ្រឿង<br>H | ២៥.២០០<br>៧គ្រឿង<br>H | | |
| ១.៣.១.៦ | ទិញទូកម៉ាស៊ីនបំពាក់ដោយម៉ាស៊ីនបូមទឹក២គ្រឿង ធុងទឹកចំណុះ ១.០០០លីត្រ កាំភ្លើងបាញ់ទឹក២ និងទុយោ២ដុំ (៣.០០០$ x ២ គ្រឿង) | ២គ្រឿង | រដ្ឋបាល ជលផល | ខណ្ឌរដ្ឋបាល ជលផល | ៦.០០០ | H | ៣.០០០<br>១គ្រឿង<br>H H | ៣.០០០<br>១គ្រឿង<br>H | | |
| ១.៣.១.៧ | ទិញម៉ូតូសម្រាប់ក្រុមល្បាតភ្លើងឆេះព្រៃ (២.៣០០$ x ៣២គ្រឿង) | ៣២គ្រឿង | រដ្ឋបាល ជលផល | ខណ្ឌរដ្ឋបាល ជលផល | ៧៣.៦០០ | H | ២៥.៣០០<br>១១គ្រឿង<br>H H | ២៥.៣០០<br>១១គ្រឿង<br>H H | ២៣.០០០<br>១០គ្រឿង<br>H | |
| ១.៣.១. | ទិញឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ (ប្រអប់សង្គ្រោះបឋម តង់ កាបូប | ៣៨កំប្លេ | រដ្ឋបាល | ខណ្ឌរដ្ឋបាល | ៤៥.៦០០ | | ២២.៨០០ | | ២២.៨០០ | |

| | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | ស្ពាយ ធុងស្ពាយបាញ់ទឹក រ៉ែនតា ស្បែកជើងកវែង កែវយឺត, GPS, ១drone ...) សម្រាប់ក្រុមល្បាត (១២០០$ x ២ឈុត x ១៩ឃុំ) | | ជលផល | ជលផល | | | | | | ១៩កំប្លេ | | | | | | | | ១៩កំប្លេ | | | | | | | |
| | | | | | | | | | | H | | | | | | | | H | | | | | | | |
| ១.៣.១.៩ | ប្រជុំជាមួយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំដើម្បីណែនាំអំពីរបៀបប្រើប្រាស់ លក្ខន្តិកៈ និងផ្តល់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក (៤៥$ x ២ប្រជុំ x ១៩ឃុំ) | ៣៨ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរឃុំ | ១.៧១០ | | | | | ៨៥៥ | | | | | | | | ៨៥៥ | | | | | | | |
| | | | | | | | | | | ១៩ប្រជុំ | | | | | | | | ១៩ប្រជុំ | | | | | | | |
| | | | | | | | | | | H | | | | | | | | H | | | | | | | |
| ១.៣.១.១០ | ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តស្តីពីបច្ចេកទេសពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់មន្ត្រីខណ្ឌរដ្ឋបាលជលផល និងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ស្រុក (៤៥$ x ២៥នាក់ x ៣ថ្ងៃ) | ១វគ្គ | រដ្ឋបាលជលផល | អង្គការ WCS | ៣.៣៧៥ | ៣.៣៧៥ | | | | | | | | | | | | | | | | | | | |
| | | | | | | ១វគ្គ | | | | | | | | | | | | | | | | | | | |
| | | | | | | | | | H | | | | | | | | | | | | | | | | |
| ១.៣.១.១១ | រៀបចំវគ្គបណ្តុះបណ្តាលថ្នាក់ស្រុកស្តីពីវិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់សមាជិកក្រុមល្បាតភ្លើងឆេះព្រៃ (២០$ x ៣០នាក់ x ២វគ្គ x ៤ស្រុក) | ៨វគ្គ | ខណ្ឌរដ្ឋបាលជលផល | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ៤.៨០០ | | | | | ២.៤០០ | | | | | | | | ២.៤០០ | | | | | | | |
| | | | | | | | | | | ៤វគ្គ | | | | | | | | ៤វគ្គ | | | | | | | |
| | | | | | | | | | | H | | | | | | | | H | | | | | | | |
| ១.៣.១.១២ | ថ្លៃសម្របសម្រួលសម្រាប់គ្រូបង្គោល និងសម្ភារៈសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល [(៤៥$ x ៣នាក់)+៥០$ (សំភារៈបណ្តុះបណ្តាល)] x ២វគ្គ x ៤ស្រុក | ៨វគ្គ | ខណ្ឌរដ្ឋបាលជលផល | | ១.៤៨០ | | | | | 740 | | | | | | | | 740 | | | | | | | |
| | | | | | | | | | | ៤វគ្គ | | | | | | | | ៤វគ្គ | | | | | | | |
| | | | | | | | | | | H | | | | | | | | H | | | | | | | |
| **១.៣.២** | **កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ប្រើប្រាស់ក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក** | | | | **៩៤.០០០** | | | | | | | | | | | | | | | | | | | | |
| ១.៣.១ | សាងសង់ប៉មសម្រាប់ក្រុមល្បាតអង្កេតមើលភ្លើងឆេះព្រៃលិចទឹក (៨.០០០$ x ៥ប៉ម) | ៥កន្លែង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៤០.០០០ | | | | | ៨.០០០ | | | | ១៦.០០០ | | | | ១៦.០០០ | | | | | | | |
| | | | | | | | | | | ១កន្លែង | | | | ២កន្លែង | | | | ២កន្លែង | | | | | | | |
| | | | | | | | | | | H | H | | | H | H | | | H | H | | | | | | |
| ១.៣.២ | ស្តារស្រះ/បឹងធម្មជាតិដើម្បីរក្សាទឹកទុកសម្រាប់ពន្លត់ភ្លើងឆេះព្រៃ និងអភិរក្សត្រីមេពូជ (៤.៥០០$ x ១២ស្រះ) | ១២កន្លែង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៥៤.០០០ | | | | | ១៨.០០០ | | | | ១៨.០០០ | | | | ១៨.០០០ | | | | | | | |
| | | | | | | | | | | ៤កន្លែង | | | | ៤កន្លែង | | | | ៤កន្លែង | | | | | | | |
| | | | | | | | | | | H | H | | | H | H | | | H | H | | | | | | |
| **២** | **លទ្ធផលទី២៖ ភាពប្រសើរឡើងនូវការជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក** | | | | **១២១.០៤០** | | | | | | | | | | | | | | | | | | | | |
| ២.១ | តាមដានសេចក្តីរាយការណ៍ប្រចាំថ្ងៃ ដើម្បីជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃទៅតាមតម្រូវការបន្ទាន់របស់ក្រុមល្បាត (១០០$ x ៣ករណី x ១៩ឃុំ x ៥ឆ្នាំ) | ២៨៥ករណី | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២៨.៥០០ | ៨.៥០០ | | | | ៧.១០០ | | | | ៥.៧០០ | | | | ៤.៣០០ | | | | ២.៩០០ | | | |
| | | | | | | ៨៥ករណី | | | | ៧១ករណី | | | | ៥៧ករណី | | | | ៤៣ករណី | | | | ២៩ករណី | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |
| ២.២ | ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិស្តីពីការរៀបចំសំណុំរឿងបទល្មើសជលផលដល់មន្ត្រីខណ្ឌរដ្ឋបាលជលផល (៤៥$ x ៣នាក់ x ៤ថ្ងៃ) | ១វគ្គ | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៥៤០ | | | | | ៥៤០ | | | | | | | | | | | | | | | |
| | | | | | | | | | | ១វគ្គ | | | | | | | | | | | | | | | |
| | | | | | | | | | | | | H | | | | | | | | | | | | | |
| ២.៣ | ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ខេត្តស្តីពីការប្រមូលភស្តុតាង និងការរៀបចំសំណុំរឿងបទល្មើសជលផលជូនមន្ត្រីខណ្ឌរដ្ឋបាលជលផល (៤៥$ x ២០នាក់ x ៣ថ្ងៃ) | ១វគ្គ | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ២.៧០០ | | | | | ២.៧០០ | | | | | | | | | | | | | | | |
| | | | | | | | | | | ១វគ្គ | | | | | | | | | | | | | | | |
| | | | | | | | | | | | | | H | | | | | | | | | | | | |
| ២.៤ | ពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងជនល្មើសដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងទន្ទ្រានរំលោភយកដីព្រៃលិចទឹកធ្វើជាកម្មសិទ្ធិខុសច្បាប់ (១៨០$ x ២ករណី x ១៩ឃុំ x ៥ឆ្នាំ) | ១៩០ករណី | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣៤.២០០ | ១០.២៦០ | | | | ៨.៤៦០ | | | | ៦.៨៤០ | | | | ៥.០៤០ | | | | ៣.៦០០ | | | |
| | | | | | | ៥៧ករណី | | | | ៤៧ករណី | | | | ៣៨ករណី | | | | ២៨ករណី | | | | ២០ករណី | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |

<table>
<tr><td rowspan="3">២.៥</td><td rowspan="3">ថវិកាសម្រាប់ថែរក្សា និងទិញបន្ថែមឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកតាមតម្រូវការចាំបាច់ (១០០$ x ៥ខែ x ១៩ឃុំ x ៥ឆ្នាំ)</td><td rowspan="3">សរុប</td><td rowspan="3">សង្កាត់រដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរឃុំ</td><td rowspan="3">៤៧.៥០០</td><td colspan="4">៩.៥០០</td><td colspan="4">៩.៥០០</td><td colspan="4">៩.៥០០</td><td colspan="4">៩.៥០០</td><td colspan="4">៩.៥០០</td></tr>
<tr><td colspan="4">សរុប</td><td colspan="4">សរុប</td><td colspan="4">សរុប</td><td colspan="4">សរុប</td><td colspan="4">សរុប</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td rowspan="3">២.៦</td><td rowspan="3">រៀបចំសិក្ខាសាលាថ្នាក់ខេត្តដើម្បីចែករំលែកមេរៀន បទពិសោធន៍នៃការទប់ស្កាត់និងការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹក (២.៨០០$ x ១វគ្គ)</td><td rowspan="3">១វគ្គ</td><td rowspan="3">រដ្ឋបាលជលផល</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">២.៨០០</td><td colspan="4">២.៨០០</td><td colspan="4"></td><td colspan="4"></td><td colspan="4"></td><td colspan="4"></td></tr>
<tr><td colspan="4">១វគ្គ</td><td colspan="4"></td><td colspan="4"></td><td colspan="4"></td><td colspan="4"></td></tr>
<tr><td></td><td></td><td>H</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="3">២.៧</td><td rowspan="3">ផ្តល់រង្វាន់លើកទឹកចិត្តដល់បុគ្គលដែលបានចូលរួមយ៉ាងសកម្ម ឬ រងរបួសក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃ (៨០$ x ៦០នាក់)</td><td rowspan="3">៦០នាក់</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរមូលដ្ឋាន</td><td rowspan="3">៤.៨០០</td><td colspan="4">១.២៨០</td><td colspan="4">១.២៨០</td><td colspan="4">៩៦០</td><td colspan="4">៨០០</td><td colspan="4">៤៨០</td></tr>
<tr><td colspan="4">១៦នាក់</td><td colspan="4">១៦នាក់</td><td colspan="4">១២នាក់</td><td colspan="4">១០នាក់</td><td colspan="4">៦នាក់</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td>៣</td><td colspan="4">លទ្ធផលទី៣៖ ព្រៃលិចទឹកដែលត្រូវភ្លើងឆេះបានស្តារឡើងវិញ</td><td>២២០.១១០</td><td colspan="20"></td></tr>
<tr><td rowspan="3">៣.១</td><td rowspan="3">ចូលរួមក្នុងការវាយតម្លៃដោយឆាប់រហ័សដើម្បីកំណត់វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានឆេះ (៨០$ x ៣ថ្ងៃ x ៤ស្រុក x ៥ឆ្នាំ) + (៦០$ x ៤ផែនទី x ៥ឆ្នាំ)</td><td rowspan="3">៥របាយការណ៍ថ្នាក់ស្រុក</td><td rowspan="3">រដ្ឋបាលជលផល និង FAO</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">៦.០០០</td><td colspan="4">១.២០០</td><td colspan="4">១.២០០</td><td colspan="4">១.២០០</td><td colspan="4">១.២០០</td><td colspan="4">១.២០០</td></tr>
<tr><td colspan="4">១របាយការណ៍</td><td colspan="4">១របាយការណ៍</td><td colspan="4">១របាយការណ៍</td><td colspan="4">១របាយការណ៍</td><td colspan="4">១របាយការណ៍</td></tr>
<tr><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td></tr>
<tr><td rowspan="3">៣.២</td><td rowspan="3">បោះបង្គោលស៊ីម៉ង់ត៍ និងដាក់ស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ភ្លើងឆេះព្រៃលិចទឹក (៦០$ x ៦០០បង្គោល)</td><td rowspan="3">៦០០បង្គោល</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរមូលដ្ឋាន</td><td rowspan="3">៣៦.០០០</td><td colspan="4">១០.៨០០</td><td colspan="4">៩.០០០</td><td colspan="4">៧.២០០</td><td colspan="4">៥.៤០០</td><td colspan="4">៣.៦០០</td></tr>
<tr><td colspan="4">១៨០បង្គោល</td><td colspan="4">១៥០បង្គោល</td><td colspan="4">១២០បង្គោល</td><td colspan="4">៩០បង្គោល</td><td colspan="4">៦០បង្គោល</td></tr>
<tr><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="3">៣.៣</td><td rowspan="3">ចូលរួមសិក្ខាសាលាថ្នាក់ខេត្តស្តីពីបច្ចេកទេសគ្រប់គ្រងថ្នាលបណ្តុះកូនព្រៃលិចទឹក និងវិធីសាស្ត្រស្តារព្រៃលិចទឹក (១.៧០០$ x ២វគ្គ)</td><td rowspan="3">២វគ្គ</td><td rowspan="3">រដ្ឋបាលជលផល និង FAO</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">៣.៤០០</td><td colspan="4"></td><td colspan="4">១.៧០០</td><td colspan="4"></td><td colspan="4">១.៧០០</td><td colspan="4"></td></tr>
<tr><td colspan="4"></td><td colspan="4">១វគ្គ</td><td colspan="4"></td><td colspan="4">១វគ្គ</td><td colspan="4"></td></tr>
<tr><td></td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="3">៣.៤</td><td rowspan="3">ប្រជុំពិគ្រោះយោបល់នៅថ្នាក់ឃុំជាមួយអ្នកពាក់ព័ន្ធពិភាក្សាអំពីការស្តារព្រៃលិចទឹកដែលខូចខាតដោយភ្លើងឆេះ (៦៨$ x ១៩ប្រជុំ/ឃុំ x ៥ឆ្នាំ)</td><td rowspan="3">៩៥ប្រជុំ</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរមូលដ្ឋាន</td><td rowspan="3">៦.៤៦០</td><td colspan="4">១.២៩២</td><td colspan="4">១.២៩២</td><td colspan="4">១.២៩២</td><td colspan="4">១.២៩២</td><td colspan="4">១.២៩២</td></tr>
<tr><td colspan="4">១៩ប្រជុំ</td><td colspan="4">១៩ប្រជុំ</td><td colspan="4">១៩ប្រជុំ</td><td colspan="4">១៩ប្រជុំ</td><td colspan="4">១៩ប្រជុំ</td></tr>
<tr><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td></tr>
<tr><td rowspan="3">៣.៥</td><td rowspan="3">គាំទ្រសហគមន៍ក្នុងការរៀបចំថ្នាល និងបណ្តុះកូនព្រៃលិចទឹកសំរាប់ការស្តារព្រៃលិចទឹកដែលបានឆេះ (២០០$x១ថ្នាលx៤ស្រុកx៥ឆ្នាំ)</td><td rowspan="3">២០ថ្នាល</td><td rowspan="3">សង្កាត់រដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">៤.០០០</td><td colspan="4">៨០០</td><td colspan="4">៨០០</td><td colspan="4">៨០០</td><td colspan="4">៨០០</td><td colspan="4">៨០០</td></tr>
<tr><td colspan="4">៤ថ្នាល</td><td colspan="4">៤ថ្នាល</td><td colspan="4">៤ថ្នាល</td><td colspan="4">៤ថ្នាល</td><td colspan="4">៤ថ្នាល</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td></td><td></td><td>H</td><td>H</td><td></td><td></td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td rowspan="3">៣.៦</td><td rowspan="3">គាំទ្រ និងត្រួតពិនិត្យការដាំកូនព្រៃលិចទឹកដោយសហគមន៍មូលដ្ឋាននៅក្នុងតំបន់ស្តារព្រៃលិចទឹក (៥.៨៥០$)</td><td rowspan="3">១៣០ហិកតា</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរមូលដ្ឋាន</td><td rowspan="3">៥.៨៥០</td><td colspan="4">៨១០</td><td colspan="4">១.២៦០</td><td colspan="4">១.២៦០</td><td colspan="4">១.២៦០</td><td colspan="4">១.២៦០</td></tr>
<tr><td colspan="4">១៨ហិកតា</td><td colspan="4">២៨ហិកតា</td><td colspan="4">២៨ហិកតា</td><td colspan="4">២៨ហិកតា</td><td colspan="4">២៨ហិកតា</td></tr>
<tr><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td></tr>
<tr><td rowspan="3">៣.៧</td><td rowspan="3">ចំណាយដាំកូនព្រៃលិចទឹកគិតទាំងតម្លៃកូនឈើ ការដឹកជញ្ជូន និងការដាំ (១$ x ១.១០០ដើម x ១៣០ហ.ត)</td><td rowspan="3">១៤៣.០០០ ដើម</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">១៤៣.០០០</td><td colspan="4">១៩.៨០០</td><td colspan="4">៣០.៨០០</td><td colspan="4">៣០.៨០០</td><td colspan="4">៣០.៨០០</td><td colspan="4">៣០.៨០០</td></tr>
<tr><td colspan="4">១៨ហ.ត<br>១៩.៨០០ដើម</td><td colspan="4">២៨ហ.ត<br>៣០.៨០០ដើម</td><td colspan="4">២៨ហ.ត<br>៣០.៨០០ដើម</td><td colspan="4">២៨ហ.ត<br>៣០.៨០០ដើម</td><td colspan="4">២៨ហ.ត<br>៣០.៨០០ដើម</td></tr>
<tr><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td><td></td><td></td><td>H</td><td></td></tr>
<tr><td rowspan="3">៣.៨</td><td rowspan="3">ចំណាយថែទាំកូនឈើដែលបានដាំនៅក្នុងតំបន់ស្តារព្រៃលិចទឹកដោយសហគមន៍ (១០០$ x ១៣០ ហ.ត)</td><td rowspan="3">១៣០ ហិកតា</td><td rowspan="3">សង្កាត់រដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">១៣.០០០</td><td colspan="4">១.៨០០</td><td colspan="4">២.៨០០</td><td colspan="4">២.៨០០</td><td colspan="4">២.៨០០</td><td colspan="4">២.៨០០</td></tr>
<tr><td colspan="4">១៨ ហ.ត</td><td colspan="4">២៨ ហ.ត</td><td colspan="4">២៨ ហ.ត</td><td colspan="4">២៨ ហ.ត</td><td colspan="4">២៨ ហ.ត</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
</table>

| | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៩ | វាយតម្លៃអត្រារស់ និងលូតលាស់នៃកូនព្រៃលិចទឹកនៅក្នុងតំបន់ស្តារព្រៃលិចទឹក (សរុប:២.៤០០$) | ១២០ ហិកតា | រដ្ឋបាលជលផល និង FAO | ខណ្ឌរដ្ឋបាលជលផល | ២.៤០០ | | | | | | | | | ៦០០ | | | | ៦០០ | | | | ១.២០០ | | | |
| | | | | | | | | | | | | | | ៣០ហិកតា | | | | ៣០ហិកតា | | | | ៦០ហិកតា | | | |
| | | | | | | | | | | | | | | H | | | | H | | | | H | | | |
| **៤** | **ការចុះគាំទ្រ តាមដាន និងវាយតំលៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃ** | | | | **៦១.២០០** | | | | | | | | | | | | | | | | | | | | |
| ៤.១ | ចូលរួមក្នុងការប្រមូលទិន្នន័យដើម (baseline survey) នៅឃុំគោលដៅដែលអនុវត្តដោយក្រុមការងាររដ្ឋបាលជលផល និងគម្រោងCAPFISH (សរុបៈ ១.២០០$) | ១ដង | រដ្ឋបាលជលផល/FAO | ខណ្ឌរដ្ឋបាលជលផល | ១.២០០ | ១.២០០ | | | | | | | | | | | | | | | | | | | |
| | | | | | | ១ដង | | | | | | | | | | | | | | | | | | | |
| | | | | | | | | H | | | | | | | | | | | | | | | | | |
| ៤.២ | ចូលរួមក្នុងការគាំទ្រ និងតម្រង់ទិសការអនុវត្តផែនការគ្រប់គ្រងព្រៃលិចទឹកដោយក្រុមការងារបច្ចេកទេសនៃរដ្ឋបាលជលផល (៤៥$ x ២នាក់ x ១ដង x ៦ខែ x ៤ស្រុក x ៥ឆ្នាំ) | ១២០ដង | រដ្ឋបាលជល | ខណ្ឌរដ្ឋបាលជលផល | ១០.៨០០ | ២.១៦០ | | | | ២.១៦០ | | | | ២.១៦០ | | | | ២.១៦០ | | | | ២.១៦០ | | | |
| | | | | | | ២៤ដង | | | | ២៤ដង | | | | ២៤ដង | | | | ២៤ដង | | | | ២៤ដង | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |
| ៤.៣ | ចវិកាសម្រាប់មន្ត្រីរដ្ឋបាលជលផលចុះគាំទ្រ ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសដល់ការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រចាំខែ(៨២០$ x ២ដង x ៦ខែ x ៥ឆ្នាំ) | ៦០ដង | រដ្ឋបាលជល | ខណ្ឌរដ្ឋបាលជលផល | ៤៩.២០០ | ៩.៨៤០ | | | | ៩.៨៤០ | | | | ៩.៨៤០ | | | | ៩.៨៤០ | | | | ៩.៨៤០ | | | |
| | | | | | | ១២ដង | | | | ១២ដង | | | | ១២ដង | | | | ១២ដង | | | | ១២ដង | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |
| | | | | | **សរុប: ៨៨៦.២០៥** | | | | | | | | | | | | | | | | | | | | |

# ១០. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ថ្នាក់ស្រុក ឆ្នាំ២០២១-២០២៥

## ១០.១ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ស្រុកឯកទី្ត ឆ្នាំ២០២១-២០២៥

| ល.រ | សកម្មភាព | សូចនាករ (៥ឆ្នាំ) | ភាគីពាក់ព័ន្ធ | | ថវិកា (2021-2025) | ២០២១ (ត្រីមាស) | | | | ២០២២ (ត្រីមាស) | | | | ២០២៣ (ត្រីមាស) | | | | ២០២៤ (ត្រីមាស) | | | | ២០២៥ (ត្រីមាស) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អ្នកដឹកនាំ | អ្នកគាំទ្រ | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| **១** | **លទ្ធផលទី១៖ ការសិក្សាពិនិត្យឡើងវិញនូវការកាត់បន្ថយហានិភ័យ និងភាពត្រៀមខ្លួនរួចជាស្រេចក្នុងការបង្កា ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានប្រសិទ្ធភាព។** | | | | **១៣០.៩១៩** | | | | | | | | | | | | | | | | | | | | |
| **១.១** | **ការសិក្សាពិនិត្យឡើងវិញអំពីទម្រង់ បទពិសោធន៍ និងយុទ្ធសាស្ត្រនៃការទប់ស្កាត់ ការពន្លត់ភ្លើងឆេះព្រៃ និងការស្តារព្រៃលិចទឹកឡើងវិញ ដែលបានអនុវត្តកន្លងមក។** | | | | **៤.៨០០** | | | | | | | | | | | | | | | | | | | | |
| ១.១.១ | ប្រជុំជាមួយអ្នកពាក់ព័ន្ធនៅថ្នាកឃុំដើម្បីប្រមូលពត៌មានបទពិសោធន៍ និងយុទ្ធសាស្ត្រនៃការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក (៤៥$ x ៥ប្រជុំ x ៥ឆ្នាំ) | ២៥ប្រជុំថ្នាក់ឃុំ ៥របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ភូមិ និងឃុំ | ១.១២៥ | ២២៥ | | | | ២២៥ | | | | ២២៥ | | | | ២២៥ | | | | ២២៥ | | | |
| | | | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | |
| | | | | | | H | | | M | | | | M | | | | M | | | | M | | | | M |
| ១.១.២ | អង្កេតតំបន់ភ្លើងឆេះព្រៃលិចទឹកដើម្បីប្រមូលនិយាមកា និងព័ត៌មានអំពីទិដ្ឋភាពភូមិ-រូបសាស្ត្រ-ឋានលេខា ទំហំនៃការខូចខាត ការប្រើប្រាស់ដី និងគម្របដីមុន និងក្រោយពេលភ្លើងឆេះ (៤៥$ x ៣ ថ្ងៃ x ៥ឃុំ x ៥ឆ្នាំ) | ២៥ដងថ្នាក់ឃុំ ៥របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | សង្កាត់រដ្ឋបាលជលផល អាជ្ញាធរឃុំ និងសហគមន៍នេសាទ | ៣.៣៧៥ | ៤៥០ | | | | ៤៥០ | | | | ៤៥០ | | | | ៤៥០ | | | | ៤៥០ | | | |
| | | | | | | ៥ដង ១របាយការណ៍ | | | | ៥ដង ១របាយការណ៍ | | | | ៥ដង ១របាយការណ៍ | | | | ៥ដង ១របាយការណ៍ | | | | ៥ដង ១របាយការណ៍ | | | |
| | | | | | | H | H | | H | H | | | H | H | | | H | H | | | H | H | | | |
| ១.១.៣ | ផលិតផែនទីតំបន់ភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក (៦០$ x ១ផែនទី x ៥ឆ្នាំ) | ៥ផែនទី | នាយកដ្ឋានកិច្ចការជលផល | ខណ្ឌរដ្ឋបាលជលផល | ៣០០ | ៦០ | | | | ៦០ | | | | ៦០ | | | | ៦០ | | | | ៦០ | | | |
| | | | | | | ១ផែនទី | | | | ១ផែនទី ធ្វើបច្ចុប្បន្នភាព | | | | ១ផែនទី ធ្វើបច្ចុប្បន្នភាព | | | | ១ផែនទី ធ្វើបច្ចុប្បន្នភាព | | | | ១ផែនទី ធ្វើបច្ចុប្បន្នភាព | | | |
| | | | | | | H | | | H | H | | | H | H | | | H | H | | | H | H | | | H |
| **១.២** | **<u>ការកាត់បន្ថយហានិភ័យ</u>នៃភ្លើងឆេះព្រៃលិចទឹកដោយការលើកកំពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍ មូលដ្ឋានក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៤២.១៥០** | | | | | | | | | | | | | | | | | | | | |
| ១.២.១ | ផលិតផ្ទាំងរូបភាពផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក (១,៥$ x ១០០សន្លឹក x ៥ឃុំ x ៥ឆ្នាំ) | ២.៥០០សន្លឹក | រដ្ឋបាលជលផល | អង្គការ FAO | ៣.៧៥០ | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | |
| | | | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | |
| | | | | | | H | | | | H | | | | H | | | | H | | | | H | | | |
| ១.២.២ | តម្លើងស្លាកផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក (៣០០$ x ២ ស្លាក x ៥ឃុំ) | ១០ស្លាក | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣.០០០ | ៦០០ | | | | ១.៥០០ | | | | ៩០០ | | | | | | | | | | | |
| | | | | | | ២ស្លាក | | | | ៥ស្លាក | | | | ៣ស្លាក | | | | | | | | | | | |
| | | | | | | M | | | | M | | | | M | | | | | | | | | | | |
| ១.២.៣ | រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមអ្នកពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផលនៅក្នុងតំបន់២ និងតំបន់៣ (១០០$ x ៥ឃុំ x ៥ឆ្នាំ) | ២៥ច្បាប់ | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២.៥០០ | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | |
| | | | | | | ៥ច្បាប់ | | | | ៥ច្បាប់ បច្ចុន្នភាព | | | | ៥ច្បាប់ បច្ចុន្នភាព | | | | ៥ច្បាប់ បច្ចុន្នភាព | | | | ៥ច្បាប់ បច្ចុន្នភាព | | | |
| | | | | | | | | | H | | | | H | | | | H | | | | H | | | | H |
| ១.២.៤ | ផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីការចូលរួមគ្រប់គ្រងភ្លើងឆេះព្រៃ ច្បាប់ជលផល អនុក្រឹត្យ គោលនយោបាយ និង | ៥០ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៧.៥០០ | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | |
| | | | | | | ១០ប្រជុំ | | | | ១០ប្រជុំ | | | | ១០ប្រជុំ | | | | ១០ប្រជុំ | | | | ១០ប្រជុំ | | | |
| | | | | | | H | H | | | H | H | | | H | H | | | H | H | | | H | H | | |

| | | | | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|---|---|---|---|
| | លិខិតបទដ្ឋានពាក់ព័ន្ធ (១៥០$ x ២ប្រជុំ x ៥ឃុំ x ៥ឆ្នាំ) | | | | | | | | | |
| ១.២.៥ | រៀបចំរចនាសម្ព័ន្ធក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ និង ផែនការចុះល្បាត (៨០$ x ៥ឃុំ) | ៥ក្រុម | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៤០០ | ៤០០<br>៥ក្រុម<br>H | | | | |
| ១.២.៦ | ចុះល្បាតឃ្លាំមើលភ្លើងឆេះព្រៃលិចទឹក៖ ៥ថ្ងៃ/ខែ (២៥០$ x ៤ខែ x ៥ឃុំ x ៥ឆ្នាំ) | ៥០០ដង | ក្រុមល្បាត និង សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២៥.០០០ | ៥.០០០<br>១០០ថ្ងៃ<br>H H | ៥.០០០<br>១០០ថ្ងៃ<br>H H | ៥.០០០<br>១០០ថ្ងៃ<br>H H | ៥.០០០<br>១០០ថ្ងៃ<br>H H | ៥.០០០<br>១០០ថ្ងៃ<br>H H |
| **១.៣** | **<u>ការត្រៀមខ្លួនជាស្រេច</u>៖ រៀបចំរចនាសម្ព័ន្ធការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក និងខេត្ត និងសម្ភារៈសំរាប់ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៨៣.៩៦៩** | | | | | |
| **១.៣.១** | **បង្កើត និងពង្រឹងទំនាក់ទំនងរវាងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត និងក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ ដើម្បីជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ និងបំពាក់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត** | | | | **៥៤.៤៦៩** | | | | | |
| ១.៣.១.១ | ប្រជុំជាមួយរដ្ឋបាលស្រុកពិភាក្សាអំពីឯកសារចាំបាច់ដែលត្រូវរៀបចំ ដើម្បីបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក (៦៥$ x ១ប្រជុំ/ស្រុក) | ១ប្រជុំ & សេចក្តីព្រាងToRs របស់ក្រុមការងារ | រដ្ឋបាល និងខណ្ឌរដ្ឋបាលជលផល មន្ទីរក.រ.ន | រដ្ឋបាលខេត្ត និង ស្រុកគោលដៅ | ៦៥ | ៦៥<br>១ប្រជុំ<br>H | | | | |
| ១.៣.១.២ | ប្រជុំបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក (៦៥$ x ១ប្រជុំ/ស្រុក) | ១ក្រុម | រដ្ឋបាល និងខណ្ឌរដ្ឋបាលជលផល មន្ទីរក.រ.ន | រដ្ឋបាលខេត្ត និង ស្រុកគោលដៅ | ៦៥ | ៦៥<br>១ក្រុម<br>H | | | | |
| ១.៣.១.៣ | ចូលរួមប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ខេត្តដើម្បីពិភាក្សាអំពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ និងស្វែងរកដំណោះស្រាយបញ្ហា (៣៩៤$x ១ប្រជុំx ៥ឆ្នាំ) | ៥ប្រជុំ | រដ្ឋបាល និងខណ្ឌរដ្ឋបាលជលផល មន្ទីរក.រ.ន | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត | ១.៩៧៤ | ៣៩៤<br>១ប្រជុំ<br>H H | ៣៩៤<br>១ប្រជុំ<br>H H | ៣៩៤<br>១ប្រជុំ<br>H H | ៣៩៦<br>១ប្រជុំ<br>H H | ៣៩៦<br>១ប្រជុំ<br>H H |
| ១.៣.១.៤ | រៀបចំប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក ប្រចាំត្រីមាសដើម្បីពិភាក្សាអំពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ ស្វែងដំណោះស្រាយបញ្ហា និងលើកផែនការគាំទ្រការល្បាតនៅថ្នាក់ឃុំ (៣២០$ x ២ប្រជុំ x ៥ឆ្នាំ) | ១០ប្រជុំ | ខណ្ឌរដ្ឋបាលជលផល និង មន្ទីរក.រ.ន | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ៣.២០០ | ៦៤០<br>២ប្រជុំ<br>H H | ៦៤០<br>២ប្រជុំ<br>H H | ៦៤០<br>២ប្រជុំ<br>H H | ៦៤០<br>២ប្រជុំ<br>H H | ៦៤០<br>២ប្រជុំ<br>H H |
| ១.៣.១.៥ | ទិញកាឡេថងបំពាក់ដោយម៉ាស៊ីនបូមទឹក២ ធុងទឹកចំណុះ១០០០L ទុយោ២ដុំ និងកាំភ្លើងបាញ់ទឹក២ដើម (៣.៦០០$ x ៤គ្រឿង) | ៤គ្រឿង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ១៤.៤០០ | H | ៧.២០០<br>២គ្រឿង<br>H H | ៧.២០០<br>២គ្រឿង<br>H | | |
| ១.៣.១.៦ | ទិញកាណូតបំពាក់ដោយម៉ាស៊ីនបូមទឹក២គ្រឿង ធុងទឹកចំណុះ ១.០០០L កាំភ្លើងបាញ់ទឹក២ដើម និងទុយោ២ដុំ (៣.០០០$ x ២ គ្រឿង) | ២គ្រឿង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៦.០០០ | ៣.០០០<br>១គ្រឿង<br>H | ៣.០០០<br>១គ្រឿង<br>H | | | |
